# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

## គម្រោងប្រយុទ្ធនឹងជំងឺឆ្លងទី២ ក្នុងមហាអនុតំបន់មេគង្គ

គាំទ្រដោយ

## ធនាគារអភិវឌ្ឍន៍អាស៊ី

ADB Grant No 0231-CAM

# សៀវភៅមគ្គុទេសន៍សំរាប់គ្រូសម្របសម្រួល

## វគ្គបណ្តុះបណ្តាល

## ការប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន

(ការកសាងភូមិសុខភាពគំរូ)

## ឆ្នាំ ២០១៣

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

# អារម្ភកថា

ដោយមានការឧបត្ថម្ភ គាំទ្រ និងគំនិតផ្តួចផ្តើម ក្នុងការបង្កើតឲ្យមានជាភូមិសុខភាពគំរូ ពីធនាគារអភិវឌ្ឍន៍អាស៊ី នៃគម្រោងប្រយុទ្ធនឹងជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គជំហានទី២ ដែលផ្តល់អន្តរាគមន៍ដល់ តំបន់ ភូមិ ឃុំ ជាប់ព្រំដែន ពិសេសក្នុងខេត្តជម្រើសទាំង ១០ រួមមានខេត្ត ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង កណ្តាល តាកែវ និង កំពត និងដោយយោងតាមសេចក្តីណែនាំអំពីការគ្រប់គ្រង និងការអនុវត្តន៍យុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺឆ្លង នៅតាមសហគមន៍មូលដ្ឋាន ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសុខាភិបាល នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ដោយមានកិច្ចសហប្រតិបត្តិការជាមួយ ដៃគូអភិវឌ្ឍន៍សំខាន់ៗ ដូចជា៖ អង្គការសុខភាពពិភពលោក(WHO) អង្គការយូនីសេហ្វ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមាន អង្គការ RACHA, World Vison, RHAC បានរៀបចំកម្មវិធីសិក្សាសំរាប់ប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាននេះឡើង ដើម្បីអនុវត្តសេចក្តីណែនាំអំពីការគ្រប់គ្រង និង ការអនុវត្តន៍ យុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺឆ្លង នៅតាមសហគមន៍មូលដ្ឋាន បានដោយជោគជ័យ និងដើម្បីតំរង់ទិស មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព ភ្នាក់ងារអនុវត្តគម្រោង និងដៃគូពាក់ព័ន្ធនានា។

កម្មវិធីសិក្សានេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីផ្តល់ការបណ្តុះបណ្តាល ដល់ក្រុមគ្រប់គ្រងភូមិនៃភូមិសុខភាពគំរូ ក្នុងការផ្តល់ការអប់រំ និងលើកកំពស់សុខភាពប្រកបដោយប្រសិទ្ធភាពនៅថ្នាក់សហគមន៍ (ភូមិ) សំរាប់ប្រជាជនគ្រប់វ័យ ។ កម្មវិធីសិក្សានេះ ទទួលស្គាល់ថា ការចូលរួមយ៉ាងសកម្មរបស់សហគមន៍និងគ្រួសារមានសារៈសំខាន់យ៉ាងខ្លាំង នៅក្នុងការកសាងភូមិសុខភាពគំរូនៅកម្ពុជា។ វារួមចំណែកជួយជំរុញសហគមន៍និងគ្រួសារដើម្បីថែទាំសុខភាពឲ្យកាន់តែប្រសើរឡើងសំរាប់សមាជិកគ្រួសារនិងសហគមក៍ទាំងមូល ដែលជាជំហ៊ានមួយដ៏មានសារៈសំខាន់បំផុតឆ្ពោះទៅរកការកាត់បន្ថយការរាលដាលជំងឺឆ្លង និងធ្វើឲ្យប្រសើរឡើងនូវសុខភាព ប្រជាជនទូទៅ។

ក្រសួងសុខាភិបាល សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាសំរាប់ប្រយុទ្ធនឹងជំងឺឆ្លង នៅតាមសហគមន៍មូលដ្ឋាននេះ នឹងប្រើជាឯកសារយោង ជាមូលដ្ឋាន សំរាប់ពង្រឹងសមត្ថភាពក្រុមគ្រប់គ្រងភូមិដោយ ផ្តល់នូវអត្ថប្រយោជន៍ ដល់ប្រជាជនក្នុងសហគមន៍ សំរាប់ធ្វើឲ្យប្រសើរឡើង នូវការប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍ និងរួមចំណែកដល់ការកាត់បន្ថយអត្រាឈឺនិងអត្រាស្លាប់ របស់ប្រជាពលរដ្ឋគ្រប់វ័យ សំដៅឈានទៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សឆ្នាំ២០១៥ ដែលនេះ ក៏ជាការចូលរួមចំណែក ក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ របស់រាជរដ្ឋាភិបាលផងដែរ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៣

**ស. រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**រដ្ឋលេខាធិការ**

សាស្ត្រាចារ្យ **អេង ហួត**

# សេចក្តីថ្លែងអំណរគុណ

បុគ្គលិក និងអង្គការជាច្រើន បានផ្តល់ការចូលរួមចំណែក និងធនធានដ៏មានតម្លៃដល់ការអភិវឌ្ឍន៍កម្មវិធីសិក្សានេះ។ លោកវេជ្ជបណ្ឌិត សុខ ទូច ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង បានដឹកនាំកិច្ចខិតខំប្រឹងប្រែងនេះដោយមានការជួយឧបត្ថម្ភផ្នែកថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី ។ លោកស្រី វេជ្ជបណ្ឌិត តេង ស្រី អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង លោក លុយតិចឆេង មន្ត្រីជំនាញផ្នែកយេនឌ័រ របស់កម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទីពីរ (ADB/GMS-CDC2) លោកវេជ្ជបណ្ឌិត ភីធី ចន មីលឡឺ ប្រធានទីប្រឹក្សាបច្ចេកទេស របស់កម្មវិធីទ្រទ្រង់វិស័យសុខាភិបាលជំហានទីពីរ (ADB/GMS-CDC2) និង លោក សូននី អ៊ីនបារាហ្គ គ្រីសនាន មន្ត្រីប្រាស្រ័យទាក់ទង និងទំនាក់ទំនងសារព័ត៌មាន របស់អង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា (WHO) បានរួមចំណែកយ៉ាងសកម្ម នៅក្នុងការធ្វើឲ្យមានកម្មវិធីសិក្សានេះលេចចេញជារូបរាងឡើង។

សូមថ្លែងអំណរគុណផងដែរដល់ សិក្ខាកាមចូលរួម ក្នុងសិក្ខាសាលា ពិគ្រោះយោបល់ពិនិត្យពង្រាងកម្មវិធីបណ្តុះបណ្តាលការប្រយុទ្ធនឹងជំងឺឆ្លង នៅតាមសហគមន៍មូលដ្ឋាន នៃការអនុវត្តន៍ភូមិសុខភាពគំរូ មកពី កម្មវិធីជាតិដូចជា កម្មវិធីជាតិប្រយុទ្ធនឹងជំងឺរលាកផ្លូវដង្ហើមស្រួច រាគ និងអាសន្នរោគ កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម កម្មវិធីជាតិកំចាត់ជំងឺដង្កូវព្រូន មន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ នៃខេត្តទាំង១០រួមមានខេត្ត ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង កណ្តាល តាកែវ និង កំពត ដែលអនុវត្តគម្រោងប្រយុទ្ធនឹងជំងឺឆ្លងក្នុងមហាអនុតំបន់មេគង្គទី២ អង្គការក្រៅរដ្ឋាភិបាលរួមមាន អង្គការ UNICEF, RACHA, World Vison, និង RHAC បានចូលរួមចំណែកនូវយោបល់និងព័ត៌មានត្រឡប់ដ៏មានតម្លៃ ហើយនិងការខិតខំប្រឹងប្រែងរបស់ពួកគេ។

សូមថ្លែងអំណរគុណផងដែរដល់សមាជិកសហគមន៍ជាច្រើន ក្រុមគ្រប់គ្រងភូមិ និងបុគ្គលិកមណ្ឌលសុខភាព ដែលបានរួមចំណែកយ៉ាងសកម្មតាមរយៈការពិភាក្សា កំណត់អាទិភាពជំងឺនៅក្នុងសហគមន៍របស់ខ្លួន។

# មាតិកា


អារម្ភកថា……………………………………………………………………………i
សេចក្តីថ្លែងអំណរគុណ……………………………………………………………ii
មាតិកា……………………………………………………………………………iii

**ម៉ូឌុលទី១ សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាលការប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន**
សេចក្តីផ្តើម និងការសាកល្បងមុនសិក្សា…………………………………………… ៣
គោលបំណងរួម និងវត្ថុបំណងនៃការបណ្តុះបណ្តាល……………………………………… ៥
ការណែនាំសិក្ខាកាមឱ្យស្គាល់គ្នា………………………………………………………… ៧
សារៈសំខាន់នៃក្រុមគ្រប់គ្រងភូមិ………………………………………………………… ៩
តួនាទី និងការទទួលខុសត្រូវរបស់ក្រុមគ្រប់គ្រងសុខភាពភូមិ……………………………… ១២
រចនាសម្ព័ន្ធនៃការអប់រំសុខភាព និងលើកកំពស់សុខភាពនៅថ្នាក់ភូមិ…………………… ១៧
ការសង្ខេប និងការសាកល្បងក្រោយសិក្សា………………………………………………… ២០

**ម៉ូឌុលទី២ ជំងឺរាក**
ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា…………………………………………… ២៧
ជំងឺរាក……………………………………………………………………………… ៣០
ការសង្ខេប និងការសាកល្បងក្រោយសិក្សា………………………………………………… ៣៨

**ម៉ូឌុលទី៣ គ្រុនក្តៅ**
ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា…………………………………………… ៥១
គ្រុនក្តៅ……………………………………………………………………………… ៥៤
ជំងឺពងបែកនៅដៃ ជើង និងមាត់…………………………………………………… ៦២
ការសង្ខេប និងការសាកល្បងក្រោយសិក្សា………………………………………………… ៦៧

**ម៉ូឌុលទី៤ ជំងឺផ្តាសាយ**
ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា…………………………………………… ៧៧
ជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល……………………………… ៨០
ការសង្ខេប និងការសាកល្បងក្រោយសិក្សា………………………………………………… ១០០

**ម៉ូឌុលទី៥ ជំងឺគ្រុនឈាម និង ជំងឺដង្កូវពោះវៀន (ព្រូន)**
ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា…………………………………………… ១១៣
ជំងឺគ្រុនឈាម………………………………………………………………………… ១១៧
ជំងឺដង្កូវពោះវៀន(ព្រូន)……………………………………………………………… ១២៧
ការសង្ខេប និងការសាកល្បងក្រោយសិក្សា………………………………………………… ១៣៦

# ម៉ូឌុលទី១

# សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាល ការប្រយុទ្ធនឹងជំងឺឆ្លង នៅតាមសហគមន៍មូលដ្ឋាន

# សៀវភៅបណ្តុះបណ្តាលក្រុមគ្រប់គ្រងភូមិ

## ម៉ូឌុលទី១ សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាលការប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន

| ចំណងជើងមេរៀន | វត្ថុបំណងនៃការសិក្សា | រយៈពេល* |
|---|---|---|
| ១.ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា | ១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ<br>២. អនុវត្តការសាកល្បងមុនការសិក្សា | ៣០នាទី |
| ២.គោលបំណងរួម និងវត្ថុបំណងនៃការបណ្តុះបណ្តាល | ១. រៀបរាប់ពីគោលបំណងរួមនិងវត្ថុបំណងនៃកម្មវិធីបណ្តុះបណ្តាល | ២៥នាទី |
| ៣. ការណែនាំសិក្ខាកាមឱ្យស្គាល់គ្នា | ១. ប្រាប់ឈ្មោះគ្នាទៅវិញទៅមក និងសាកសួរគ្នានូវព័ត៌មានផ្សេងៗ<br>២. ពិភាក្សាអំពីវិន័យជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាល។ | ២០នាទី |
| ៤. សារៈសំខាន់នៃក្រុមគ្រប់គ្រងភូមិ | ១. ពន្យល់ពីសារៈសំខាន់នៃក្រុមគ្រប់គ្រងភូមិ ចំពោះសហគមន៍របស់គាត់។ | ៤៥នាទី |
| ៥. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមគ្រប់គ្រងសុខភាពភូមិ | ១. ពិពណ៌នាពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមគ្រប់គ្រងសុខភាពភូមិ<br>២. រៀបរាប់ពីអត្ថប្រយោជន៍របស់ក្រុមគ្រប់គ្រងសុខភាពភូមិ។ | ៤៥នាទី |
| ៦. រចនាសម្ព័ន្ធនៃការអប់រំសុខភាព និងលើកកំពស់សុខភាពនៅថ្នាក់ភូមិ | ១. ពន្យល់ពីរចនាសម្ព័ន្ធនៃការអប់រំសុខភាព និងលើកកំពស់សុខភាព នៅថ្នាក់ភូមិ។ | ៤៥នាទី |
| ៧.ការសង្ខេប និងការសាកល្បងក្រោយសិក្សា | ១. រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ<br>២. វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយពេលសិក្សា | ៣០នាទី |
| **សរុប** | | **៤ម៉ោង** |

* ថ្ងៃបណ្តុះបណ្តាលនិមួយៗមានរយៈពេលសរុបម៉ោង (ព្រឹកម៉ោង៨ព្រឹក ដល់៥ល្ងាច)

- រយៈពេលបណ្តុះបណ្តាល៥ម៉ោង (ពេលព្រឹក៣ម៉ោង និងរសៀល២ម៉ោង)
- សម្រាក ២ម៉ោងសម្រាប់អាហារថ្ងៃត្រង់និង១ម៉ោងសម្រាប់អាហារសម្រន់ (ព្រឹក៣០នាទី និងរសៀល៣០នាទី

# សេចក្តីផ្តើមនៃវគ្គបណ្តុះបណ្តាលការប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន

## មេរៀនទី ១៖ សេចក្តីផ្តើម និងការសាកល្បងមុនការសិក្សា រយៈពេល ៣០ នាទី

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច៖

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច៖

១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលនៃម៉ូឌុលនេះ
២. អនុវត្តការសាកល្បងមុនការសិក្សា

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាស់ផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សាថ្ងៃនេះ
- ក្តារខៀន ហ្វឺត ក្រដាស់ផ្ទាំងធំ កន្ត្រៃ និងបង់ស្អិត
- ឯកសារសំណួរសាកល្បងមុនការសិក្សា ដែលបានថតចម្លងរួចសម្រាប់សិក្ខាកាមនីមួយៗ

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- ពិភាក្សាក្រុម
- ការសាកល្បងមុនការសិក្សា

**ដំណាក់កាលសកម្មភាព៖**

**បង្ហាញនូវវត្ថុបំណងរួម**

ការចាប់ផ្តើមមេរៀនៈ អ្នកសម្របសម្រួលទាំងអស់ គួរតែចាប់ផ្តើមដោយការស្វាគមន៍ដល់សិក្ខាកាមទាំងអស់ ចំពោះការបណ្តុះបណ្តាលនេះ។

### វត្ថុបំណងទី ១៖ រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលនៃម៉ូឌុលនេះ

➢ ពិភាក្សាក្រុម

- អ្នកសម្របសម្រួលដឹកនាំសិក្ខាកាមទាំងអស់ ឱ្យពិភាក្សាកំណត់រកនូវវត្ថុបំណងនៃម៉ូឌុលនេះ។ អ្នកសម្របសម្រួលគួរតែមានវត្ថុបំណងនៃម៉ូឌុល ដែលសរសេរលើផ្ទាំងក្រដាសធំ និងដាក់ជូនឱ្យសិក្ខាកាម ទាំងអស់ដើម្បីអាន និងតាមដានការបណ្តុះបណ្តាលនៃម៉ូឌុលនេះ។ សិក្ខាកាមទាំងអស់ គួរតែបានអានគោលបំណងនៃម៉ូឌុល នេះ គ្រប់ៗគ្នា។

អ្នកសម្របសម្រួលគួរតែមានកិច្ចសន្ទនាដូចជា៖ ថ្ងៃនេះយើងនិងរៀនអំពីការចាប់ផ្តើមវគ្គបណ្តុះបណ្តាល ការប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន។ អ្នកសម្របសម្រួលស្នើឲ្យសិក្ខាកាមម្នាក់អានវត្ថុបំណងនៃម៉ូឌុល.

- អ្នកសម្របសម្រួលគួរសួរសិក្ខាកាមទាំងអស់ប្រសិនបើមានសំណួរ។

## វត្ថុបំណងទី ២៖ អនុវត្តការសាកល្បងមុនការសិក្សា

➢ **សាកល្បងមុនការសិក្សា**

- អ្នកសម្របសម្រួលធ្វើការសន្ទនាអាចជាៈមុននឹងយើងចាប់ផ្ដើមយើងធ្វើសំណួរសាកល្បងមុនការសិក្សាដ៏ខ្លីមួយ។ អ្នកនឹងត្រូវធ្វើសំណួរសាកល្បងដូចគ្នា នៅទីបញ្ចប់ វគ្គបណ្ដុះបណ្ដាលម៉ូឌុលនេះគឺជាការសាកល្បងក្រោយការសិក្សាមួយ។ ការសាកល្បងមុនការសិក្សានិងការសាកល្បងក្រោយការសិក្សានិងជួយអ្នកសម្របសម្រួលទាំងឡាយចំណាំថាតើអ្នករៀនបានល្អយ៉ាងដូចម្ដេចក្នុងពេលបណ្ដុះបណ្ដាលនិងបង្ហាញ អ្នកថា តើអ្នករៀនបានប៉ុន្មាន។
- សូមកុំបារម្ភ ប្រសិនបើអ្នកមិនដឹងនូវចម្លើយទាំងអស់នោះ។ សូមព្យាយាម ឆ្លើយនូវសំណួរដូចដែរអ្នកអាចឆ្លើយបាន។
- ផ្ដល់ឲ្យសិក្ខាកាមនិមួយៗនូវក្រដាសចម្លងមុនពេលសាកល្បងមុនការសិក្សា
- រក្សាពិន្ទុនៃការសាកល្បងមុនការសិក្សាដើម្បីប្រៀបធៀបនូវការសាកល្បងក្រោយការសិក្សា

### សំណួរតេស្តមុនការសិក្សា និងក្រោយការសិក្សាៈ

សំណួរខុស-ត្រូវ។ ចម្លើយត្រឹមត្រូវ គឺនៅក្នុងប្រអប់ពណ៌ខ្មៅ។

| | | |
|---|---|---|
| ១. គោលបំណងនៃវគ្គសិក្សានេះ គឺដើម្បីបណ្ដុះបណ្ដាលអ្នកឱ្យក្លាយជាចុងភៅដ៏ល្អម្នាក់ | ត្រូវ | ខុស |
| ២. ក្រុមគ្រប់គ្រងភូមិ អាចផ្ដល់ដំបូន្មាននានាដែលត្រូវធ្វើ ប្រសិនបើមាននរណាម្នាក់ឈឺ | ត្រូវ | ខុស |
| ៣. សម្របសម្រួល/រៀបចំកិច្ចប្រជុំ និងយុទ្ធនាការអប់រំសុខភាព នានានៅក្នុងសហគមន៍ | ត្រូវ | ខុស |
| ៤. ក្រុមគ្រប់គ្រងភូមិ ផ្ដល់នូវការអប់រំសុខភាពដល់អ្នកភូមិ ដើម្បីជានាឲ្យភូមិក្លាយជាភូមិសុខភាពគំរូ | ត្រូវ | ខុស |
| ៥. ក្រុមគ្រប់គ្រងភូមិ ធ្វើរបាយការណ៍ប្រចាំត្រីមាសទៅ គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព | ត្រូវ | ខុស |
| ៦. រៀបចំបង្កើតផែនការសកម្មភាពប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន និងសម្របសម្រួលបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។ | ត្រូវ | ខុស |

ចម្លើយ

| | | |
|---|---|---|
| ១. គោលបំណងនៃវគ្គសិក្សានេះ គឺដើម្បីបណ្ដុះបណ្ដាលអ្នកឱ្យក្លាយជាចុងភៅដ៏ល្អម្នាក់ | ត្រូវ | **ខុស** |
| ២. ក្រុមគ្រប់គ្រងភូមិ អាចផ្ដល់ដំបូន្មាននានាដែលត្រូវធ្វើ ប្រសិនបើមាននរណាម្នាក់ឈឺ | **ត្រូវ** | ខុស |

| | | |
|---|---|---|
| ៣. សម្របសម្រួល/រៀបចំកិច្ចប្រជុំ និង យុទ្ធនាការអប់រំសុខភាព នានានៅក្នុងសហគមន៍ | ត្រូវ | ខុស |
| ៤. ក្រុមគ្រប់គ្រងភូមិ ផ្តល់នូវការអប់រំសុខភាពដល់អ្នកភូមិ ដើម្បីធានាឲ្យភូមិក្លាយជាភូមិសុខភាពគំរូ | ត្រូវ | ខុស |
| ៥. ក្រុមគ្រប់គ្រងភូមិ ធ្វើរបាយការណ៍ប្រចាំត្រីមាសទៅ គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព | ត្រូវ | ខុស |
| ៦. រៀបចំបង្កើតផែនការសកម្មភាពប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន និងសម្របសម្រួលបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។ | ត្រូវ | ខុស |

## មេរៀនទី ២៖ គោលបំណងរួម និងវត្ថុបំណងនៃកម្មវិធីបណ្តុះបណ្តាល រយៈពេល ២៥នាទី

**វត្ថុបំណងនៃការសិក្សា:** នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាចៈ

១. រៀបរាប់ពីគោលបំណងរួមនិងវត្ថុបំណងនៃកម្មវិធីបណ្តុះបណ្តាល

**សម្ភារៈជំនួយបង្រៀន:**

- ក្រដាសផ្ទាំងធំ មានសរសេរអំពី" គោលបំណងរួមនិងវត្ថុបំណងនៃវគ្គបណ្តុះបណ្តាល"
- ផ្ទាំងក្រដាស ហ្វឺតសម្រាប់សរសេរ និងបង់ស្អិត

**វិធីសាស្ត្របង្រៀន:**

- ការបំផុសគំនិត
- ការពិភាក្សាតាមក្រុម

**ដំណើរការសកម្មភាព:**

**បង្ហាញពីវត្ថុបំណងរួម**

**សេចក្តីផ្តើម**

១." គោលបំណងរួម " គឺដើម្បីបណ្តុះបណ្តាលក្រុមគ្រប់គ្រងភូមិ (ក.គ.ភ) **(VMG)** ឲ្យចេះប្រើប្រាស់ចំណេះដឹង អាកប្បកិរិយា និងជំនាញ ដែលទទួលបានពីការបណ្តុះបណ្តាលនេះ ដើម្បីជួយលើកកម្ពស់សុខភាពប្រជាជនទាំងអស់ក្នុងភូមិរបស់ពួកគាត់ តាមរយៈសកម្មភាពលើកកម្ពស់សហគមន៍ដើម្បីធ្វើឲ្យភូមិរបស់ពួកគេក្លាយជាភូមិសុខភាពគំរូ។

" វត្ថុបំណង" នៃបណ្តុះបណ្តាលគឺលើកកម្ពស់សមត្ថភាពរបស់សិក្ខាកាម ដើម្បីៈ

- ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយសមាជិកឬប្រជាជននៅក្នុងភូមិរបស់ពួកគាត់ទាំងមូល និង ផ្តល់ដំបូន្មានដល់ពួកគេឲ្យប្រកាន់យកនូវឥរិយាបទថ្មី សំដៅលើកកម្ពស់សុខភាពប្រជាជនគ្រប់វ័យ។
- អប់រំប្រជាជនគ្រប់វ័យ នៅក្នុងសហគមន៍ របស់ពួកគេ អំពីការបង្ការជំងឺឆ្លងជាមូលដ្ឋាន និងការលើកកម្ពស់សុខភាព។
- អប់រំប្រជាជន អំពីថាតើត្រូវទៅមណ្ឌលសុខភាពនៅពេលណា។

- បញ្ជូនអ្នកជំងឺ ដែលមានសញ្ញាគ្រោះថ្នាក់ ឈឺធ្ងន់ធ្ងរ ទៅមណ្ឌលសុខភាពដើម្បីពិនិត្យ និង ទទួលការព្យាបាលជាពិសេសជំងឺទាក់ទងនិងជំងឺឆ្លង។
- កៀងគរនិងរៀបចំប្រជាជននៅក្នុងសហគមន៍ ភូមិ របស់ពួកគេ សំដៅលើកកម្ពស់សុខភាព តាមរយៈការសម្របសម្រួល/រៀបចំកិច្ចប្រជុំ និង យុទ្ធនាការអប់រំសុខភាពនានានៅក្នុងសហគមន៍
- ចុះតាមផ្ទះដើម្បីត្រួតពិនិត្យការរីកចម្រើននៃការអនុវត្តន៍យុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺឆ្លងនៅតាមមូលដ្ឋាន
- ចែកចាយសម្ភារៈ ផ្សព្វផ្សាយអប់រំ ទៅដល់អ្នកភូមិ
- ជួយក្នុងការប្រមូលព័ត៌មានអំពីសុខភាពក្នុងភូមិ។
- កំណត់គ្រួសារដែលត្រូវការ ការគាំទ្រដើម្បីក្លាយជាគ្រួសារសុខភាពល្អ
- រៀបចំការប្រជុំប្រចាំខែនៅមូលដ្ឋាន ជាមួយសមាជិកក្រុមគ្រប់គ្រងភូមិ និង តំណាងមណ្ឌលសុខភាព
- កត់ត្រា និងរក្សាទុកទិន្នន័យសុខភាពសហគមន៍ ស្ថានភាពអនាម័យ បរិស្ថាន
- ធ្វើរបាយការណ៍ប្រចាំត្រីមាសទៅ គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព
- រៀបចំបង្កើតផែនការសកម្មភាពប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន និងសម្របសម្រួលបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## វត្ថុបំណងទី១៖ រៀបរាប់ពីគោលបំណងរួមនិងវត្ថុបំណងនៃកម្មវិធីបណ្តុះបណ្តាល

បំផុសគំនិត និងការពិភាក្សាអំពីគោលបំណង និងវត្ថុបំណង

១.បិទក្រដាសផ្ទាំងធំដែលមានចំណងជើងសកម្មភាពនិងវត្ថុបំណង។ពិនិត្យឡើងវិញជាមួយសិក្ខាកាមដោយអានឮឬស្នើឲ្យក្រុមគ្រប់គ្រងភូមិអានឲ្យឮៗ ។

មុនចាប់ផ្តើមវគ្គចូរសរសេរអំពី "គោលបំណងរួម" និង "វត្ថុបំណង" របស់អ្នក (អ្នកសម្របសម្រួលអំពីកម្មវិធីបណ្តុះបណ្តាលនៅលើក្រដាសផ្ទាំងធំ។

២.បំផុសគំនិតពីគោលបំណងរួមពីសិក្ខាកាម នៅក្នុងការចូលរួមក្នុងវគ្គសិក្សានេះ ហើយថាតើពួកគេចង់សិក្សាអំពីអ្វី។លើកទឹកចិត្តដល់សិក្ខាកាមឲ្យចែករំលែកគំនិតដែលពួកគេមានហើយកុំឲ្យពួកគេមានអារម្មណ៍អៀនខ្មាសនឹងនិយាយ។

៣.សរសេរចម្លើយដាក់លើក្រដាសផ្ទាំងធំ។ សង្ខេបចម្លើយ និងស្នើឲ្យអ្នកស្ម័គ្រចិត្តម្នាក់អានចម្លើយទាំងនោះឲ្យឮដល់ក្រុម ប្រសិនបើអាច (ប្រសិនបើសិក្ខាកាមមិនចង់អានឮ អ្នកសម្របសម្រួលអាចអានឲ្យឮដោយខ្លួនឯង។)

៤.ព្យួរក្រដាសផ្ទាំងធំដែលមានសរសេរអក្សរជាមុន ដាក់ជាប់នឹងចម្លើយរបស់ក្រុម ហើយស្នើ សិក្ខាកាមឲ្យអានឮប្រសិនបើអាចធ្វើទៅបាន។ ប្រៀបធៀបចំណុចដូចគ្នា និងខុសគ្នារវាងគោលបំណងរួមរបស់ សិក្ខាកាម និងរបស់អ្នកសម្របសម្រួល។

៥. ប្រសិនបើអាច ចូររក្សាទុកក្រដាសផ្ទាំងធំនោះនៅកន្លែងណា ដែលអាចមើលឃើញសម្រាប់ឱ្យសិក្ខាកាម អាននៅពេលខាងមុខ ជាការរំលឹកអំពីគោលបំណងរួម និងវត្ថុបំណងនៃការបណ្តុះបណ្តាល។

**សង្ខេបមេរៀនឡើងវិញ៖**

លើកទឹកចិត្តឲ្យម្នាក់ៗរំលឹកឡើងវិញនូវអ្វីៗដែលពួកគេបានចងចាំ អំពីគោលបំណង និងវត្ថុបំណង។

ការវាយតម្លៃ៖ អ្នកសម្របសម្រួល បន្ទាប់ពីឲ្យសិក្ខាកាមប្រាប់ត្រូវផ្តល់ចម្លើយដែលត្រឹមត្រូវឲ្យពួកគេ។

## មេរៀនទី ៣៖ ការណែនាំសិក្ខាកាមឱ្យស្គាល់គ្នា រយៈពេល ២០នាទី

**វត្ថុបំណងនៃការសិក្សា៖**នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច៖

១. ប្រាប់ឈ្មោះគ្នាទៅវិញទៅមក និងសាកសួរគ្នានូវព័ត៌មានផ្សេងៗ
២. ពិភាក្សាអំពីវិន័យជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាល។

**សម្ភារៈជំនួយបង្រៀន៖**

- ប័ណ្ណដែលមានឈ្មោះសត្វផ្សេងៗ (ឬរូបភាពសត្វផ្សេងៗ)
- ក្រដាសផ្ទាំងធំ ហ្វឺតសម្រាប់សរសេរ

**វិធីសាស្ត្របង្រៀន៖**

- ល្បែងសម្រាប់ណែនាំខ្លួន
- ពិភាក្សាក្រុម

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

សេចក្តីផ្តើម (ធ្វើការសន្ទនាបើអាចធ្វើបាន)៖ អ្នកសម្របសម្រួលសំដែងនូវការស្វាគមន៍ ដល់អ្នកអប់រំ សុខភាពសហគមន៍ និងថ្លែងអំណរគុណដល់ពួកគេដែលបានចូលរួមក្នុងវគ្គសិក្សាថ្ងៃនេះ។ ថ្ងៃនេះ ជាថ្ងៃជួបជុំគ្នាដំបូង យើងនឹងចំណាយពេលវេលាខ្លះ ដើម្បីស៊ាំស្គាល់គ្នា និងបានដឹងថា តើវគ្គបណ្តុះបណ្តាលនេះនិយាយអំពីអ្វី។ អ្នករាល់គ្នាត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងវគ្គ/គម្រោងនេះ ពីព្រោះយើងមានជំនឿលើអ្នក ជាអ្នកដែលអាចជួយលើកកំពស់សុខភាពប្រជាជននៅក្នុងភូមិរបស់អ្នកនិងជួយឲ្យភូមិនេះជាភូមិសុខភាពគំរូ។ ឥឡូវនេះ យើងនឹងលេងល្បែងកំសាន្តមួយដើម្បីជួយឱ្យយើងទាំងអស់បានស្គាល់គ្នា។ សកម្មភាពនេះនឹងជួយក្រុមរបស់យើងមានអារម្មណ៍រីករាយក្នុងចិត្ត ដោយធ្វើដូចនេះយើងអាចធ្វើការ និងសិក្សាជាមួយគ្នាបានងាយស្រួលផងដែរ "។

**វត្ថុបំណងទី ១៖ ប្រាប់ឈ្មោះគ្នាទៅវិញទៅមក និងសាកសួរគ្នានូវព័ត៌មានផ្សេងៗ**

**ល្បែងណែនាំខ្លួន**

សិក្ខាកាមចាប់គូជាមួយគ្នា ដោយខ្លួនឯង ដោយជ្រើសរើសយកនរណាម្នាក់ដែលខ្លួនមិនស្គាល់ ឬដោយការចែក ប័

ណ្ណចាប់គូដោយព្រាវៗ (ឧទាហរណ៍ ប័ណ្ណដែលមានរូបសត្វ ឬរូបភាពផ្សេងៗ) ហើយពួកគេត្រូវស្វែងរកដៃគូ ដែលមានរូបសត្វ ឬរូបភាពដូចគ្នា។ ក្នុងករណីប័ណ្ណចាប់គូជាសត្វ, សិក្ខាកាមត្រូវបង្ហាញដៃគូដែលខ្លួនរកឃើញ នូវប័ណ្ណរបស់ខ្លួន និងមិននិយាយប្រាប់អ្នកដទៃ ប៉ុន្តែត្រូវធ្វើជាសំលេងរបស់សត្វដែលមានក្នុងប័ណ្ណរបស់ខ្លួន ដើម្បីស្វែងរកដៃគូ, ឧទាហរណ៍ សំលេង "មេវ,មេវ" សម្រាប់សត្វឆ្មា និងសំលេង "ម៉, ម៉" សម្រាប់សត្វគោ។ សិក្ខាកាមគួរធ្វើកាយវិការដូចសត្វរបស់ខ្លួនផងដែរ, ឧទាហរណ៍ ធ្វើកាយវិការ ជាដំរីបោយប្រមោយ ឬអេះ ត្រៀកជាសញ្ញាសត្វស្វា។ល។ នៅពេលសិក្ខាកាមម្នាក់ៗបានរកឃើញដៃគូរបស់ខ្លួនហើយ ពួកគេគួរចាប់ផ្តើម ធ្វើសម្ភាសគ្នា ដោយប្រើប្រាស់ព័ត៌មានទាំងឡាយដូចខាងក្រោមៈ

- ឈ្មោះអ្វី?
- ទីកន្លែងធ្វើការ តួនាទី?
- ស្ថានភាពគ្រួសារ តើអ្នកមានកូនឬទេ? ប៉ុន្មាននាក់?
- ចំណង់ចំណូលចិត្ត?

អ្នកសម្របសម្រួលគួរចាប់គូជាមួយសិក្ខាកាមណាដែលគ្មានដៃគូ ផងដែរ។

សិក្ខាកាមមានពេល ១០នាទី សម្រាប់លំហាត់នេះ និងណែនាំអំពីដៃគូរបស់ខ្លួនដល់សិក្ខាកាមទាំងមូល។ អ្នកសម្របសម្រួលអាចផ្លាស់ប្តូរសំណួរផ្សេងៗពីនេះ ក៏បាន។

## **ចំណុចបំណងទី ២៖ ពិភាក្សាអំពីវិន័យជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាល**

អ្នកសម្របសម្រួលពន្យល់ថា វិន័យជាមូលដ្ឋាន គឺជាវិធានដែលសិក្ខាកាមត្រូវយល់ព្រមអនុវត្តនៅក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនេះ ហើយមានគោលបំណងធ្វើឱ្យក្រុមអាចដំណើរការទៅបានប្រកបដោយប្រសិទ្ធភាព ។ អ្នកសម្របសម្រួលដឹកនាំក្រុមពិភាក្សា អំពីអ្វីដែលគួរតែជាវិន័យជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាល។ អ្នកសម្រប-សម្រួលគួរ សរសេរនៅលើក្រដាសធំ នូវវិន័យទាំងនេះ ហើយបិទនៅលើជញ្ជាំងសម្រាប់ឱ្យសិក្ខាកាមមើល នៅក្នុងពេលបណ្តុះបណ្តាល។

ឧទាហរណ៍នៃវិន័យជាមូលដ្ឋាន រួមមាន៖

- ការមកទាន់ពេលវេលារបស់សិក្ខាកាម/ការតាមដានពេលវេលារបស់អ្នកសម្របសម្រួល
- ការរក្សាការសម្ងាត់
- ត្រូវបិទទូរស័ព្ទដៃ
- ត្រូវគោរពទស្សនៈរបស់អ្នកដទៃ
- ឱកាសសម្រាប់សិក្ខាកាមទាំងអស់ក្នុងការបង្ហាញទស្សនៈរបស់ខ្លួន
- មិនត្រូវនិយាយបង្អាក់ពេលនរណាម្នាក់កំពុងនិយាយ
- មិនត្រូវញ៉ាំចំណីនៅក្នុងថ្នាក់។

## **សង្ខេបមេរៀនឡើងវិញ៖**

សួរទៅសិក្ខាកាមថាតើ ពួកគេអាចចងចាំឈ្មោះ និងព័ត៌មានផ្សេងៗទៀតរបស់ដៃគូរបស់គេបានឬទេ។

**ការវាយតម្លៃ**

អ្នកសម្របសម្រួល សួរសិក្ខាកាមពីរបីនាក់ ឱ្យប្រាប់ឈ្មោះអ្នកដទៃទៀតក្នុងថ្នាក់។

## មេរៀនទី ៤៖ សារៈសំខាន់នៃក្រុមគ្រប់គ្រងភូមិ រយៈពេល ៤៥ នាទី

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹងអាច៖

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច៖

១. ពន្យល់ពីសារៈសំខាន់នៃក្រុមគ្រប់គ្រងភូមិ ចំពោះសហគមន៍របស់គាត់។

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាស់ផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សាថ្ងៃនេះ
- ក្ដារខៀន ហ្វឺត ក្រដាស់ផ្ទាំងធំ កន្ត្រៃ និងបង់ស្អិត

**វិធីសាស្រ្តបង្រៀន៖**

- សំណួរ និងចម្លើយ
- ពិភាក្សាក្រុម

**ជំហានសកម្មភាព៖**

**បង្ហាញនូវវត្ថុបំណងរួម**

**សេចក្ដីផ្ដើម**

សេចក្ដីផ្ដើមនៃមេរៀនសម្រាប់ អ្នកសម្របសម្រួល៖ អំឡុងពេលសិក្សានេះអ្នកសម្របសម្រួលនឹងដឹកនាំសិក្ខាកាមឲ្យឆ្លើយសំណួរ ដែលនឹងធ្វើឲ្យគេ គិតអំពីបទពិសោធន៍របស់សមាជិកសហគមន៍ ដែលពាក់ព័ន្ធនឹងការស្វែងរកការថែទាំសុខភាពរបស់គាត់ឬកូនរបស់គាត់។ នៅក្នុងតួនាទីនេះ ក្រុមគ្រប់គ្រងភូមិ គួរដាក់ខ្លួនឲ្យចូលក្នុងតួនាទីនៃសមាជិកសហគមន៍។គោលបំណងនៃមេរៀននេះនឹងចង្អុលបង្ហាញនូវសារៈសំខាន់របស់ក្រុមគ្រប់គ្រងភូមិក្នុងសហគមន៍និងធ្វើឲ្យ សិក្ខាកាមទាំងអស់មានមោទនភាពក្នុងការផ្ដល់នូវសេវាកម្មមួយដ៏មានតម្លៃ។

ការណែនាំទៅកាន់ក្រុម (កិច្ចសន្ទនាដែលអាចធ្វើបាន) ‶ ឥឡូវយើងមានគំនិតមួយកាន់តែប្រសើរសម្រាប់ អ្វីជាគោលបំណងរបស់អ្នក ដែលជាក្រុមទ្រទ្រង់សុខភាពភូមិ និងអ្វីដែលអ្នកនឹងធ្វើ ចូរសួរខ្លួនឯងថា ហេតុអ្វីបានជាការងាររបស់អ្នកសំខាន់ម្ល៉េះ។‶

**វត្ថុបំណងទី ១៖ ពន្យល់នូវសារៈសំខាន់នៃក្រុមគ្រប់គ្រងភូមិ ចំពោះភូមិ របស់គាត់**

➢ សំណួរ និងចម្លើយ

អ្នកសម្របសម្រួលគួរតែអានសំណួរនិមួយៗខាងក្រោមដោយប្រុងប្រយ័ត្ន មុនពេលបង្រៀនបានចាប់ផ្តើម។ ដូច្នេះពួកគេយល់ពីរបៀបសម្របសម្រួលឬនាំឲ្យមានការពិភាក្សាដ៏ល្អមួយ។ ក្នុងអំឡុងពេលពិភាក្សា អ្នកសម្របសម្រួលម្នាក់អាចកត់ចំណាំនៅលើក្រដាសផ្ទាំងធំសិន បើគេចង់នោះមានការសំគាល់ជាច្រើនដែលត្រូវសង្ខេបនៅខាងចុងបញ្ចប់នៃម៉ោងនោះ។

១. ស្នើឲ្យសិក្ខាកាមអង្គុយជារង្វង់។បិតតាំងក្រដាសផ្ទាំងធំដែលមានចំណងជើងមេរៀននិងវត្ថុបំណង។សុំឲ្យសិក្ខាកាមអានខ្លាំងៗឬស្នើឲ្យអ្នកស្ម័គ្រចិត្តអានខ្លាំងៗ។

២. ពន្យល់ទៅកាន់ក្រុមដែលពួកគេ និងស្វែងរកចំណងជើងតាមរយៈសំណួរនិងចម្លើយនិងថាពួកគេ ត្រូវបានលើកទឹកចិត្ត ដើម្បីចែកព័ត៌មានច្រើន ដូចដែលពួកគេពេញចិត្ត។ សំណួរខាងក្រោម អាចប្រើជាគំនិតដឹកនាំសម្រាប់ការពិភាក្សាឬផ្លាស់ប្តូរនូវសំណួរដោយយោងទៅលើតម្រូវការរបស់ពួកគេ។

៣. សំណួរដែលអាចដាក់បាន៖

១. ពេលចុងក្រោយនេះអ្នកណាម្នាក់ក្នុងចំណោមសមាជិកគ្រួសារ បានឈឺ តើអ្នកបានស្វែងរកដំបូន្មានណាមួយ ពីនរណាម្នាក់ដែលនៅក្បែរឬនៅក្នុងសហគមន៍នោះឬទេដើម្បីធ្វើការថែទាំ? ហេតុអ្វីបាន? ហេតុអ្វីមិនបាន?
២.តើនរណា ដែលអ្នកបានសួរនូវយោបល់នេះ? ហេតុអ្វីបានជាអ្នកជ្រើសរើសមនុស្សនេះ?
៣. តើដំបូន្មានរបស់ពួកគេមានន័យគ្រប់គ្រាន់សម្រាប់អ្នកដែរឬទេ? តើពួកគេពិភាក្សាជាមួយអ្នកនូវអ្វីដែលជាបញ្ហារបស់កូនអ្នកដែរ ឬទេ? តើអ្នកមានអារម្មណ៍កក់ក្តៅក្នុងការសាកសួរសំណួរអំពីរឿងអ្វីដែលអ្នកមិនបានយល់ដែរ ឬទេ?
៤. តើអ្នកមានធ្វើតាមដំបូន្មានរបស់គាត់ដែរ ឬទេ? ហេតុអ្វីធ្វើតាម? ហេតុអ្វីមិនធ្វើតាម?
៥. តើដំបូន្មានរបស់ពួកគេ ជួយ សមាជិកគ្រួសាររបស់អ្នក ឱ្យកាន់តែមានសុខភាពប្រសើរដែរ ឬទេ?
៦. តើអ្នកបង់លុយថ្លៃសេវាកម្មនេះដែរ ឬទេ? តើអ្នកចំណាយពេលច្រើនដែរ ឬទេ ក្នុងការស្វែងរកជំនួយពីគាត់?
៧. តើដំបូន្មានរបស់ពួកគាត់ រួមមានការទៅស្វែងរកជំនួយពីមណ្ឌលសុខភាពដែរឬទេ? តើអ្នកមាន ធ្វើតាមដំបូន្មាននោះទេ? ហេតុអ្វីធ្វើតាម? ហេតុអ្វីមិនធ្វើតាម?
៨. តើមានន័យដូចម្តេចចំពោះការការពារជំងឺឆ្លងនានា?
៩. តើអ្នកគិតថា ការការពារខ្លួនកុំឲ្យឈឺប្រសើរជាងឬក៏ការព្យាបាលបន្ទាប់ពីពួកគេមានជំងឺប្រសើរជា
១០. តើមួយណា ការការពារជំងឺ ឬ ក៏ការព្យាបាលជំងឺ ដែលអ្នកគិថាជួយសន្សំពេលវេលាយើង និងលុយកាក់បានច្រើន?
១១.តើយើងត្រូវការអ្វីខ្លះ ដើម្បីយើងជួយ សមាជិកក្នុងគ្រួសាររបស់យើងឱ្យមានសុខភាពល្អ និង ជួយពួកគេឱ្យចៀសផុតពីជំងឺឆ្លងនានា?

## សង្ខេបមេរៀនឡើងវិញ៖

តាមរយៈការពិភាក្សាក្រុម សង្ឃឹមថា ចំណុចសំខាន់ៗ មួយចំនួន នឹងកើតឡើង ដូចខាងក្រោម៖

**ការវាយតម្លៃ**

អ្នកសម្របសម្រួល សួរសិក្ខាកាមពីរបីនាក់ ឱ្យប្រាប់ឈ្មោះអ្នកដទៃទៀតក្នុងថ្នាក់។

- ជារឿយៗ សិក្ខាកាមចង់បាននរណាម្នាក់ពិភាក្សាអំពីបញ្ហាសុខភាព និងការ ថែទាំសមាជិក ក្រុមគ្រួសាររបស់ ខ្លួន ប៉ុន្តែពួក គាត់មិនមានអ្នកណាមួយ ដែលគាត់ទុកចិត្ត មានអារម្មណ៍ងាយស្រួលក្នុងការពិភាក្សាជាមួយ ឬក៏អ្នក ដែលរស់នៅជិតខាង។
- កន្លងមក សិក្ខាកាមមួយចំនួនមិនអាចបានដោះស្រាយជាវិជ្ជមាន ជាមួយអ្នកផ្តល់សេវាព្យាបាលនោះទេ ដូចជា (វេជ្ជបណ្ឌិត គ្រូបុរាណ អ្នកលក់ថ្នាំ។ល។)។ ជួនកាលអ្នកផ្តល់សេវាព្យាបាលទាំងនោះ ធ្វើការ បំភិតបំភ័យ មិនអនុញ្ញាតឱ្យគេសួរសំណួរ ផ្តល់នូវដំបូន្មានភ័ន្តច្រឡំ ឬមិនច្បាស់លាស់ យកលុយកាក់ ច្រើន ឬរស់នៅឆ្ងាយពេក។ ជួនកាលដំបូន្មាន ឬ ការព្យាបាលរបស់គេមិនមានប្រសិទ្ធភាពឡើយ។
- អ្នកផ្តល់សេវាព្យាបាលទាំងនោះ មួយចំនួនអាចជួយសម្រាប់ការព្យាបាលជំងឺតែប៉ុណ្ណោះ ក្រោយពីកុមារមានជំងឺ) ប៉ុន្តែពួកគេមិនអាចយល់ដឹង ពីមធ្យោបាយការពារជំងឺនោះឡើយ (រក្សាកុមារឱ្យសុខភាព ល្អ)។
- ការការពារជំងឺប្រសើរ ជាងការព្យាបាលជំងឺ។
- ក្រុមគ្រប់គ្រងសុខភាពភូមិ អាចជួយប្រជាជនការពារពីជំងឺ ដោយផ្តល់នូវព័ត៌មាន និងដំបូន្មានទៅដើម្បីអនុវត្តការពារមុនពេលមានជំងឺ.
- ថែទាំសមាជិក ក្រុមគ្រួសារ ការការពារជំងឺអាចជួយសន្សំពេលវេលា និងលុយកាក់ រីឯការព្យាបាលជំងឺខាតទាំងពេលវេលា និង លុយកាក់។ ***ក្រុមគ្រប់គ្រងសុខភាពភូមិអាចជួយប្រជាជនសន្សំទាំងពេលវេលា និង លុយកាក់*** ។
- ក្រុមគ្រប់គ្រងសុខភាពភូមិមានសមាជិកមកពីភូមិ ដែលពួកគាត់កំពុងធ្វើការ។ ពួកគាត់ងាយស្រួលទៅរករាក់ទាក់ និង យល់ដឹងច្បាស់ពីស្ថានភាពប្រជាជននៅក្នុងភូមិ។
- ក្រុមគ្រប់គ្រងសុខភាពភូមិមានសមាជិករស់នៅក្នុងសហគមន៍ ដូច្នេះហើយមានការងាយស្រួលទៅរកគាត់ និងពិភាក្សា ជាមួយគាត់។
- ក្រុមគ្រប់គ្រងសុខភាពភូមិមានពេលវេលាគ្រប់គ្រាន់ដើម្បីពន្យល់ ផ្តល់ព័ត៌មាន និងពិភាក្សាអំពីបញ្ហា នានាជាមួយឪពុកម្តាយ។ ពួកគាត់មានលក្ខណៈទូលំទូលាយ ហើយអាចឱ្យប្រជាជនសួរនូវសំណួរគ្រប់ បែបយ៉ាងបាន។ ពួកគាត់មិនបំភិតបំភ័យដូចវេជ្ជបណ្ឌិតខ្លះ ឬអ្នកដទៃទៀតដែលអាចនឹងប្រព្រឹត្ត នោះ ឡើយ។
- ក្រុមគ្រប់គ្រងសុខភាពភូមិមាន (ឬនឹងមាន) ជំនាញ ដើម្បីជួយប្រជាជនឱ្យមានសុខភាពកាន់តែល្អ
- ក្រុមគ្រប់គ្រងសុខភាពភូមិមានសារៈសំខាន់ណាស់ ចំពោះសហគមន៍ពួកគាត់ ពីព្រោះពួកគាត់ផ្តល់នូវសេវាដ៏មានសារៈសំខាន់ ដែលអ្នកដទៃទៀតពុំអាចផ្តល់ឱ្យបាន។
- ក្រុមគ្រប់គ្រងសុខភាពភូមិអាចមានអារម្មណ៍មោទនភាពចំពោះខ្លួន.

**ការវាយតម្លៃ**

អ្នកសម្របសម្រួលសួរទៅសិក្ខាកាម ដើម្បីឱ្យគាត់បង្ហាញនូវយោបល់ផ្ទាល់របស់គាត់ គេថាហេតុអ្វី បានជាពួកគាត់គិតថា ក្រុមគ្រប់គ្រងសុខភាពភូមិមានសារៈសំខាន់។

## មេរៀនទី ៥៖ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមគ្រប់គ្រងសុខភាពភូមិ

**រយៈពេល ៤៥នាទី**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងអាច៖

**១–**ពិពណ៌នាពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមគ្រប់គ្រងសុខភាពភូមិ
**២–**រៀបរាប់ពីអត្ថប្រយោជន៍របស់ក្រុមគ្រប់គ្រងសុខភាពភូមិ។

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សា។
- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពី "អ្វីដែលក្រុមគ្រប់គ្រងសុខភាពភូមិអនុវត្ត" "អ្វីដែលក្រុមគ្រប់គ្រងសុខភាពភូមិ ប្រហែលមិនធ្វើ" "អត្ថប្រយោជន៍ ដែល ក្រុមគ្រប់គ្រងសុខភាពភូមិ នឹងទទួលបាន តាមរយៈការចូលរួមក្នុងគម្រោង" និង "អត្ថប្រយោជន៍ ដែលក្រុមគ្រប់គ្រងសុខភាពភូមិ នឹងមិនទទួលបានតាមរយៈការចូលរួមក្នុងគម្រោង "។
- ក្តារខៀន ហ្វឺត ក្រដាស់ផ្ទាំងធំ កន្រ្តៃ និងបង់ស្អិត។
- ប្រអប់ធំល្មម ដើម្បីដាក់បំណែកទាំងឡាយនៃក្រដាសពណ៌។

**វិធីសាស្រ្តបង្រៀន៖**

- ល្បែង "ជ្រើសរើសក្រដាសផ្ទាំងធំដែលត្រឹមត្រូវ"
- ពិភាក្សាក្រុម

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម៖**

**សេចក្តីផ្តើម**

" ឆ្លងកាត់វគ្គមុន ឥឡូវនេះអ្នកប្រហែលជាមានគំនិតកាន់តែប្រសើរអំពីមូលហេតុ អ្វីបានជាយើងមកជួបជុំគ្នាហើយតើអ្វីខ្លះដែលយើងនឹងរៀនជាមួយគ្នា។ នៅក្នុងវគ្គនេះយើងជជែកបន្តិច អំពី តើអ្នកនឹងធ្វើអ្វីខ្លះ នៅក្នុងតួនាទីជា

ក្រុមគ្រប់គ្រងសុខភាពភូមិ.នៅពេលដែលអ្នកត្រូវបានជ្រើសជា ក្រុមគ្រប់គ្រងសុខភាពភូមិយើងនឹងជម្រាបអ្នកអំពីការងារដ៏មានសារៈសំខាន់ ទាំងនេះនឹងមានអ្វីខ្លះ។ ឥឡូវនេះយើងនឹងជជែកគ្នាថែមទៀតអំពីរឿងនេះដើម្បីឲ្យអ្នកទាំងអស់គ្នាបានយល់កាន់តែច្បាស់នូវអ្វីដែលជាគោលបំណងនៃការបង្កើតក្រុមគ្រប់គ្រងសុខភាពភូមិនិងអ្វីដែលក្រុមគ្រប់គ្រងសុខភាពភូមិត្រូវអនុវត្តសកម្មភាព ហើយមានជំនាញនិងសមត្ថភាព អ្វីខ្លះដែលអ្នកនឹងទទួលបានក្នុងនាមជាក្រុមគ្រប់គ្រងសុខភាពភូមិ ”។

## វត្ថុបំណង ១៖ ពិពណ៌នាពី តួនាទី និងការទទួលខុសត្រូវរបស់ក្រុមគ្រប់គ្រងសុខភាពភូមិ

- ល្បែង " ជ្រើសរើសផ្ទាំងក្រដាសធំៗដែលត្រឹមត្រូវ "

១. បិតតាំងក្រដាសផ្ទាំងធំដែលមានចំណងជើងមេរៀននិងវត្ថុបំណង។ សុំឲ្យសិក្ខាកាមទាំងឡាយ អានខ្លាំងៗ ឬស្នើឲ្យអ្នកស្ម័គ្រចិត្តអានខ្លាំងៗ

២. សួរសិក្ខាកាម " តើមានការងារ សំខាន់អ្វីខ្លះ ដែល ក្រុមគ្រប់គ្រងសុខភាពភូមិយល់ថា អាចធ្វើបាន? " បន្ទាប់ពីសិក្ខាកាមផ្តល់នូវគំនិត សូមពន្យល់ថាការងារដ៏សំខាន់បំផុត ដែល ក្រុមគ្រប់គ្រងសុខភាពភូមិ អាចធ្វើបាន គឺជួយអ្នកដទៃឱ្យចាប់ផ្តើមអនុវត្តនូវឥរិយាបថដែលនាំឱ្យមានសុខភាពល្អ នឹងលើកកំពស់សុខភាពប្រជាជនក្នុងសហគមន៍ និងបញ្ឈប់នូវឥរិយាបថណា ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព នឹងបង្កឱ្យគ្រោះថ្នាក់ដល់អាយុជីវិ។ សូមពន្យល់ថាក្រុមគ្រប់គ្រងសុខភាពភូមិអាចបំពេញនូវគោលបំណងដ៏ សំខាន់នេះបាន ដោយចូលរួមនៅក្នុងសកម្មភាពមួយចំនួនដែលក្រុមនឹងលើកយកមកពិភាក្សាឥឡូវ នេះ។

១. មុនចាប់ផ្តើមមេរៀននេះត្រូវរៀបចំក្រដាសផ្ទាំងធំពីរ មួយផ្ទាំងសរសេរ " ការងារដែលក្រុមគ្រប់គ្រងសុខភាពភូមិត្រូវធ្វើ " និងមួយផ្ទាំងទៀតសរសេរ " ការងារដែលក្រុមគ្រប់គ្រងសុខភាពភូមិទំនងជាមិនត្រូវធ្វើ ”។

២. សូមកាត់ក្រដាស សជាបន្ទះៗធំល្មម ដែលអាចសរសេរបាន (ត្រូវសរសេរឱ្យធំល្មមដែលមើលឃើញ ពីចម្ងាយប្រហែល ១ ឬ ២ម៉ែត្របាន)។ នៅលើក្រដាសនីមួយៗ ចូរសរសេរអំពីតួនាទី និងការទទួលខុសត្រូវតែមួយ ប៉ុណ្ណោះ ដូចដែលមានក្នុងបញ្ជីខាងក្រោម (អាចដាក់បន្ថែម/លុបចេញពីបញ្ជី ឱ្យបានសមរម្យ)៖

1. អប់រំប្រជាជន នៅក្នុងសហគមន៍ របស់ពួកគេ អំពីការបង្ការជំងឺឆ្លងជាមូលដ្ឋាននិងការលើកកម្ពស់សុខភាព។
2. ចលនាក្រុមគ្រួសារ និងសហគមន៍ ដោយធ្វើយុទ្ធនាការអនាម័យ យុទ្ធនាការសំអាតបរិស្ថានជុំវិញលំនៅឋាន សំអាត ពាងទឹក ដើម្បីកំចាត់មូស និងដង្កូវទឹក ។ល។
3. អប់រំប្រជាជនអំពីថាតើត្រូវទៅមណ្ឌលសុខភាពនៅពេលណា។
4. សម្របសម្រួល/បញ្ជូនអ្នកជំងឺ ដែលមានសញ្ញាគ្រោះថ្នាក់ ឈឺធ្ងន់ធ្ងរ ទៅមណ្ឌលសុខភាព/មន្ទីរពេទ្យ ដើម្បីពិនិត្យ និង ទទួលការព្យាបាលឲ្យបានទាន់ពេលវេលា ជាពិសេសជំងឺទាក់ទងនិងជំងឺឆ្លង។
5. កៀងគរនិងរៀបចំប្រជាជននៅក្នុងសហគមន៍ ភូមិ របស់ពួកគេ សំដៅលើកកម្ពស់សុខភាព តាមរយៈការ

សម្របសម្រួល/រៀបចំកិច្ចប្រជុំ និង យុទ្ធនាការអប់រំសុខភាពនានានៅក្នុងសហគមន៍

6. ចែករំលែកសារនិងសម្ភារៈ ផ្សព្វផ្សាយអប់រំ សុខភាពជាមួយសហគម និងរៀបចំផ្សព្វផ្សាយសារសុខភាព ដែលទទួលបាន
7. កំណត់គ្រួសារដែលត្រូវការ ការគាំទ្រដើម្បីក្លាយជាគ្រួសារសុខភាពល្អ
8. រៀបចំការប្រជុំប្រចាំខែនៅមូលដ្ឋាន ជាមួយសមាជិកក្រុមគ្រប់គ្រងភូមិ និង តំណាងមណ្ឌលសុខភាព
9. កត់ត្រា និងរក្សាទុកទិន្នន័យសុខភាពសហគមន៍ ស្ថានភាពអនាម័យ បរិស្ថានក្នុងភូមិ
10. ធ្វើរបាយការណ៍ប្រចាំត្រីមាសទៅ គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាពអំពី
    - ចំនួន គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ
    - ស្ថានភាពនៃការអនុវត្តន៍ការគ្រប់គ្រងកាកសំណល់បានត្រឹមត្រូវ
    - ចំនួន កុមារ ដែលទទួលបានការចាក់វ៉ាក់សាំងគ្រប់
    - ចំនួន ម្តាយ ដែលទទួលបានការចាក់វ៉ាក់សាំងគ្រប់
    - ចំនួន ស្ត្រីសម្រាលកូនថ្មី ដោយឆ្មបជំនាញ ដែលបានទទួលការបណ្តុះបណ្តាល
    - ចំនួន ស្ត្រីសម្រាលកូនថ្មី ដោយ ឆ្មបបុរាណ
    - ចំនួនស្ត្រីមានផ្ទៃពោះទទួលបានការពិគ្រោះយោបល់ពីការថែទាំផ្ទៃពោះ មុនពេលសម្រាល ពី ២ ដង ឬច្រើនជាង២ដង ពីបុគ្គលិកជំនាញសុខាភិបាល
    - ចំនួនស្ត្រីក្នុងវ័យបន្តពូជ (អាយុ ១៥ - ៤៩ឆ្នាំ) ទទួលបានថ្នាំ មេបង់ដាសហ្ស៊ុល
    - ចំនួនកុមារា កុមារី មុនចូលសាលា អាយុពី ១-៥ ឆ្នាំ បានទទួលថ្នាំ មេបង់ដាសហ្ស៊ុល
    - ចំនួនកុមារា កុមារី ក្នុងសាលា អាយុពី ៦-១៤ ឆ្នាំ បានទទួលថ្នាំ មេបង់ដាសហ្ស៊ុល
11. ចំនួនផ្ទះដែលបានទទួលថ្នាំបាណកឃាដ សំលាប់ដង្កូវទឹក មូសខ្លាភ្នាក់ងារបង្ករជំងឺគ្រុនឈាម
12. ចំនួនពាងឬអាងដែលបានទទួលថ្នាំបាណកឃាដ សំលាប់ដង្កូវទឹក មូសខ្លាភ្នាក់ងារបង្ករជំងឺគ្រុនឈាមរៀបចំបង្កើតផែនការសកម្មភាពប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន និងសម្របសម្រួលបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

៣– បន្ទាប់ពីក្រដាសនីមួយៗត្រូវបានសរសេរសាររួចហើយ ត្រូវបត់វាផ្សេងៗពីគ្នា និងទុកដោយឡែកៗ ពីគ្នា។ ទាំងនេះ គឺ " ការងារដែលក្រុមភូមិត្រូវធ្វើ " ។

៤– អនុវត្តជំហានទី ៤ម្តងទៀត ដោយកាត់ក្រដាស សបន្ថែមទៀត ប៉ុន្តែលើកនេះ សូមសរសេរសារ មួយក្នុងចំណោមសារ ដែលមានដូចខាងក្រោមនៅលើក្រដាសនីមួយៗ។ បន្ថែម ឬលុបចេញពីបញ្ជីនេះ ទៅតាមការពេញចិត្តរបស់អ្នក។ សារនៅលើបញ្ជីនេះមានលក្ខណៈមិនត្រឹមត្រូវ ឬគួរឱ្យចង់សើច ដូច្នេះ សកម្មភាពនេះ នឹង នាំឱ្យសប្បាយរីករាយសម្រាប់ក្រុមទាំងមូល។ ឧទាហរណ៍ដូចជា៖

- ភ្លេចចូលរួមការបណ្តុះបណ្តាលប្រចាំខែ និងកិច្ចប្រជុំសំខាន់ៗ ផ្សេងទៀតនៅមណ្ឌលសុខភាព
- ព្យាយាមផ្តល់អង់ទីប៊ីយ៉ូទិក ដល់ប្រជាជននៅក្នុងភូមិ ដើម្បីព្យាបាលជំងឺរបស់ពួកគាត់
- ចម្អិនអាហារសម្រាប់អ្នកភូមិទាំងមូលក្នុង ១សប្តាហ៍ម្តង

- សុំឱ្យប្រជាជនឱ្យលុយខ្ញុំ ដូច្នេះខ្ញុំនឹងចែករំលែកជាមួយពួកគាត់នូវអ្វីដែលខ្ញុំបានរៀនសូត្រ
- ផ្តល់ដំបូន្មានសុខភាព តែចំពោះអ្នកជិតខាងមួយចំនួនតែប៉ុណ្ណោះ (មិនទាំងអស់ទេ)
- ប្រាប់តែមិត្តភ័ក្តិ ឬ ក្រុមគ្រួសារនៅពេលដែលបុគ្គលិកមណ្ឌលសុខភាពចុះធ្វើសកម្មភាពតាមមូលដ្ឋាន

**៥–** បត់ក្រដាសទាំងអស់ និងបន្ទាប់មកដាក់ក្រដាសទាំងអស់ ពីជំហានទី ៤-៦ ចូលគ្នានៅក្នុងប្រអប់មួយ និង ច្របល់ចូលគ្នា។

**៦–** សូមឱ្យសិក្ខាកាមអង្គុយជារង្វង់។ ព្យួរក្រដាសធំពីរសន្លឹកនៅខាងមុខ និងពន្យល់ថានៅពេលដល់វេនរបស់ខ្លួន អ្នកត្រូវលូកយកក្រដាសមួយសន្លឹកពីក្នុងប្រអប់។ អ្នកត្រូវអានឱ្យក្រុមស្តាប់ ឱ្យឮខ្លាំងៗ និងបន្ទាប់មកត្រូវមានជំនួយពីក្រុម ដើម្បីសម្រេចថា តើក្រដាសនោះរៀបរាប់ការងារដែលក្រុម ទ្រទ្រង់សុខភាពភូមិ " ត្រូវធ្វើ " ឬ " ប្រហែលជាមិនត្រូវធ្វើ " ។ នៅពេលដែលពួកគាត់បានសម្រេចចិត្ត ហើយអ្នកនោះត្រូវបិតក្រដាសនោះ លើផ្ទាំងក្រដាសដែលត្រូវគ្នា ហើយត្រលប់ទៅកន្លែងអង្គុយវិញ។

**៧–** នៅពេលចាប់រើសអស់ពីប្រអប់ហើយ អ្នកសម្របសម្រួល ឬ អ្នកស្ម័គ្រចិត្តម្នាក់អានក្រដាសទាំងអស់នោះ ដែលភ្ជាប់ទៅនឹងបញ្ជីដែល " ត្រូវធ្វើ " ។ សួរសិក្ខាកាម ថាតើពួកគាត់យល់ស្របតាមអ្វី ដែលមាននៅលើបញ្ជីនេះឬទេ ហើយពិនិត្យមើលបើមានអ្វីត្រូវផ្លាស់ប្តូរ។ បន្ទាប់មកអនុវត្តដូចគ្នាដដែលចំពោះបញ្ជីដែល " មិនត្រូវធ្វើ " ហើយពិនិត្យមើលក្រែងមានអ្វីត្រូវផ្លាស់ប្តូរ។

## ចំណុចបំណងទី ២៖ រៀបរាប់ពីផលប្រយោជន៍របស់ក្រុមគ្រប់គ្រងភូមិ

### ➢ ពិភាក្សាជាក្រុម

ពន្យល់ក្រុមថាឥឡូវនេះ ពួកគាត់នឹងធ្វើសកម្មភាព ដដែលឡើងវិញ ដូចនៅក្នុងសកម្មភាពទី ១ដែរ ប៉ុន្តែប្រធានបទលើកនឹងផ្តោតអំពី " គុណប្រយោជន៍ ដែល ក្រុមគ្រប់គ្រងភូមិនឹងទទួលបានតាមរយៈការចូលរួម ក្នុងគម្រោងនេះ " ។

**១–** មុននឹងចាប់ផ្តើមមេរៀននេះ ចូររៀបចំក្រដាសផ្ទាំងធំពីរ មួយសរសេរអំពី " គុណប្រយោជន៍ ដែលក្រុមគ្រប់គ្រងភូមិនឹងទទួលបានតាមរយៈការចូលរួមក្នុងគម្រោងនេះ " ។ និងមួយទៀតសរសេរអំពី " គុណប្រយោជន៍ដែលក្រុមគ្រប់គ្រងភូមិប្រហែលជានឹងមិនអាចបានទទួល តាមរយៈការចូលរួមក្នុងគម្រោងនេះ " ។

**២–** កាត់ក្រដាស សជាសន្លឹកធំល្មមនឹងសរសេរដូចនៅក្នុងសកម្មភាពទី ១។ នៅលើក្រដាសនីមួយៗ ចូរសរសេរអំពីគុណប្រយោជន៍តែមួយប៉ុណ្ណោះ ដូចដែលមាននៅក្នុងបញ្ជីខាងក្រោម (បន្ថែម/លុបចេញពីបញ្ជី ទៅតាមសមស្រប)។

- មានការយល់ដឹងកាន់តែប្រសើរ អំពីបញ្ហាសុខភាព
- ស្គាល់ការផ្តល់សេវារបស់មណ្ឌលសុខភាព កាន់តែច្បាស់ជាងមុន
- មានជំនាញក្នុងការអប់រំកាន់តែប្រសើរ
- មានជំនាញទំនាក់ទំនងកាន់តែល្អ
- មានការយល់ដឹងអំពីសហគមន៍របស់ខ្លួន កាន់តែប្រសើរឡើងថែមទៀត
- មានជំនាញ ដើម្បីអនុវត្តគម្រោងការងារជាក់លាក់ (ទម្រង់នានា របាយការណ៍ ផែនការការងារ ។ល។)
- ភាពទុកចិត្តលើខ្លួនឯង កើនឡើង
- ឱ្យតម្លៃលើខ្លួនឯងខ្ពស់

- ការពេញចិត្តចំពោះការងារខ្លួនឯង កើនឡើង
- ការគោរពពីសហគមន៍ កើនឡើង
- ទទួលការការព្យាបាលដោយឥតគិតថ្លៃ សម្រាប់ខ្លួនឯង និងគ្រួសារ
- សមត្ថភាពរស់នៅប្រកបដោយសុខភាពល្អកើនឡើង និងការថែទាំសុខភាពគ្រួសារកាន់ប្រសើរឡើង

៣– បន្ទាប់ពីក្រដាសនីមួយត្រូវសរសេរសាររួច ត្រូវបត់ផ្សេងៗគ្នា និងដាក់ដោយឡែកពីគ្នា។ ទាំងនេះគឺជា " គុណប្រយោជន៍ ដែលក្រុមគ្រប់គ្រងភូមិ នឹងទទួលបាន "។

៤– អនុវត្តជំហានទី ២ ឡើងវិញដោយកាត់ក្រដាស សបន្ថែម ប៉ុន្តែលើកនេះ ចូរសរសេរលើក្រដាសនីមួយៗនូវចំណុចមួយនីមួយៗ ដូចខាងក្រោមអំពី " ផលប្រយោជន៍ ដែលក្រុមគ្រប់គ្រងភូមិប្រហែលជាមិនអាចទទួលបាន "។ បន្ថែម ឬ លប់ចេញពីបញ្ជីនេះ ទៅតាមសមស្រប។ សារនៅលើបញ្ជីនេះ មានលក្ខណៈមិនត្រឹមត្រូវ ឬ គួរឱ្យ ចង់សើច ដូច្នេះសកម្មភាពនេះ នឹងនាំឱ្យសប្បាយរីករាយសម្រាប់ក្រុមទាំងមូល។ ឧទាហរណ៍ដូចជា:

- ច្រៀងកាន់តែពិរោះ
- រាំរបាំប្រពៃណីខ្មែរកាន់តែល្អប្រសើរ
- រត់កាន់តែលឿន
- អាចនិយាយភាសាអង់គ្លេសបាន
- ។ល។

៥– បត់ក្រដាសទាំងអស់ ហើយដាក់ក្រដាសទាំងអស់ ពីជំហានទី ២-៤ ចូលគ្នាក្នុងប្រអប់មួយ និងច្របល់ចូលគ្នា

៦– សូមឱ្យសិក្ខាកាមអង្គុយជារង្វង់។ ព្យួរក្រដាសផ្ទាំងធំ ពីរសន្លឹកនៅខាងមុខ និងធ្វើដូចលើកមុនអញ្ជើង ដោយម្នាក់ៗ ត្រូវលូកយកក្រដាសមួយសន្លឹកពីក្នុងប្រអប់ ហើយអានឱ្យក្រុមស្តាប់ឱ្យឮខ្លាំងៗ និងបន្ទាប់មកត្រូវមានជំនួយពីក្រុម ដើម្បីសំរេចថា តើក្រដាសនោះរៀបរាប់ផលប្រយោជន៍ ដែលក្រុមគ្រប់គ្រងភូមិ" នឹង ទទួលបាន " ឬ " ប្រហែលជានឹងមិនទទួលបាន " ដោយត្រូវបិទក្រដាសនោះ នៅលើផ្ទាំងក្រដាសដែលត្រូវគ្នា និង ត្រឡប់ទៅកន្លែងអង្គុយវិញ។

៧– នៅពេលចាប់រើសអស់ពីប្រអប់ អ្នកសម្របសម្រួល ឬអ្នកស្ម័គ្រចិត្តម្នាក់អានក្រដាសទាំងអស់នោះដែលភ្ជាប់ទៅនឹងបញ្ជី " ត្រូវធ្វើ "។ សួរសិក្ខាកាមថា តើពួកគាត់យល់ស្របតាមអ្វី ដែលមាននៅលើបញ្ជីនេះ ឬទេ ហើយពិនិត្យមើលបើមានអ្វីត្រូវផ្លាស់ប្តូរ។

## សង្ខេបមេរៀនឡើងវិញ៖

តាមរយៈសកម្មភាពនៃវគ្គបំណងទី ១ ខាងលើក្រុមសិក្ខាកាម គួរតែយល់ច្បាស់អំពីអ្វី ដែលជាគោលបំណងនៃអ្នកអប់រំសុខភាពសហគមន៍។ សួរទៅក្រុមម្តងទៀត " ផ្អែកលើអ្វីៗទាំងអស់ ដែលយើងសម្រេចចិត្តអនុវត្ត តើអ្វីដែលជាគោលបំណងនៃ "ក្រុមគ្រប់គ្រងភូមិ? " ចម្លើយរបស់ពួកគាត់អាចមានដូចជា " ដើម្បីលើកកំពស់ សុខភាពសហគមន៍ តាមរយៈសកម្មភាពអប់រំសុខភាព ការគាំទ្រការរស់នៅប្រកបដោយសុខភាពល្អប្រសើរ និង ជម្រើសនៅក្នុងសហគមន៍ និងភ្ជាប់ទំនាក់ទំនងរវាងប្រជាជនក្នុងសហគមន៍ និងមណ្ឌលសុខភាព "។ លើកទឹកចិត្ត ឱ្យមានការពិភាក្សាខ្លីមួយ ចំពោះប្រធានបទនេះ ប្រសិនបើសិក្ខាកាមហាក់ដូចជាច្រឡំ ឬ យល់មិនច្បាស់អំពីអ្វីដែល ជា គោល

បំណងនៃក្រុមគ្រប់គ្រងភូមិ.

នៅពេលសកម្មភាពនៃវត្ថុបណងទី ២ ចប់ សួរទៅក្រុមសិក្ខាកាម ប្រសិនបើពួកគាត់មានបំណងធ្វើសកម្មភាព ត្រូវបានជំរុញលើកទឹកចិត្ត និង/ឬមានអារម្មណ៍រំភើប តិច ឬ ច្រើន ដែលបានធ្វើជាក្រុមគ្រប់គ្រងភូមិ។ ពន្យល់ថា មេរៀននេះត្រូវបានរៀបចំឡើង ដើម្បីជំរុញទឹកចិត្តក្រុម ដោយផ្តល់ឱ្យក្រុមធ្វើការពិភាក្សានូវអ្វី ដែលពួកគាត់នឹងអនុវត្ត ហើយទទួលបានផល ពីការចូលរួមក្នុងកម្មវិធីនេះ។

**ការវាយតម្លៃ៖**

អ្នកសម្របសម្រួលសួរទៅសិក្ខាកាម ឱ្យគាត់បញ្ចេញយោបល់ផ្ទាល់របស់គាត់ រៀបរាប់ពី តួនាទី និង ការទទួលខុសត្រូវរបស់ យ៉ាងតិច២ ឬ ៣។

**ឯកសារយោង៖** គោលនយោបាយ ការចូលរួមរបស់សហគមន៍ (ឯកសារពង្រាង ឆ្នាំ ២០០៨)

## មេរៀនទី ៦៖ រចនាសម្ព័ន្ធនៃការអប់រំសុខភាព និងលើកកំពស់សុខភាពនៅថ្នាក់ភូមិ

**រយៈពេល ៤៥នាទី**

**វត្ថុបំណងនៃការសិក្សា៖**

នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមទាំងអស់នឹងអាចៈ

**១–** ពន្យល់ពីរចនាសម្ព័ន្ធនៃការអប់រំសុខភាព និងលើកកំពស់សុខភាព នៅថ្នាក់ភូមិ។

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សា។
- ក្រដាសផ្ទាំងធំ ដែលមានគំនូសបំប្រួញនៃរចនាសម្ព័ន្ធពីរ។
- ក្តារខៀន ហ្វឺត ក្រដាស់ផ្ទាំងធំ កន្ត្រៃ និងបង់ស្អិត។

**វិធីសាស្រ្តបង្រៀន៖**

- បាឋកថា
- បាឋកថា អមការពិភាក្សាក្រុម

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម៖**

**សេចក្តីផ្តើម** " ក្រុមគ្រប់គ្រងភូមិគឺនៅកណ្តាលនៃរចនាសម្ព័ន្ធនៃការអប់រំសុខភាពនិងលើកកំពស់សុខភាពនៅថ្នាក់ភូមិ ដែលមានសមាជិក ៥-៧ រូប រួមមាន គណៈកម្មាធិការឃុំដើម្បីស្ត្រី និងកុមារ ១នាក់ ប្រធាន/អនុប្រធានភូមិ១នាក់ ក្រុមទ្រទ្រង់សុខភាពភូមិពីរនាក់ និងអ្នកតំណាងសហគមន៍ផ្សេងទៀតរួមទាំងគណៈកម្មការគ្រប់គ្រងមណ្ឌល

សុខភាព និងក្រុមប្រឹក្សាឃុំ គឺជាអ្នកដើរតួរសំខាន់នៅក្នុងរចនាសម្ព័ន្ធនៃការចូលរួមរបស់សហគម។

**ចំនុចបំណងទី១៖ ពន្យល់ពីរចនាសម្ព័ន្ធនៃការអប់រំសុខភាព និងលើកកំពស់សុខភាព នៅថ្នាក់ភូមិ**

➢ **បាឋកថា អមការពិភាក្សាក្រុម**

បង្ហាញសិក្ខាកាមនូវរចនាសម្ព័ន្ធនៃក្រុមគ្រប់គ្រងភូមិ ដោយប្រើតារាងខាងក្រោមជា ជំនួយ ក្នុងការពន្យល់ និង ពិភាក្សា។

នៅក្នុងភូមិនីមួយៗ មាន ក្រុមគ្រប់គ្រងភូមិ មួយក្រុម។ ក្រុមគ្រប់គ្រងភូមិរួមមាន គណៈកម្មាធិការឃុំដើម្បីស្ត្រី និងកុមារ ប្រធាន/អនុប្រធានភូមិ ក្រុមទ្រទ្រង់សុខភាពភូមិពីរនាក់ និងអ្នកតំណាងសហគមន៍ផ្សេងទៀត.

សមាជិកភាព ក្រុមគ្រប់គ្រងភូមិ មាន៖

- គណៈកម្មាធិការឃុំដើម្បីស្ត្រី និងកុមារ ១រូប
- ជំទប់ឃុំដែលទទួលខុសត្រូវខាងសុខភាព១រូប
- ប្រធាន/អនុប្រធានភូមិ១រូប
- ក្រុមទ្រទ្រង់សុខភាពភូមិ ២រូប ដែលត្រូវបោះឆ្នោតដោយសហគមន៍ដែលទទួលខុសត្រូវ ១០-២០ គ្រួសារ
- និងអ្នកតំណាងសហគមន៍ផ្សេងទៀត១រូប.

គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព គួរមានចំនួនសមាជិកចន្លោះពី ៩-១១រូប រួមមាន៖

- ប្រធាន៖ អនុប្រធានក្រុមប្រឹក្សាឃុំ ដែលទទួលបន្ទុកសង្គមកិច្ច រួមទាំង សុខាភិបាល និង អប់រំ។ល។ ក្នុងករណីដែលមណ្ឌលសុខភាពគ្របដណ្តប់ឃុំលើសពី១ប្រធានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព គឺជាអនុប្រធានក្រុមប្រឹក្សាឃុំដែលមណ្ឌលសុខភាពនោះតាំងនៅ។
- អនុប្រធាន៖ គឺជាប្រធានមណ្ឌលសុខភាព។ក្នុងករណីដែលប្រធានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព អវត្តមាន អនុប្រធានគណៈកម្មការ នឹងក្លាយជាប្រធានស្តីទី។
- សមាជិកដទៃទៀត៖
  - សមាជិកបន្ថែមពីក្រុមប្រឹក្សាឃុំ ១រូបទៀត អ្នកដែលគួរចង់បាន គឺជនបង្គោលស្ត្រី និងកុមារ
  - សមាជិកបន្ថែមពីមណ្ឌលសុខភាព ១រូបទៀត អ្នកដែលគួរចង់បាន គឺឆ្មបមណ្ឌលសុខភាព ដែលបំពេញតួនាទីជាលេខាធិការ
  - ប្រធានក្រុមទ្រទ្រង់សុខភាពភូមិ ៤-៧រូប មកពីតំបន់គ្របដណ្តប់មណ្ឌលសុខភាពដោយ ធានាថា ពួកគាត់មកពីឃុំនីមួយៗ ដែលមណ្ឌលសុខភាពគ្របដណ្តប់ និងមានចំនួនបុរសស្មើនឹងស្ត្រី។

ក្រុមប្រឹក្សាឃុំ ផ្តល់នូវការគ្រប់គ្រងរួម និងមើលការខុសត្រូវ លើមុខងារនៃគណៈកម្មការគប់គ្រងមណ្ឌលសុខភាព។ ពួកគាត់ផ្តល់ការគាំទ្រ ដូចជាផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធមណ្ឌលសុខភាព (ពាក់ព័ន្ធនឹងប្រភពហិរញ្ញវត្ថុ) និងទិដ្ឋភាពផ្សេងៗ នៃការអនុវត្តទំហំការងាររបស់ ក្រុមគ្រប់គ្រងភូមិ.

## រចនាសម្ព័ន្ធគ្រប់គ្រងការប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន




## សង្ខេបមេរៀនឡើងវិញ

- សង្ខេបពី ទស្សនៈទូទៅនៃអ្នកដើរតួសំខាន់ នៅក្នុងរចនាសម្ព័ន្ធនៃការចូលរួមរបស់សហគមន៍ ដូចជា ក្រុមគ្រប់គ្រងភូមិ គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និង ក្រុមប្រឹក្សាឃុំ។

## ការវាយតម្លៃ៖

អ្នកសម្របសម្រួលសួរទៅសិក្ខាកាមថា នរណាជា ក្រុមគ្រប់គ្រងភូមិ នៅក្នុងភូមិរបស់គាត់។

## ឯកសារយោង៖

គោលនយោបាយ ការចូលរួមរបស់សហគមន៍(ឯកសារពង្រាងឆ្នាំ២០០៨) និងសេចក្ដីណែនាំអំពីការគ្រប់គ្រង និងការអនុវត្តន៍យុទ្ធសាស្រ្តប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន០៥កុម្ភៈ២០១៣

## មេរៀនទី៧ ៖ ការសង្ខេប និងការសាកល្បងក្រោយសិក្សា រយៈពេល ៣០នាទី

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច ៖

១. រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ
២. វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយពេលសិក្សា

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំធំ មានវត្ថុបំណងម៉ូឌុលសរសេរលើនោះ
- ក្រដាសផ្ទាំងធំ មានសារគន្លឹះសម្រាប់ម៉ូឌុលនេះ
- ហ្វឺតសម្រាប់សរសេរ, បង់ស្កុត
- បញ្ជីសំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

**វិធីសាស្ត្របង្រៀន៖**

- ពិភាក្សាក្រុម
- តេស្តក្រោយវគ្គសិក្សា

**ជំហានសកម្មភាព៖**

**បង្ហាញពីវត្ថុបំណងរួម៖**

**សេចក្តីផ្តើម៖** អ្នកសម្របសម្រួលពន្យល់ថា នេះគឺជាមេរៀនចុងក្រោយសម្រាប់ម៉ូឌុលនេះ។

**វត្ថុបំណងទី១៖ រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ**

**ពិភាក្សាក្រុម**

- អ្នកសម្របសម្រួល ដឹកនាំសិក្ខាកាមពិភាក្សាពីចំណុចសង្ខេប និងសារគន្លឹះសម្រាប់ម៉ូឌុលនេះ។ អ្នកសម្របសម្រួលគួរមានសារគន្លឹះនៅលើក្រដាសផ្ទាំងធំ បិទឱ្យសិក្ខាកាមឃើញ។ បន្ទាប់មក ស្នើឱ្យសិក្ខាកាមអានសារគន្លឹះទាំងនេះ។
- បន្ទាប់មក អ្នកសម្របសម្រួល សួរសិក្ខាកាមថា តើមានសំណួរអ្វីទេ។

**វត្ថុបំណងទី ២៖ វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយ ពេលសិក្សា**

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថា មុននឹងយើងបញ្ចប់ម៉ូឌុលនេះ យើងនឹងធ្វើតេស្តក្រោយពេលសិក្សាខ្លីមួយ។ តេស្តនេះគឺដូចគ្នានឹងតេស្តមុនពេលសិក្សាដែលអ្នកទាំងអស់គ្នាបានធ្វើ មុនចាប់ផ្តើមម៉ូឌុលនេះដែរ។ ការធ្វើតេស្តបែបនេះ គឺដើម្បីវាស់ពីចំណេះដឹងសិក្ខាកាមនៅមុននឹងក្រោយពេលសិក្សា ដើម្បីចង់ដឹងថា តើអ្នក ទាំង

អស់គ្នា បានទទួលចំណេះដឹងប៉ុណ្ណាពីវគ្គនេះ។ ដូច្នេះ សូមកុំព្រួយបារម្ភ ប្រសិនបើអ្នកមិនចេះសំណួរណា មួយនោះ។

បន្ទាប់មក ចែកសំណួរតេស្តដល់សិក្ខាកាម។

ក្រោយពីសិក្ខាកាមបានធ្វើតេស្តក្រោយពេលសិក្សាចប់ អ្នកសម្របសម្រួលគួរបូកសរុបចម្លើយ ហើយប្រៀប-ធៀបនឹងលទ្ធផលតេស្តមុនពេលសិក្សា។

## សំណួរតេស្តមុនការសិក្សា និងក្រោយការសិក្សា៖

សំណួរខុស-ត្រូវ។ ចម្លើយត្រឹមត្រូវ គឺនៅក្នុងប្រអប់ពណ៌ខ្មៅ។

| | | |
|---|---|---|
| ១. គោលបំណងនៃវគ្គសិក្សានេះ គឺដើម្បីបណ្តុះបណ្តាលអ្នកឱ្យក្លាយជាចុងភៅដ៏ល្អម្នាក់ | ត្រូវ | ខុស |
| ២. ក្រុមគ្រប់គ្រងភូមិ អាចផ្តល់ដំបូន្មាននានាដែលត្រូវធ្វើប្រសិនបើមាននរណាម្នាក់ឈឺ | ត្រូវ | ខុស |
| ៣. សម្របសម្រួល/រៀបចំកិច្ចប្រជុំ និង យុទ្ធនាការអប់រំសុខភាព នានានៅក្នុងសហគមន៍ | ត្រូវ | ខុស |
| ៤. ក្រុមគ្រប់គ្រងភូមិ ផ្តល់នូវការអប់រំសុខភាពដល់អ្នកភូមិ ដើម្បីធានាឲ្យភូមិក្លាយជាភូមិសុខភាពគំរូ | ត្រូវ | ខុស |
| ៥. ក្រុមគ្រប់គ្រងភូមិ ធ្វើរបាយការណ៍ប្រចាំត្រីមាសទៅ គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព | ត្រូវ | ខុស |
| ៦. រៀបចំបង្កើតផែនការសកម្មភាពប្រយុទ្ធនឹងជំងឺឆ្លងនៅតាមសហគមន៍មូលដ្ឋាន និងសម្របសម្រួលបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។ | ត្រូវ | ខុស |

# ម៉ូឌុលទី២

## ជំងឺរាក

# សៀវភៅបណ្តុះបណ្តាលក្រុមគ្រប់គ្រងភូមិ

## ម៉ូឌុលទី២ ជំងឺរាគ

| ចំណងជើងមេរៀន | វត្ថុបំណងនៃការសិក្សា | រយៈពេល* |
|---|---|---|
| ១.ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា | ១– រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ<br>២– អនុវត្តការសាកល្បងមុនការសិក្សា | ៣០នាទី |
| ២. ជំងឺរាគ | ១– កំណត់និយមន័យជំងឺរាគនិងអាការៈនៃជំងឺរាគ<br>២– ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺរាគ(ខ្វះអនាម័យ)<br>៣– រៀបរាប់ពីការព្យាបាល និងការថែទាំជំងឺរាគស្រាលនៅផ្ទះ<br>៤– រៀបរាប់ពីរបៀបលាយទឹកអូរ៉ាលីត និងការផ្តល់ឲ្យកុមារនៅផ្ទះ<br>៥– រៀបរាប់ពីរបៀបផ្តល់ឱសថសង្ក័សី និងការផ្តល់ឲ្យកុមារនៅផ្ទះ<br>៦– រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺរាគធ្ងន់ធ្ងរដែលត្រូវបញ្ជូនទៅ មណ្ឌលសុខភាព<br>៧– រៀបរាប់ពីវិធានការការពារជំងឺរាគ | ៤ម៉ោង |
| ៣. ការសង្ខេប និងការសាកល្បងក្រោយសិក្សា | ១– កំណត់បាននូវសិក្ខាកាមត្រូវការជំនួយ ឬការគាំទ្របន្ថែម<br>២– អនុវត្តការសាកល្បងក្រោយការសិក្សា | ៣០នាទី |
| **សរុប** | | **៥ម៉ោង** |

* ថ្ងៃបណ្តុះបណ្តាលនិមួយៗមានរយៈពេលសរុបម៉ោង (ព្រឹកម៉ោង៨ព្រឹក ដល់៥ល្ងាច)

- រយៈពេលបណ្តុះបណ្តាល៥ម៉ោង (ពេលព្រឹក៣ម៉ោង និងរសៀល២ម៉ោង)
- សម្រាក ២ម៉ោងសម្រាប់អាហារថ្ងៃត្រង់និង១ម៉ោងសម្រាប់អាហារសម្រន់ (ព្រឹក៣០នាទី និងរសៀល៣០នាទី)

# សេចក្តីណែនាំកម្មវិធីសិក្សា

## ម៉ូឌុលទី ២៖ អំពីជំងឺរាក

### មេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងដំបូង រយៈពេលសរុប ៣០នាទី

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្ត្របង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ | គោលបំណង នៃ ម៉ូឌុលទី ២ | បាឋកថា | ផ្ទាំងក្រដាសធំ ដែលមាន សរសេរអំពីគោលបំណងនៃម៉ូឌុលនេះ | ១៥ នាទី | សំណួរ-ចម្លើយ |
| ២.អនុវត្តការសាកល្បងមុនការសិក្សា | ការសាកល្បង មុនការសិក្សា | ការសាកល្បង មុនការសិក្សា | ឯកសារសាកល្បងមុនការសិក្សា<br>ក្តាខៀន ហ្វឺត<br>ក្រដាសផ្ទាំងធំ | ១៥ នាទី | ការត្រួតពិនិត្យ |

### មេរៀនទី ២៖ ជំងឺរាក រយៈពេលសរុប៤ម៉ោង

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្ត្របង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. កំណត់និយមន័យនិងអាការៈនៃជំងឺរាក | – និយមន័យជំងឺរាក<br>– អាការៈនៃជំងឺរាក | – សំណួរបំផុសគំនិត | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺរាក (ខ្វះអនាម័យ) | - មូលហេតុនិងសារគន្លឹះដែលបង្កឲ្យមានជំងឺរាក | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ<br>– សន្លឹករូបភាពទំព័រទី៣២ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៣. រៀបរាប់ពីការព្យាបាល និងការថែទាំជំងឺរាកស្រាលនៅផ្ទះ | – វីធីព្យាបាល និង សារគន្លឹះសំខាន់ព្យាបាល និងថែទាំជំងឺរាកស្រាល | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ<br>សន្លឹករូបភាពទំព័រទី៣៣ | ៤០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៤. រៀបរាប់ពីរបៀបលាយទឹកអូរ៉ាលីត និងការផ្តល់ឲ្យកុមារ នៅផ្ទះ | – របៀបលាយទឹកអូរ៉ាលីត និង របៀបផ្តល់ឲ្យកុមារផឹក | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ<br>សន្លឹករូបភាពទំព័រទី៣៤ | ៤០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ៥. រៀបរាប់ពីរបៀបផ្តល់ឱសថសង្គ័សី និងការផ្តល់ឲ្យកុមារ នៅផ្ទះ | ស្គាល់ឱសថសង្គ័សី និងរបៀបផ្តល់ឲ្យកុមារនៅផ្ទះ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ សន្លឹករូបភាពទំព័រទី៣៥ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៦. រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺរាកធ្ងន់ធ្ងរ ដែលត្រូវបញ្ជូនទៅគ្រឹះស្ថានសុខាភិបាល | – ស្គាល់សញ្ញាដែលត្រូវនាំកុមារទៅគ្រឹះស្ថានសុខាភិបាល | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>– សន្លឹករូបភាពទំព័រទី៣៦ | ៤០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៧. រៀបរាប់ពីវិធានការការពារជំងឺរាក | – វិធានការ ការពារនិងសារគន្លឹះ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ សន្លឹករូបភាពទំព័រទី៣៧ | ៣០ នាទី | សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

**មេរៀនទី ៣៖ ការសង្ខេប និងការសាកល្បងក្រោយសិក្សា** **រយៈពេលសរុប ៣០នាទី**

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១- កំណត់បាននូវសិក្ខាកាមណា ដែលចាំបាច់ត្រូវការជំនួយ ឬ ការគាំទ្របន្ថែម | – ដំណោះស្រាយបញ្ហានានា និងសំណូមពររបស់សិក្ខាកាម | – ពិភាក្សាក្រុម | – ផ្ទាំងក្រដាសធំ មានសរសេរ អំពីវត្ថុបំណងការសិក្សា<br>– ក្រដាសផ្ទាំងធំ<br>– ក្តាខៀន ហ្វឺត | ១៥ នាទី | – សំណួរ-ចម្លើយ |
| ២- អនុវត្តការសាកល្បងក្រោយការសិក្សា | ការសាកល្បងក្រោយការសិក្សា | សាកល្បងក្រោយការសិក្សា | ឯកសារសាកល្បងក្រោយការសិក្ស | ១៥ នាទី | ការត្រួតពិនិត្យ |

# គម្រោងមេរៀន

## ចំណាងជើងមេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងមុនការសិក្សា រយៈពេល ៣០នាទី

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ

២. អនុវត្តការសាកល្បងមុនការសិក្សា។

**សម្ភារៈជំនួយបង្រៀន៖**

- ផ្ទាំងក្រដាសធំ ដែលមានសរសេរអំពីវត្ថុបំណងសិក្សាថ្ងៃនេះផងដែរ
- ឯកសារសំណួរសាកល្បងមុនការសិក្សា ដែលបានថតចម្លងរួច សម្រាប់សិក្ខាកាមនីមួយៗ

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- ការសាកល្បងមុនការសិក្សា

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖ សូមស្វាគមន៍ម្តងទៀត ចំពោះកម្មវិធីបណ្តុះបណ្តាលម៉ូឌុលទី២របស់យើង។ យើងសង្ឃឹមថា អ្នកទទួលបាន នូវបទពិសោធន៍ល្អៗច្រើន កាលពីម៉ូឌុលមុនៗដូចជាអ្នកបានសាកល្បង នូវសកម្មភាពជាក្រុមក្រុមគ្រប់គ្រងភូមិ របស់អ្នក។ យើងនឹងពិភាក្សាគ្នាអំពីបទពិសោធន៍ខ្លះៗរបស់អ្នកនៅថ្ងៃនេះ។ យើងពេញចិត្តនឹងស្តាប់យោបល់ និងគំនិតផ្សេងៗរបស់អ្នកណាស់។

បន្តិចទៀត យើងនិងពិភាក្សាច្រើនអំពីជំងឺរាក មូលហេតុ ការការពារ របៀបព្យាបាលនិងការស្វែងរកការថែទាំពេលមានសញ្ញាគ្រោះថ្នាក់ ។ ប៉ុន្តែការការពារជំងឺរាក និងជំងឺដទៃផ្សេងទៀត ប្រសើរជាងការចំណាយពេលវេលា និងថវិកាសម្រាប់ព្យាបាល។ តើអ្នកយល់ឃើញអញ្ចឹងឬទេ?

## វត្ថុបំណងទី ១៖ រៀបរាប់ពីគោលបំណង នៃការបណ្តុះបណ្តាលថ្ងៃនេះ

➢ បាឋកថា

ការអនុវត្តអនាម័យល្អ ដែលជាការរក្សាខ្លួនយើង និងអ្វីៗជុំវិញយើង ឱ្យបានស្អាត គឺជាមធ្យោបាយមួយ ក្នុង ចំណោមមធ្យោបាយដ៏ល្អបំផុត ដើម្បីជៀសវាងការកើតជំងឺមានជំងឺរាក និងជំងឺផ្សេងៗទៀត។ ការប្រព្រឹត្តិដែលមានអនាម័យល្អប្រសើរជាងការចំណាយប្រាក់ ការចំណាយពេលវេលា ដើម្បីព្យាបាលជំងឺដែលបណ្តាលមកពីការប្រព្រឹត្តិគ្មានអនាម័យ។ ដូច្នេះ គោលបំណងរបស់ យើងនៅថ្ងៃនេះគឺ ៖

- ពិភាក្សាអំពីជំងឺរាក

- ពិភាក្សាថាហេតុអ្វីអនាម័យល្អមានសារៈសំខាន់ចំពោះសុខភាពយើង ជាពិសេសជៀសវាងពីជំងឺរាកបាន
- ពិភាក្សាថា តើត្រូវអនុវត្តអនាម័យល្អនៅផ្ទះរបស់យើងដូចម្តេចដើម្បីការពារកុំឲ្យមានជំងឺរាក

**វត្ថុបំណងទី ២៖ អនុវត្តការសាកល្បងមុនការសិក្សា**

➢ ការសាកល្បងមុនការសិក្សា

មុនពេលយើងចាប់ផ្តើម យើងចង់ឱ្យអ្នកទាំងអស់គ្នា ធ្វើសំណួរសាកល្បងមួយខ្លីៗ។ ប្រហែលជាអ្នកនៅចាំ បានថា កាលពីលើកមុនសំណួរសាកល្បងនេះ នឹងជួយអ្នកសម្របសម្រួលឱ្យរកឃើញ នូវវិធីសាស្ត្រល្អបំផុតដែលជួយ ដល់ការរៀនសូត្រនៅក្នុងវគ្គនេះ។ សូមកុំបារម្ភ ប្រសិនបើអ្នកមិនដឹងរាល់ចម្លើយទាំងអស់។ គ្រាន់តែសាកល្បង ឆ្លើយឱ្យបានល្អតាមដែលអាចធ្វើបាន។ មុនពេលយើងចាប់ផ្តើម តើអ្នកមានសំណួរអ្វីទេ?

១. ចែកសំណួរសាកល្បងមុនការសិក្សាដល់សិក្ខាកាមម្នាក់មួយច្បាប់ និងសុំឱ្យពួកគាត់ធ្វើរៀងៗខ្លួន។

២. រក្សាទុកពិន្ទុនេះដើម្បីប្រៀបធៀប ជាមួយនឹងពិន្ទុសាកល្បងក្រោយការសិក្សា។

**សំណួរសាកល្បងមុន និងក្រោយការសិក្សា**

សំណួរត្រូវ ឬ ខុស (ចម្លើយត្រឹមត្រូវ គឺនៅក្នុងប្រអប់ពណ៌ខ្មៅ

| | | |
|---|---|---|
| ១. រាកបណ្តាលមកពីការហូបចំណី ផឹកទឹក គ្មានអនាម័យ គ្មានសុវត្ថិភាព | ត្រូវ | ខុស |
| ២. ការលាងសំអាតដៃជាមួយសាប៊ូ ឬផេះ បន្ទាប់ពីបន្ទោបង់ជាទង្វើដ៏ល្អមួយ | ត្រូវ | ខុស |
| ៣. ការលាងសំអាតដៃបន្ទាប់ពីលាងគូថទារកមិនចាំបាច់ទេ | ត្រូវ | ខុស |
| ៤. សាប៊ូ និងផេះ ល្អសម្រាប់លាងសំអាតដៃ | ត្រូវ | ខុស |
| ៥. កន្លែងធ្វើម្ហូប និងសម្ភារៈផ្ទះបាយ (ដូចជា ចាន សម ស្លាបព្រា ចង្កឹះ និង ខ្ទះ។ល។)គ្មានអនាម័យ | ត្រូវ | ខុស |
| ៦. លាមករបស់ទារកមិនបង្កគ្រោះថ្នាក់ដល់សុខភាព ដូចលាមកមនុស្សពេញវ័យទេ | ត្រូវ | ខុស |
| ៧. អាហារគួរការពារកុំឱ្យរុយពោម ព្រោះរុយជាសត្វកខ្វក់ ហើយអាចបណ្តាលឱ្យមនុស្សមានរាក | ត្រូវ | ខុស |
| ៨. កុមារមានរាក ត្រូវឱ្យអាហារញាំ និងជាតិទឹកច្រើនជាងធម្មតា។ | ត្រូវ | ខុស |
| ៩. រាកអាចមានគ្រោះថ្នាក់ដល់អាយុជីវិត ពីព្រោះវាធ្វើឱ្យរាងកាយបាត់បង់នូវជាតិទឹកជាច្រើន។ | ត្រូវ | ខុស |

១០. សូមគូសរង្វង់លើអក្សរខាងមុខ វត្ថុពីរប្រភេទសម្រាប់លាង និងជូតដៃឱ្យបានស្អាត។ ចម្លើយត្រឹមត្រូវ គឺ អក្សរ  ក និង គ។

ក. សាប៊ូ ឬផេះ

ខ. ស្ងោ ទឹកសុទ្ធ

គ. ក្រមា ឬកន្សែងស្អាត

១១.  សូមគូសរង្វង់លើអក្សរនៅខាងមុខឃ្លា, ដែលបញ្ជាក់ពីពេលវេលាសំខាន់៣ សម្រាប់ការលាងសំអាតដៃ របស់អ្នក។

ចម្លើយត្រឹមត្រូវ គឺអក្សរ ក ខ និង ឃ ។

ក. ក្រោយពេលបន្ទោបង់

ខ. ក្រោយលាងគូថទារក

គ. ក្រោយពីបរិភោគ

ឃ. មុនពេលរៀបចំម្ហូបអាហារ

១២. តើមធ្យោបាយណាមួយដែលងាយស្រួល សម្រាប់ធ្វើទឹកឱ្យមានសុវត្ថិភាព? ចម្លើយត្រឹមត្រូវ ដាំទឹកឱ្យពុះ។

១៣. កុមារម្នាក់អាយុ៩ខែ មានជំងឺរាក តើជាតិទឹកអ្វីខ្លះដែលលោក អ្នកត្រូវអោយ?

☐ ទឹកដោះម្តាយ

☐ ទឹកអូរ៉ាលីត

☐ ទឹកឆ្អិន ទឹកដូងខ្ចី ទឹកបបរ ទឹកសំឡ

១៤. កុមារម្នាក់អាយុ៤ខែកន្លះ(បៅដោះសុទ្ធ) មានជំងឺរាក តើជាតិទឹកអ្វីខ្លះដែលលោក អ្នកមិនត្រូវអោយ?

☐ ទឹកដោះម្តាយ

☐ ទឹកអូរ៉ាលីត ឬទឹកស្អាត

☐  ទឹកដូងខ្ចី ទឹកបបរ ទឹកសំឡ ទឹកត្នោតផ្អែម ទឹកអំពៅ

១៥. ចូររៀបរាប់ពី វិធីលាយទឹកអូរាលីត?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

១៦. ចូររៀបរាប់ពីបរិមាណទឹកអូរាលីតដែលត្រូវផ្តល់អោយកូនរបស់អ្នក មានរាក?

..................................................................................................................................

.................................................................................................................................................

.................................................................................................................................................

.................................................................................................................................................

១៧. ចូររៀបរាប់សញ្ញាសំខាន់ៗ៥ នៃជំងឺរាកដែលត្រូវបញ្ជូនជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាល?

- ..................................................................
- ..................................................................
- ..................................................................
- ..................................................................
- ..................................................................

**ចំណងជើងមេរៀនទី ២៖ ជំងឺរាក** **រយៈពេល ៤ ម៉ោង**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១– កំណត់និយមន័យជំងឺរាកនិងអាការៈនៃជំងឺរាក

២– ពិភាក្សាអំពី មូលហេតុដែលបង្កឱ្យមានជំងឺរាក (កង្វះអនាម័យ)

៣– រៀបរាប់ពី ការព្យាបាល និងការថែទាំជំងឺរាកស្រាលនៅផ្ទះ

៤– រៀបរាប់ពី របៀបលាយទឹកអូរ៉ាលីត និងការផ្តល់ឲ្យកុមារ នៅផ្ទះ

៥– រៀបរាប់ពី របៀបផ្តល់ឱសថសង្ក័សី និងការផ្តល់ឲ្យកុមារ នៅផ្ទះ

៦– រៀបរាប់ពី រោគសញ្ញា ឬអាការៈជំងឺរាកធ្ងន់ធ្ងរដែលត្រូវបញ្ជូនទៅគ្រឹះស្ថានសុខាភិបាល។

៧– រៀបរាប់ពី វិធានការការពារជំងឺរាក

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណាងនៃការសិក្សា
- រូបភាពទំព័រទី ៣២ ៣៣ ៣៤ ៣៥ ៣៦ និង៣៧
- ក្រដាស ដែលមានសរសេរសារកំណត់និយមន័យ អាការៈ មូលហេតុ ការព្យាបាល និងការថែទាំ របៀបលាយទឹកអូរ៉ាលីត របៀបផ្តល់ឱសថសង្ក័សី រោគសញ្ញា ឬអាការៈជំងឺរាកធ្ងន់ធ្ងរ វិធានការការពារជំងឺរាក
- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត កន្រ្តៃ និងបង់ស្អិត។

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- សំណួរបំផុសគំនិត
- ពិភាក្សាក្រុមធំ

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖

ដោយផ្អែកលើបទពិសោធន៍របស់យើងកន្លងមក អ្នកទាំងអស់គ្នាបានយល់ដឹង អំពីអ្វីជាជំងឺរាក ប៉ុន្តែប្រហែល ជាយើងមិនទាន់យល់ច្បាស់ អំពីមូលហេតុរបស់វា និងការការពារ ។ ឥឡូវនេះ យើងចាប់ផ្តើមពិភាក្សាអំពីមូលហេតុខ្លះៗនៃរាក ដូច្នេះយើងអាចយល់អំពី របៀបការពារជំងឺរាកនៅពេលអនាគត។

**វត្ថុបំណងទី ១៖កំណត់និយមន័យនិងអាការៈនៃជំងឺរាក រយៈពេល ៣០នាទី**

➢ **សំណួរបំផុសគំនិត**

**សំណួរ៖** តើនៅក្នុងភូមិរបស់យើងឥឡូវនេះមានអ្នករាកឬទេ?

តើអ្នកដឹងថាជំងឺរាកមានអាការៈយ៉ាងដូចម្តេច? អាការៈស្រាល?អាការៈធ្ងន់ធ្ងរ

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីនិយមន័យជំងឺរាក

**ចម្លើយចូលរួម៖** រាក គឺជាការបន្ទោបង់លាមកខុសធម្មតា ជ្រាយ រាវ ឬ សុទ្ធតែទឹកនិងជុះយ៉ាងតិច៣ដងឬច្រើនជាងនេះក្នុង១ថ្ងៃ (១ថ្ងៃ១យប់) ។

**អាការៈស្រាល ៖**

- កុមារលេងធម្មតា
- កុមារមិនទាន់ស្រេកទឹក
- ភ្នែកមិនទាន់ស្លក់
- ផ្ចត់ស្បែកពោះរលាមកវិញរហ័ស ក្រោយ ពីការច្បិច

**អាការៈធ្ងន់ធ្ងរ៖**

- កុមារយំរញ៉ុំរញ៉ូវ
- កុមារអស់កម្លាំង ដេកស្តូកស្តឹង
- ភ្នែករងខូងដែលអាចសម្គាល់ឃើញច្បាស់
- កុមារមិនអាចផឹកឬជញ្ជក់ដោះបានដោយសារខ្សោយខ្លាំង
- កុមារស្រេកទឹកត្រហេបត្រហប
- ផ្ចត់ស្បែកពោះរលាយឺតឬយឺតណាស់ក្រោយពីការច្បិច

- ក្អួតញឹកញាប់
- រាកមានលាយឈាម

**វគ្គបំណងទី ២៖ ពន្យល់អំពីមូលហេតុដែលបង្កឱ្យមានរាក រយៈពេល ៣០នាទី**

- **ពិភាក្សាក្រុមធំ**

បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖



- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើអ្នកគិតថាមនុស្សម្នាក់មានរាកយ៉ាងដូចម្ដេច? **ចម្លើយ៖** បណ្ដាលមកពីការផឹកទឹក មិនស្អាត ឬហូបអាហារដែលមានប្រឡាក់លាមកក្នុងនោះ អាហារដែលចម្អិនមិនបានល្អ រុយរោម បន្លែផ្លែឈើ មិនស្អាត.
- សួរសិក្ខាកាមថា តើមានឥរិយាបទអាក្រក់អ្វីខ្លះ ដែលអ្នកគិតថា បណ្ដាលឱ្យមានរាក? សូមគិតអំពីប្រជាជននៅក្នុងភូមិរបស់អ្នក ចំពោះអ្នកដែលកើតមានជំងឺរាកញឹកញាប់។ តើពួកគាត់មានឥរិយាបទអ្វីខ្លះ ដែលបង្កឱ្យពួកគាត់មានជំងឺ?
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្ដារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីមូលហេតុដែលបង្កឱ្យមានជំងឺរាក

**ចម្លើយចូលរួម៖** មូលហេតុនៃជំងឺរាក៖

១. ផឹកទឹកគ្មានអនាម័យ(គ្មានសុវត្ថិភាព)

២. មិនបានលាងដៃមុនបរិភោគ មុនពេលរៀបចំអាហារ ក្រោយពេលបន្ទោបង់ ឬក្រោយលាងគូថទារក។

៣. ការបរិភោគអាហារដែលគ្មានសុវត្ថិភាព (អាហារដែលចំអិនមិនបានល្អ បន្លែ និងផ្លែឈើដែលមិនស្អាត អាហារដែលមានរុយ ឬសត្វល្អិតទុំ អាហារដែលមានជាតិពុល...)

៤. កន្លែងធ្វើម្ហូប និងសម្ភារៈផ្ទះបាយ (ដូចជា ចាន សម ស្លាបព្រា ចង្កឹះ និងខ្ទះ។ល។)គ្មានអនាម័យ

៥. ការបន្ទោបង់លាមកពាសវាលពាសកាល។

**វត្ថុបំណងទី ៣៖ រៀបរាប់ពី ការព្យាបាល និងការថែទាំជំងឺរាកស្រាលនៅផ្ទះ រយៈពេល ៤០នាទី**

➢ ពិភាក្សាក្រុមធំ

- បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖




- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើត្រូវធ្វើដូចម្តេចនៅពេលអ្នកណាម្នាក់មានជំងឺរាកស្រាល?
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីមូលហេតុដែលបង្កឱ្យមានជំងឺរាក

**ចម្លើយ៖ ត្រូវផ្តល់ទឹកអូរ៉ាលីត និងថ្នាំគ្រាប់ជាតិស័ង្កសីដល់កុមារ** និង៖

- **កុមារអាយុតិចជាង៦ខែ**ត្រូវបន្តបំបៅដោះកូនឲ្យបានញឹកញាប់ជាង មុននិងឲ្យបានយូរនៅពេលបៅម្តងៗ ឬទឹកស្អាត
- **កុមារអាយុ៦ខែឡើង**ទៅត្រូវបន្តបំបៅដោះកូនឲ្យបានញឹកញាប់ជាងមុន និង បន្តផ្តល់អាហារដែលកុមារ ធ្លាប់ហូបរាល់ថ្ងៃ (បបរខាប់គ្រប់គ្រឿង) បន្ថែមមួយ ពេលទៀតរហូតដល់ពីរអាទិត្យក្រោយពេលបាត់រាក។ ចេកទុំជាចំណីដ៏ល្អផងដែរ សម្រាប់ក្មេងរាក។ ឬទឹកបបរ ទឹកដូង ទឹកតែ ទឹកសម្លទឹកឆ្អិន ទឹកផ្លែឈើស្រស់

**វគ្គបំណងទី ៤៖ រៀបរាប់ពី របៀបលាយទឹកអូរ៉ាលីត និងរបៀបផ្តល់ឲ្យកុមារ នៅផ្ទះ រយៈពេល ៤០នាទី**

➢ **ពិភាក្សាក្រុមធំ**

- បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖




**សំណួរពិភាក្សា៖** សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើអ្នកណាខ្លះ ធ្លាប់លាយទឹកអូរ៉ាលីតឲ្យផឹកនៅផ្ទះដែរឬទេ?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរបៀបលាយទឹកអូរ៉ាលីត្រ

**ចម្លើយ៖**

១) លាងសម្អាតដៃឲ្យស្អាតជាមួយសាប៊ូជាមុន

២) ចាក់ម្សៅអូរ៉ាលីតទៅក្នុងផ្តិលស្អាត

៣) រួចចាក់ទឹកដាំពុះដែលទុកឲ្យត្រជាក់/ទឹកធុងចម្រោះចំណុះ ១លីត្រចូលទៅក្នុងផ្តិល

៤) យកស្លាបព្រាស្អាតមកកូរឲ្យសព្វ

**សំណួរពិភាក្សា៖** តើត្រូវលាយទឹកអូរ៉ាលីត និងផ្តល់ឲ្យកូនយ៉ាងដូចម្តេច?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរបៀបផ្តល់ទឹកអូរ៉ាលីត្រឲ្យកុមារ

**ចម្លើយ៖** កម្រិតប្រើ៖

- ✓ **បើកុមារអាយុក្រោម២ឆ្នាំ៖** ត្រូវបញ្ចុកទឹកអូរ៉ាលីត ១០ស្លាបព្រាបាយ ឬលើសក្រោយពេលក្មេងជុះរាកម្តងៗ រហូតបាត់រាក
- ✓ **បើកុមារអាយុលើស២ឆ្នាំ៖** ត្រូវបញ្ចុកទឹកអូរ៉ាលីត ២០ស្លាបព្រាបាយ ឬលើសក្រោយពេលក្មេងជុះរាកម្តងៗ រហូតបាត់រាក
- ✓ មនុស្សពេញវ័យ ផឹកឲ្យបានច្រើនកាន់តែប្រសើរ
- ✓ ទឹកអូរ៉ាលីតដែលកំពុងប្រើត្រូវគ្របឲ្យជិតល្អ។

**ចំណាំ៖ ទឹកអូរ៉ាលីតដែលលាយហើយអាចប្រើបានតែ២៤ម៉ោងប៉ុណ្ណោះ ។**

១ស្លាបព្រាបាយខ្នាត៥ មីលីលីត្រ

**ឧត្តមំណាងទី ៥៖ រៀនរាប់ពី របៀបផ្តល់ឱសថសង្ក័សី និងការផ្តល់ឲ្យកុមារ នៅផ្ទះ រយៈពេល ៣០នាទី**

**ពិភាក្សាក្រុមធំ**

- o បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖




សំណួរពិភាក្សា៖ តើអ្នកណាខ្លះ ធ្លាប់ស្គាល់ថ្នាំសង្ក័សីឬទេ?តើអ្នកធ្លាប់ផ្តល់ថ្នាំគ្រាប់ជាតិស័ង្កសីដល់កុមារដែរឬទេ?តើត្រូវផ្តល់ថ្នាំគ្រាប់ជាតិស័ង្កសីឲ្យកុមារយ៉ាងដូចម្តេច?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន

- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរបៀបផ្តល់ឱសថសង្កសីឲ្យកុមារ

**ចម្លើយ៖** ត្រូវផ្តល់ថ្នាំគ្រាប់ជាតិស័ង្កសីដល់កុមារដូចខាងក្រោម៖

**កុមារអាយុក្រោម ៦ខែ៖**

ឲ្យកន្លះគ្រាប់ក្នុងមួយថ្ងៃ រយៈពេល១០ថ្ងៃ ទោះបីកុមារឈប់រាកក៏ដោយ។

**កុមារអាយុចាប់ពី ៦ខែឡើង៖**

- ឲ្យមួយគ្រាប់ក្នុងមួយថ្ងៃ រយៈពេល១០ថ្ងៃ ទោះបីកុមារឈប់រាកក៏ដោយ។

**វត្ថុបំណងទី ៦៖ រៀបរាប់ពី រោគសញ្ញា ឬអាការៈជំងឺរាកធ្ងន់ធ្ងរដែលត្រូវបញ្ជូនទៅគ្រឹះស្ថានសុខាភិបាល**

**រយៈពេល ៤០នាទី**

✓ **ពិភាក្សាក្រុមធំ**



តើពេលណាត្រូវនាំកុមារដែលមានជម្ងឺរាកទៅ មណ្ឌលសុខភាព?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីពេលដែលត្រូវនាំកុមារទៅមណ្ឌលសុខភាព

ចម្លើយ៖

- កុមារយំរញ៉ាំរញ៉ូវ
- កុមារអស់កម្លាំងដេកស្តូកស្តឹង

- ភ្នែករូងខូងដែលអាចសម្គាល់ឃើញច្បាស់
- កុមារមិនអាចផឹក ឬជញ្ជក់ដោះបានដោយសារ ខ្សោយខ្លាំង
- កុមារស្រេកទឹកត្រហេបត្រហប
- ផ្នត់ស្បែកពោះរលាយឺត ឬយឺតណាស់ក្រោយពីការច្បិច
- ក្អួតញឹកញាប់
- រាកមានលាយឈាម។

គ្រូវបញ្ជូនកុមារទៅគ្រឹះស្ថានសុខាភិបាលជាបន្ទាន់ក្នុងករណី កុមារមានរោគសញ្ញា ឬអាការៈណាមួយដូចខាងលើ

**វត្ថុបំណងទី ៧៖ រៀបរាប់ពីវិធានការការពារជំងឺរាក** **រយៈពេល ៣០នាទី**

➢ ពិភាក្សាក្រុមធំ
  - បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖



- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីមូលហេតុដែលបង្កឱ្យមានជំងឺរាក

ចម្លើយ ៖

- ផឹកទឹកស្អាត (មានសុវត្ថិភាព) ដូចជា៖ ទឹកដាំពុះ ទឹកធុងចម្រោះ ឬទឹកដាក់ក្លរីន

- ត្រូវចម្អិនអាហារឲ្យបានត្រឹមត្រូវ និងឆ្អិនល្អ ត្រូវគ្របអាហារឲ្យបានជិតដើម្បីការពាររុយរោម ឬធូលីដីហុយ ចូល
- ត្រូវលាងសម្អាតបន្លែផ្លែឈើឲ្យបានស្អាតល្អ
- ត្រូវលាងសម្អាតដៃជាមួយសាប៊ូឲ្យបានញឹកញាប់ ជាពិសេសមុនពេល បំបៅ ដោះកូន មុនពេលបរិភោគ មុនពេល រៀបចំអាហារ និងបញ្ចុក អាហារកូន និងក្រោយពេលចេញពីបង្គន់
- ត្រូវសម្អាតកន្លែងធ្វើម្ហូប និងសម្ភារៈផ្ទះបាយ៖ ចាន ឆ្នាំង ស្លាបព្រា សម ខ្ទះ ជ្រុញ កាំបិតឲ្យបានស្អាត ជានិច្ច
- ត្រូវជុះក្នុងបង្គន់ និងសម្អាតបង្គន់ឲ្យស្អាតជានិច្ច។ បើគ្មានបង្គន់ត្រូវជីកដីកប់លាមកឲ្យឲ្យបានត្រឹមត្រូវ។

**សង្ខេបម៉ូឌុល**

អ្នកសម្របសម្រួលសង្ខេបខ្លឹមសារមេរៀនតាមវត្ថុបំណងនិមួយៗ

១) និយមន័យជំងឺរាកនិង រោគសញ្ញា ឬអាការៈ

២) មូលហេតុដែលបង្កឲ្យមានជំងឺរាក

៣) រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺរាកធ្ងន់ធ្ងរដែលត្រូវបញ្ជូនទៅគ្រឹះស្ថានសុខាភិបាល

៤) ការព្យាបាល និងការថែទាំជំងឺរាកនៅផ្ទះ

៥) របៀបលាយទឹកអូរ៉ាលីត និងការផ្តល់ឲ្យកុមារនៅផ្ទះ

៦) របៀបផ្តល់ឱសថសង្កសី និងការផ្តល់ឲ្យកុមារ នៅផ្ទះ

៧) វិធីការពារជំងឺរាក

**មេរៀនទី៣៖ សង្ខេបម៉ូឌុល និងការធ្វើតេស្តក្រោយពេលសិក្សា រយៈពេល ៣០នាទី**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច ៖

១. រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ

២ វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយពេលសិក្សា

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ មានសរសេរពីវត្ថុបំណងម៉ូឌុល
- ក្រដាសផ្ទាំងធំ មានសារគន្លឹះសម្រាប់ម៉ូឌុលនេះ
- ហ្វឺតសម្រាប់សរសេរ, បង់ស្អិត
- បញ្ជីសំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

**វិធីសាស្ត្របង្រៀន៖**

- ពិភាក្សាក្រុម
- តេស្តក្រោយវគ្គសិក្សា

**ដំណាក់កាលសកម្មភាព៖**

## បង្ហាញពីវគ្គបំណាច់រួម:

**សេចក្តីផ្តើម៖** អ្នកសម្របសម្រួលពន្យល់ថា នេះគឺជាមេរៀនចុងក្រោយសម្រាប់ម៉ូឌុលនេះ។

## វគ្គបំណាចទី១៖ រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ (១៥នាទី)

## ពិភាក្សាក្រុម

- អ្នកសម្របសម្រួល ដឹកនាំសិក្ខាកាមពិភាក្សាពីចំណុចសង្ខេប និងសារគន្លឹះសម្រាប់ម៉ូឌុលនេះ។ អ្នក សម្របសម្រួលត្រូវបិទសារគន្លឹះនៅលើក្រដាសផ្ទាំងធំ ដើម្បីឱ្យសិក្ខាកាមមើល និងអាន។
- បន្ទាប់មក អ្នកសម្របសម្រួល សួរសិក្ខាកាមថា តើមានសំណួរអ្វីទេ?

## វគ្គបំណាចទី ២៖ វាយតម្លៃចំណេះដឹងតាមរយៈការធ្វើតេស្តក្រោយពេលសិក្សា (១៥នាទី)

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថា មុននឹងយើងបញ្ចប់ម៉ូឌុលនេះ យើងនឹងធ្វើតេស្តក្រោយពេលសិក្សាខ្លី មួយ។ តេស្តនេះគឺដូចគ្នានឹងតេស្តមុនពេលសិក្សាដែលអ្នកទាំងអស់គ្នាបានធ្វើមុនចាប់ផ្តើមម៉ូឌុលនេះដែរ។ ការធ្វើតេស្តបែបនេះ គឺដើម្បីវាស់ពីចំណេះដឹងសិក្ខាកាមនៅមុននឹងក្រោយពេលសិក្សា ដើម្បីចង់ដឹងថា តើអ្នក ទាំងអស់គ្នា បានទទួលចំណេះដឹងប៉ុណ្ណាពីវគ្គនេះ។ ដូច្នេះសូមកុំព្រួយបារម្ភ ប្រសិនបើអ្នកមិនចេះសំណួរណាមួយនោះ។

បន្ទាប់មក ចែកសំណួរតេស្តដល់សិក្ខាកាម។

ក្រោយពីសិក្ខាកាមបានធ្វើតេស្តក្រោយពេលសិក្សាចប់ អ្នកសម្របសម្រួលត្រូវបូកសរុបចម្លើយ ហើយប្រៀប-ធៀបនឹងលទ្ធផលតេស្តមុនពេលសិក្សា។

## សំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

សំណួរ "ត្រូវ ឬ ខុស" (សំណួរត្រូវ ត្រូវបានបង្ហាញក្នុងប្រអប់ខ្មៅ)

| | | |
|---|---|---|
| ១. រាគបណ្តាលមកពីការហូបចំណី ផឹកទឹក គ្មានអនាម័យ គ្មានសុវត្ថិភាព | ត្រូវ | ខុស |
| ២. ការលាងសំអាតដៃជាមួយសាប៊ូ ឬផេះ បន្ទាប់ពីបន្ទោបង់ជាទង្វើដ៏ល្អមួយ | ត្រូវ | ខុស |
| ៣. ការលាងសំអាតដៃបន្ទាប់ពីលាងគូថទារកមិនចាំបាច់ទេ | ត្រូវ | ខុស |
| ៤. សាប៊ូ និងផេះ ល្អសម្រាប់លាងសំអាតដៃ | ត្រូវ | ខុស |

| | | |
|---|---|---|
| ៥. កន្លែងធ្វើម្ហូប និងសម្ភារៈផ្ទះបាយ (ដូចជា ចាន សម ស្លាបព្រា ចង្កឹះ និង ខ្ទះ។ល។)គ្មានអនាម័យ | ត្រូវ | ខុស |
| ៦. លាមករបស់ទារកមិនបង្កគ្រោះថ្នាក់ដល់សុខភាព ដូចលាមកមនុស្សពេញវ័យទេ | ត្រូវ | ខុស |
| ៧. អាហារគួរការពារកុំឱ្យរុយរោម ព្រោះរុយជាសត្វកខ្វក់ ហើយអាចបណ្តាលឱ្យមនុស្សមានរាក | ត្រូវ | ខុស |
| ៨. កុមារមានរាក ត្រូវឱ្យអាហារញ៉ាំ និងជាតិទឹកច្រើនជាងធម្មតា។ | ត្រូវ | ខុស |
| ៩. រាកអាចមានគ្រោះថ្នាក់ដល់អាយុជីវិត ពីព្រោះវាធ្វើឱ្យរាងកាយបាត់បង់នូវជាតិទឹកជាច្រើន។ | ត្រូវ | ខុស |

១០. សូមគូសរង្វង់លើអក្សរខាងមុខ វត្ថុពីរប្រភេទសម្រាប់លាង និងជូតដៃឱ្យបានស្អាត។ ចម្លើយត្រឹមត្រូវ គឺ អក្សរ  ក និង គ។

ក. សាប៊ូ ឬផេះ

ខ. ស្បោ ទឹកសុទ្ធ

គ. ក្រមា ឬកន្សែងស្អាត

១១.  សូមគូសរង្វង់លើអក្សរនៅខាងមុខឃ្លា, ដែលបញ្ជាក់ពីពេលវេលាសំខាន់៣ សម្រាប់ការលាងសំអាតដៃ របស់អ្នក។
ចម្លើយត្រឹមត្រូវ គឺអក្សរ ក ខ និង ឃ ។

ក. ក្រោយពេលបន្ទោបង់

ខ. ក្រោយលាងគូថទារក

គ. ក្រោយពីបរិភោគ

ឃ. មុនពេលរៀបចំម្ហូបអាហារ

១២. តើមធ្យោបាយណាមួយដែលងាយស្រួល សម្រាប់ធ្វើទឹកឱ្យមានសុវត្ថិភាព? ចម្លើយត្រឹមត្រូវ ដាំទឹកឱ្យពុះ។

១៣. កុមារម្នាក់អាយុ៩ខែ មានជំងឺរាក តើជាតិទឹកអ្វីខ្លះដែលលោក អ្នកត្រូវអោយ?

☐ ទឹកដោះម្តាយ

☐ ទឹកអូរ៉ាលីត

☐ ទឹកឆ្អិន ទឹកដូងខ្ចី ទឹកបបរ ទឹកសំឡ

១៤. កុមារម្នាក់អាយុ៩ខែកន្លះ(បៅដោះសុទ្ធ) មានជំងឺរាក តើជាតិទឹកអ្វីខ្លះដែលលោក អ្នកមិនត្រូវអោយ?

☐ ទឹកដោះម្តាយ

☐ ទឹកអូរ៉ាលីត ឬទឹកស្អាត

☐ ទឹកដូងខ្ចី ទឹកបបរ ទឹកសំឡ ទឹកត្នោតផ្អែម ទឹកអំពៅ

១៥. ចូររៀបរាប់ពី វិធីលាយទឹកអូរាលីត?

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

១៦. ចូររៀបរាប់ពីបរិមាណទឹកអូរាលីតដែលត្រូវផ្តល់អោយកូនរបស់អ្នក មានរាក?

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

១៧. ចូររៀបរាប់សញ្ញាសំខាន់ៗ៥ នៃជំងឺរាកដែលត្រូវបញ្ជូនជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាល?

- ..............................................................................
- ..............................................................................
- ..............................................................................
- ..............................................................................
- ..............................................................................

# ម៉ូឌុលទី៣

## គ្រុនក្តៅ

# សៀវភៅបណ្តុះបណ្តាលក្រុមគ្រប់គ្រងភូមិ

## ម៉ូឌុលទី៣ គ្រុនក្តៅ

| ចំណងជើងមេរៀន | វត្ថុបំណងនៃការសិក្សា | រយៈពេល* |
|---|---|---|
| ១.ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា | ១– រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ<br>២– អនុវត្តការសាកល្បងមុនការសិក្សា | ៣៥នាទី |
| ២.គ្រុនក្តៅ | ១. កំណត់និយមន័យគ្រុនក្តៅ<br>២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានគ្រុនក្តៅ<br>៣. រៀបរាប់ពីសញ្ញា ឬអាការៈគ្រុនក្តៅ<br>៤. រៀបរាប់ពីការព្យាបាល និងការថែទាំគ្រុនក្តៅនៅផ្ទះ<br>៥. អនុវត្តវិធីផ្សេងៗ ដើម្បីបញ្ចុះកំដៅកុមារមានគ្រុនក្តៅ<br>៦. ពិភាក្សាអំពីសញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព និង ពេលណាដែលត្រូវបញ្ជូនកុមារមានគ្រុនក្តៅទៅមណ្ឌលសុខភាព<br>៧. រៀបរាប់ពីវិធានការការពារគ្រុនក្តៅ | ៣ម៉ោង |
| ៣. ជំងឺពងបែកនៅដៃ ជើង និងមាត់ | ១. កំណត់និយមន័យជំងឺពងបែកនៅដៃ ជើង និងមាត់<br>២. ពន្យល់អំពីមូលហេតុដែលបង្កឲ្យមានជំងឺពងបែកនៅដៃ ជើង និងមាត់<br>៣. រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺពងបែកនៅដៃ ជើង និងមាត់<br>៤. រៀបរាប់ពីការព្យាបាល និងការថែទាំ ជំងឺពងបែកនៅដៃ ជើង និងមាត់នៅផ្ទះ<br>៥. រៀបរាប់ពីវិធានការការពារជំងឺពងបែកនៅដៃ ជើង និងមាត់ | ១ ម៉ោង ៥០នាទី |
| ៤.ការសង្ខេប និងការសាកល្បងក្រោយសិក្សា | ១. កំណត់បាននូវសិក្ខាកាមត្រូវការជំនួយ ឬការគាំទ្របន្ថែម<br>២. អនុវត្តការសាកល្បងក្រោយការសិក្សា | ៣៥នាទី |
| **សរុប** | | **៦ម៉ោង** |

* ថ្ងៃបណ្តុះបណ្តាលនិមួយៗមានរយៈពេលសរុបម៉ោង (ព្រឹកម៉ោង៨ព្រឹក ដល់៥ល្ងាច)

- រយៈពេលបណ្តុះបណ្តាល៥ម៉ោង (ពេលព្រឹក៣ម៉ោង និងរសៀល២ម៉ោង)
- សម្រាក ២ម៉ោងសម្រាប់អាហារថ្ងៃត្រង់និង១ម៉ោងសម្រាប់អាហារសម្រន់ (ព្រឹក៣០នាទី និងរសៀល៣០នាទី)

# សេចក្តីណែនាំកម្មវិធីសិក្សា

## ម៉ូឌុលទី ៣៖ គ្រុនក្តៅ

### មេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងដំបូង រយៈពេលសរុប ៣០នាទី

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១- រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ | – គោលបំណងនៃម៉ូឌុលទី ៣ | – បាឋកថា | – ផ្ទាំងក្រដាសធំ ដែលមាន សរសេរអំពីគោលបំណង នៃម៉ូឌុលនេះ | ១០ នាទី | – សំណួរ-ចម្លើយ |
| ២- អនុវត្តការសាកល្បងមុន ការសិក្សា | – ការសាកល្បងមុនការសិក្សា | – ការសាកល្បងមុនការសិក្សា | – ឯកសារសាកល្បងមុន ការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ | ២៥ នាទី | – ការត្រួតពិនិត្យ |

### មេរៀនទី ២៖ គ្រុនក្តៅ រយៈពេលសរុប៣ម៉ោង

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| ១. កំណត់និយមន័យគ្រុនក្ដៅ | - និយមន័យគ្រុនក្ដៅ | – សំណួរបំផុសគំនិត | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្ដាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ២០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ២. ពន្យល់អំពីមូលហេតុដែលបង្កឲ្យមានគ្រុនក្ដៅ | – មូលហេតុដែលបង្កឲ្យមាន គ្រុនក្ដៅ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្ដាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>– សន្លឹករូបភាពទំព័រទី៥៦ ៥៧ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៣. រៀបរាប់ពីសញ្ញា ឬអាការៈគ្រុនក្ដៅ | – រោគសញ្ញា ឬ អាការៈ គ្រុនក្ដៅ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្ដាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ៤. រៀបរាប់ពីការព្យាបាល និងការថែទាំគ្រុនក្តៅនៅផ្ទះ | – វិធីព្យាបាលគ្រុនក្តៅ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីសារគន្លឹះនៃការថែទាំជាមូលដ្ឋានសម្រាប់កុមារមានគ្រុនក្តៅ<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៥. អនុវត្តវិធីផ្សេងៗ ដើម្បីបញ្ចុះកំដៅកុមារមានគ្រុនក្តៅ | –វីធីបញ្ចុះកំដៅកុមារមានគ្រុនក្តៅ | – អនុវត្តបង្ហាញ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ៣០ នាទី | –សំណួរ-ចម្លើយ<br>–ចម្លើយតបពីក្រុមពិភាក្សា |
| ៦. ពិភាក្សាអំពីសញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព និង ពេលណាដែលត្រូវបញ្ជូនកុមារមានគ្រុនក្តៅ ទៅមណ្ឌលសុខភាព | សញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព និង ពេលណាដែលត្រូវបញ្ជូនកុមារមានគ្រុនក្តៅ ទៅមណ្ឌលសុខភាព | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>សន្លឹករូបភាពទំព័រទី៦០ | ២០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ៧. រៀបរាប់ពីវិធានការ ការពារគ្រុនក្តៅ | វិធីការពារគ្រុនក្តៅ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ សន្លឹករូបភាពទំព័រទី៦១ | ២០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

**មេរៀនទី ៣៖ ជំងឺពងបែក ដៃ ជើង និងមាត់** **រយៈពេលសរុប២ម៉ោង**

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្ត្របង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. កំណត់និយមន័យជំងឺពងបែកនៅដៃ ជើង និងមាត់ | - និយមន័យពងបែកនៅដៃ ជើង និងមាត់ | – សំណួរបំផុសគំនិត | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ២០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ២. ពន្យល់អំពីមូលហេតុដែលបង្កឲ្យមានជំងឺពងបែកនៅដៃ ជើង និងមាត់ | – មូលហេតុដែលបង្កឲ្យមានពងបែកនៅដៃ ជើង និងមាត់ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្កុត និងកន្ត្រៃ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៣. រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺពងបែកនៅដៃជើងនិងមាត់ | – រោគសញ្ញា ឬអាការៈជំងឺពងបែកនៅដៃ ជើងនិងមាត់ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្កុត និងកន្ត្រៃ<br>សន្លឹករូបភាពទំព័រទី៦៤ | ២០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៤. រៀបរាប់ពីការព្យាបាលនិងការថែទាំ ជំងឺពងបែកនៅដៃ ជើង និងមាត់នៅផ្ទះ | - ការព្យាបាល និងការថែទាំ ជំងឺពងបែកនៅដៃ ជើង និងមាត់នៅផ្ទះ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ ចម្លើយចូលរួម<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្កុត និងកន្ត្រៃ | ២០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ៥. រៀបរាប់ពីវិធានការ ការពារជំងឺពងបែកនៅដៃ ជើង និងមាត់ | វិធីការពារជំងឺពងបែក នៅដៃ ជើង និងមាត់ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួម<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ២០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

**មេរៀនទី ៤៖ ការសង្ខេប និងការសាកល្បងក្រោយសិក្សា** **រយៈពេលសរុប ៣៥នាទី**

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១- កំណត់បាននូវសិក្ខាកាមណា ដែលចាំបាច់ត្រូវការជំនួយ ឬ ការគាំទ្របន្ថែម | – ដំណោះស្រាយបញ្ហានានា និងសំណូមពររបស់សិក្ខាកាម | – ពិភាក្សាក្រុម | – ផ្ទាំងក្រដាសធំ មានសរសេរ អំពីវត្ថុបំណងការសិក្សា<br>– ក្រដាសផ្ទាំងធំ<br>– ក្តាខៀន ហ្វឺត | ១៥ នាទី | – សំណួរ-ចម្លើយ |
| ២- អនុវត្តការសាកល្បងក្រោយការសិក្សា | – ការសាកល្បងក្រោយការសិក្សា | – សាកល្បងក្រោយការសិក្សា | – ឯកសារសាកល្បងក្រោយការសិក្សា | ២៥ នាទី | – ការត្រួតពិនិត្យ |

# គម្រោងមេរៀន

## ចំណងជើងមេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងមុនការសិក្សា រយៈពេល ៣៥នាទី

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ

២. អនុវត្តការសាកល្បងមុនការសិក្សា។

**សម្ភារៈជំនួយបង្រៀន៖**

- ផ្ទាំងក្រដាសធំ ដែលមានសរសេរអំពីវត្ថុបំណងសិក្សាថ្ងៃនេះផងដែរ
- ឯកសារសំណួរសាកល្បងមុនការសិក្សា ដែលបានថតចម្លងរួច សម្រាប់សិក្ខាកាមនីមួយៗ

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- ការសាកល្បងមុនការសិក្សា

**ដំណើរការសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖ សូមស្វាគមន៍ម្តងទៀត ចំពោះកម្មវិធីបណ្តុះបណ្តាលម៉ូឌុលទី៣របស់យើង។ យើងសង្ឃឹមថា អ្នកទទួលបាន នូវបទពិសោធន៍ល្អៗច្រើន កាលពីម៉ូឌុលមុនៗដូចជាអ្នកបានសាកល្បង នូវសកម្មភាពជាក្រុមក្រុមគ្រប់គ្រងភូមិ របស់អ្នក។ យើងនឹងពិភាក្សាគ្នាអំពីបទពិសោធន៍ខ្លះៗរបស់អ្នកនៅថ្ងៃនេះ។ យើងពេញចិត្តនឹងស្តាប់យោបល់ និងគំនិតផ្សេងៗរបស់អ្នកណាស់។

បន្ថិចទៀត យើងនិងពិភាក្សាច្រើនអំពីគ្រុនក្តៅ មូលហេតុ ការការពារ របៀបព្យាបាលនិងការស្វែងរកការថែទាំពេលមានសញ្ញាគ្រោះថ្នាក់ ។ ប៉ុន្តែការការពារគ្រុនក្តៅ និងជំងឺដទៃផ្សេងទៀត ប្រសើរជាងការចំណាយពេលវេលា និងថវិកាសម្រាប់ព្យាបាល។ តើអ្នកយល់ឃើញអញ្ចឹងឬទេ?

## វត្ថុបំណងទី ១៖ រៀបរាប់ពីគោលបំណង នៃការបណ្តុះបណ្តាលថ្ងៃនេះ រយៈពេល ១០នាទី

➢ បាឋកថា

ការអនុវត្តអនាម័យល្អ ដែលជាការរក្សាខ្លួនយើង និងអ្វីៗជុំវិញយើង ឱ្យបានស្អាត គឺជាមធ្យោបាយមួយ ក្នុង ចំណោមមធ្យោបាយដ៏ល្អបំផុត ដើម្បីជៀសវាងការកើតជំងឺមានជំងឺរាក គ្រុនក្តៅ និងជំងឺផ្សេងៗទៀត។ ការប្រព្រឹត្តិដែលមានអនាម័យល្អប្រសើរជាងការចំណាយប្រាក់ ការចំណាយពេលវេលា ដើម្បីព្យាបាលជំងឺដែលបណ្តាលមកពីការប្រព្រឹត្តិគ្មានអនាម័យ។ ដូច្នេះ គោលបំណងរបស់ យើងនៅថ្ងៃនេះគឺ ៖

- ពិភាក្សាអំពីគ្រុនក្តៅ
- ពិភាក្សាអំពីជំងឺពងបែកដៃជើងនិងមាត់

- ពិភាក្សាថា តើត្រូវធ្វើអ្វីដើម្បីការពារគ្រុនក្តៅ និងជំងឺពងបែកដៃជើងនិងមាត់

**វគ្គបំណាចទី ២៖ អនុវត្តការសាកល្បងមុនការសិក្សា រយៈពេល ២៥នាទី**

➢ ការសាកល្បងមុនការសិក្សា

មុនពេលយើងចាប់ផ្តើម យើងចង់ឱ្យអ្នកទាំងអស់គ្នា ធ្វើសំណួរសាកល្បងមួយខ្លីៗ។ ប្រហែលជាអ្នកនៅចាំ បានថា កាលពីលើកមុនសំណួរសាកល្បងនេះ នឹងជួយអ្នកសម្របសម្រួលឱ្យរកឃើញ នូវវិធីសាស្រ្តល្អបំផុតដែលជួយ ដល់ការរៀនសូត្រនៅក្នុងវគ្គនេះ។ សូមកុំបារម្ភ ប្រសិនបើអ្នកមិនដឹងរាល់ចម្លើយទាំងអស់។ គ្រាន់តែសាកល្បង ឆ្លើយឱ្យបានល្អតាមដែលអាចធ្វើបាន។ មុនពេលយើងចាប់ផ្តើម តើអ្នកមានសំណួរអ្វីទេ?

១. ចែកសំណួរសាកល្បងមុនការសិក្សាដល់សិក្ខាកាមម្នាក់មួយច្បាប់ និងសុំឱ្យពួកគាត់ធ្វើរៀងៗខ្លួន។

២. រក្សាទុកពិន្ទុនេះដើម្បីប្រៀបធៀប ជាមួយនឹងពិន្ទុសាកល្បងក្រោយការសិក្សា។

**សំណួរសាកល្បងមុន និងក្រោយការសិក្សា**

សំណួរត្រូវ ឬ ខុស (ចម្លើយត្រឹមត្រូវ គឺនៅក្នុងប្រអប់ពណ៌ខ្មៅ)

១. ពេលកូនរបស់លោក អ្នកមានជំងឺគ្រុនក្តៅ អ្នកត្រូវធ្វើអ្វីខ្លះ?

☐ ស្លៀកពាក់នូវសម្លៀកបំពាក់ក្រាស់ៗ ដើម្បីកុំអោយរងារ

☐ ត្រូវនាំកុមារទៅមណ្ឌលសុខភាពឬមន្ទីរពេទ្យ

☐ ត្រូវដោះខោអាវកុមារចេញ រួចជូតស្អំនឹងកន្សែងទទឹក ពិសេសនៅជុំវិញក ក្នុងក្លៀក និងម្តុំក្រលៀន

☐ ត្រូវតមអាហារ និងជាតិទឹកនានា

២. តើសញ្ញាអ្វីខ្លះដែលត្រូវបញ្ជូនកុមារមានគ្រុនក្តៅជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត?

☐ ត្រូវបញ្ជូនរាល់កុមារមានគ្រុនក្តៅទាំងអស់ទៅមណ្ឌលសុខភាពឬមន្ទីរពេទ្យ

☐ បៅមិនបាន ផឹកមិនបានឬ បានតិចតួច

☐ ក្អួតគ្មានសល់ក្រោយពេលបៅឬញ៉ាំ

☐ សន្លឹម ឬបាត់ស្មារតី

☐ មានសញ្ញាចេញឈាមណាមួយ

☐ ចង្វាក់ដង្ហើម ញាប់ ឬ

☐ ប្រកាច់

៣. ចូររៀបរាប់ពីវិធីសាស្រ្តបញ្ចុះកំដៅដោយស្អំទឹក?

..............................................................................................................

..............................................................................................................

..............................................................................................................

.......................................................................................................................

.......................................................................................................................

| | | |
|---|---|---|
| ៤. ជំងឺពងបែកនៅដៃ ជើង និងមាត់ ជាជំងឺឆ្លងដែលបង្កឡើងដោយវីរុស ច្រើនកើតមានចំពោះទារកនិងកុមារ ភាគច្រើនលើកុមារដែលមានអាយុតិចជាង១០ ឆ្នាំ ជាពិសេស កុមារអាយុក្រោម៥ឆ្នាំ។ ជំងឺនេះស្តែង**ចេញជា គ្រុនក្តៅ ពងបែកនៅមាត់ និង មានពង កន្ទួលលើបាតដៃ បាតជើង និង កំប៉េះគូទ។** | ត្រូវ | ខុស |
| ៥. ជំងឺពងបែក ដៃជើង និង ក្នុងមាត់ជាជំងឺឆ្លងដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមការប៉ះពាល់ ផ្ទាល់ជាមួយ នឹងវត្ថុរាវ នៃផ្លូវដង្ហើម រួមមាន ទឹកមាត់ កំហាក ស្លេស និងសំបោរ ទឹករងៃដែលចេញពីពងបែក លាមកអ្នកជំងឺ | ត្រូវ | ខុស |

៦.រោគសញ្ញា ឬអាការៈជំងឺពងបែក ដៃជើង និងមាត់មានអ្វីខ្លះ? សូមគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ (ចម្លើយត្រូវ ច)

ក. ដំបូងគ្រុនក្តៅជាទូទៅមានរយៈពេលពី ១ថ្ងៃ ទៅ២ថ្ងៃ

ខ. ការហូបចុកថយចុះ អស់កំលាំង និង ជាញឹកញយឈឺ បំពង់ក

គ. មួយឬពីរថ្ងៃបន្ទាប់ពីគ្រុនក្តៅ អ្នកជំងឺចាប់ផ្តើមឈឺក្នុងមាត់ ដោយមាន ចំនុចពណ៌ក្រហមតូចៗ ដែលចេញជាពង និងវិវត្តទៅជាដំបៅមានលើអណ្តាត អញ្ចាញ និង ផ្នែកខាងក្នុងនៃថ្ពាល់។

ឃ. ស្បែកកន្ទួលមិនរមាស់ ស្នាមកន្ទួលឬ ពងបែកជាទូទៅមាននៅលើបាតដៃ និង បាតជើង ហើយក៏អាចមាននៅលើ កំប៉េះគូទ និង អវៈយវៈភេទ។។

ង. ជួនកាលអ្នកជំងឺ មានតែកន្ទួល ឬ ដំបៅក្នុងមាត់។

ច. ក្នុងករណីធ្ងន់ធ្ងរ អ្នកជំងឺមានរោគសញ្ញាប្រព័ន្ធប្រសាទនិងផ្លូវដង្ហើមជាមួយគ្នា និងវិវត្តទៅរកការស្លាប់យ៉ាងឆាប់រហ័សបើគ្មានការព្យាបាលសមស្របទាន់ពេលវេលា។

ឆ.ទាំងអស់ខាងលើ

៧.ដើម្បីការពារជំងឺពងបែក ដៃជើង និងមាត់ តើត្រូវធ្វើដូចម្តេច? សូមគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ (ចម្លើយត្រូវ ង)

ក. ត្រូវលាងដៃអោយអោយបានស្អាតជាប្រចាំ ជាមួយទឹកនិងសាប៊ូ ឬផេះ ពិសេសក្រោយប៉ះពាល់ ជាមួយ នឹងវត្ថុរាវ នៃផ្លូវដង្ហើម រួមមាន ទឹកមាត់ កំហាក ស្លេស និងសំបោរ ទឹករងៃដែលចេញពីពងបែក លាមកអ្នកជំងឺ។

ខ. ត្រូវលាងសំអាតដៃអោយបានស្អាត មុនពេលរៀបចំអាហារ មុនពេលបរិភោគ មុនបញ្ចុកចំណីដល់ទារក ឬ កុមារ ក្រោយចេញពីបង្គន់ និងក្រោយប្តូរទ្រនាប់ គូទទារក ឬជូតសំអាតរាងកាយកុមារ។ លាងសំអាតផ្ទៃនិងរបស់ដែលប្រលាក់ដោយទឹកនិងសាប៊ូ។

គ. ជៀសវាងការប៉ះពាល់ស្និតស្នាល(ថើប អោប ប្រើប្រាស់សម្ភារៈសំរាប់ហូបចុក រួមគ្នា។ល។)ជាមួយកុមារដែលមានជំងឺពងបែកដៃជើង និងក្នុងមាត់ អាចកាត់បន្ថយការឆ្លងផងដែរ។

ឃ. ផ្តល់អាហារដែលមានសារជាតិចិញ្ចឹមច្រើននិង ទឹកស្អាតដល់កុមារ។ប្រើស្លាបព្រា និងចាន ដាច់ដោយឡែកសំរាប់កុមារនិមួយៗ។

ង. អ្នកមើលថែទាំកុមារតូចៗត្រូវមានអនាម័យផ្ទាល់ខ្លួនល្អ។

ច.ទាំងអស់ខាងលើ

៨. តើត្រូវធ្វើអ្វីខ្លះដើម្បី ព្យាបាល និងការថែទាំជំងឺពងបែក ដៃជើង និងមាត់ នៅផ្ទះ ? ហ៊ុំចម្លើយណាត្រឹមត្រូវ

ក. ឲ្យប៉ារ៉ាសេតាម៉ុល ដើម្បីបន្ថយ គ្រុនក្តៅ និង បំបាត់ការឈឺចុកចាប់

ខ. ជូត ឬលាប វីយ៉ូលេហ្សង់ស្យាន កន្លែងមានពងទឹក ឬដំបៅ

គ. មិនត្រូវប្រើថ្នាំ អាស្ពីរីន (aspirin) ដើម្បីបញ្ចុះកំដៅឡើយ

ឃ. ទាំងអស់ខាងលើ

៨. តើពេលណាដែលត្រូវយកកុមារមាន ជំងឺពងបែក ដៃជើង និងមាត់ មូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតជាបន្ទាន់? ហ៊ុំចម្លើយណាត្រឹមត្រូវ

ក. គ្រុនក្តៅខ្លាំង

ខ. សញ្ញាប្រព័ន្ធប្រសាទដូចជាសន្លឹមប្រកាច់កន្ត្រាក់រឹងដៃជើងឬទន់ដៃទន់ជើង

គ. សញ្ញាផ្លូវដង្ហើមដូចជាពិបាលដកដង្ហើមឬដកដង្ហើមញាប់។

ឃ. ទាំងអស់ខាងលើ

**ចំណងជើងមេរៀនទី ២៖ គ្រុនក្តៅ** **រយៈពេល ៣ ម៉ោង**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១. កំណត់និយមន័យគ្រុនក្តៅ

២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានគ្រុនក្តៅ

៣. រៀបរាប់ពីសញ្ញា ឬអាការៈគ្រុនក្តៅ

៤. រៀបរាប់ពីការព្យាបាល និងការថែទាំគ្រុនក្តៅនៅផ្ទះ

៥. អនុវត្តវិធីផ្សេងៗ ដើម្បីបញ្ចុះកំដៅកុមារមានគ្រុនក្តៅ

៦. ពិភាក្សាអំពីសញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព និង ពេលណាដែលត្រូវបញ្ជូនកុមារមានគ្រុនក្តៅ ទៅមណ្ឌលសុខភាព

៧. រៀបរាប់ពីវិធានការការពារគ្រុនក្តៅ

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សា

- រូបភាពទំព័រទី ៥៦ ៥៧  ៦០ និង ៦១
- ក្រដាស ផ្ទាំងធំ ដែលមានសរសេរអំពីចម្លើយចូលរួម
- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត កន្ត្រៃ និងបង់ស្អិត។

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- សំណួរបំផុសគំនិត
- ពិភាក្សាក្រុមធំ

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖

ដោយផ្អែកលើបទពិសោធន៍របស់យើងកន្លងមក អ្នកទាំងអស់គ្នាបានយល់ដឹង អំពីអ្វីជាគ្រុនក្តៅ ប៉ុន្តែប្រហែល ជាយើងមិនទាន់យល់ច្បាស់ អំពីមូលហេតុរបស់វា និងការការពារ ។ ឥឡូវនេះ យើងចាប់ផ្តើមពិភាក្សាអំពីមូលហេតុខ្លះៗនៃគ្រុនក្តៅ ដូច្នេះយើងអាចយល់អំពី របៀបការពារគ្រុនក្តៅ នៅពេលអនាគត។

**វត្ថុបំណងទី ១៖ កំណត់និយមន័យគ្រុនក្តៅ** **រយៈពេល ២០ នាទី**

➢ សំណួរបំផុសគំនិត

**សំណួរ៖** តើនៅក្នុងភូមិរបស់យើងឥឡូវនេះមានអ្នកណាមួយមានគ្រុកក្តៅឬទេ?

តើអ្នកដឹងថាគ្រុនក្តៅ មានអាការៈយ៉ាងដូចម្តេច?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីនិយមន័យគ្រុនក្តៅ

**ចម្លើយចូលរួម៖** គ្រុនក្តៅ គឺជាការកើនឡើងនូវកំដៅក្នុងខ្លួនរបស់យើង គឺមានន័យថាកំដៅ ចាប់ ពី ៣៧.៥ អង្សាសេ ឡើងទៅ។

**វត្ថុបំណងទី ២៖ ពន្យល់អំពីមូលហេតុដែលបង្កឱ្យមានគ្រុនក្តៅ** **រយៈពេល ៣០នាទី**

**ពិភាក្សាក្រុមធំ**

បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖






ផ្ដាសាយបក្សី
មិនត្រូវអោយកុមារលេង
ឬប៉ះពាល់មាន់-ទាទេ
ជាពិសេសមាន់-ទា
ដែលឈឺ ឬងាប់
គ្រោះថ្នាក់!








B


C




- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើអ្នកគិតថាមនុស្សម្នាក់មានគ្រុនក្តៅយ៉ាងដូចម្តេច?
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីមូលហេតុដែលបង្កឱ្យមានគ្រុនក្តៅ

**ចម្លើយចូលរួម៖** មូលហេតុនៃគ្រុនក្តៅ

គ្រុនក្តៅ គឺជា ការឆ្លើយតបរបស់សរីរាង្គយើង ទៅនឹងការលុកលុយរបស់ មេរោគ  ឱសថ ឬជាតិពុលផ្សេងៗ។ គ្រុនក្តៅ អាចជាសញ្ញានៃ ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺផ្តាសាយ ជំងឺផ្តាសាយបក្សី ជំងឺកញ្ជ្រឹល ជំងឺពងបែកដៃជើងនិងមាត់ ឬជំងឺធ្ងន់ធ្ងរណាមួយ។

**វត្ថុបំណងទី ៣៖ រៀបរាប់ពីសញ្ញា ឬអាការៈគ្រុនក្តៅ** **រយៈពេល ៣០នាទី**

➢ ពិភាក្សាក្រុមធំ

**សំណួរ៖** តើអ្នកណាធ្លាប់មានក្តៅខ្លួនឬទេ?

បើធ្លាប់តើក្តៅខ្លួនមានរោគសញ្ញាឬអាការៈដូចម្តេចខ្លះ?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរោគសញ្ញា ឬអាការៈគ្រុនក្តៅ

**ចម្លើយចូលរួម៖**

- កំដៅចាប់ពី៣៧.៥អង្សាសេ ស្ទង់នៅក្លៀក
- ស្រៀវស្រាញ ឬ រងាញាក់
- ឈឺសន្លាក់ ឬឈឺសាច់ដុំ ឬឈឺក្បាល
- ចង្វាក់បេះដូង និងដង្ហើម ញាប់
- ស្បែកឡើងក្រហម
- ប្រកាច់ (ពិសេសពេលកំដៅឡើងខ្លាំងនៅលើកុមារ)

## **វត្ថុបំណងទី ៤៖ រៀបរាប់ពី ការព្យាបាល និងការថែទាំគ្រុនក្តៅនៅផ្ទះ រយៈពេល ៣០នាទី**

➢ **ពិភាក្សាក្រុមធំ**

១. សូមឱ្យពួកគាត់និយាយប្រាប់អំពីបទពិសោធន៍ផ្ទាល់ខ្លួនគាត់ ទាក់ទងនឹងវិធីថែទាំកូនរបស់គាត់នៅពេលមានគ្រុនក្តៅ។ សរសេរបទពិសោធន៍ទាំងនោះដាក់លើក្រដាសផ្ទាំងធំ ឬ ក្តារខៀន។

២. សួរសិក្ខាកាម តើពួកគាត់បញ្ចុកអាហារ និងជាតិទឹកឱ្យកូន ក្នុងចំនួនច្រើនជាង តិចជាង ឬ ដដែលនៅពេល កូនឈឺ និងសួរពីមូលហេតុដែលធ្វើបែបហ្នឹង។ ចូរពិភាក្សា ពីហេតុផលប្រពៃណី និងវប្បធម៌ នៅពីក្រោយ ការអនុវត្តន៍ទាំងនេះ។

៣.បង្ហាញសារសារគន្លឹះនៃការថែទាំជាមូលដ្ឋានសម្រាប់កុមារមានគ្រុនក្តៅនៅផ្ទះលើក្រដាសផ្ទាំងធំដែលសរសេររួច ហៅសិក្ខាកាមឲ្យអាន រួចផ្ទៀងផ្ទាត់ចម្លើយជាមួយចម្លើយចូលរួមរបស់គាត់

១. ដោះខោអាវកុមារចេញរួចជូតស្អំកន្សែង ឬ ក្រម៉ាសើម (ទឹកធម្មតា) និងជាពិសេស នៅជុំវិញក ក្រោមក្លៀក និងនៅម្ដុំក្រលៀន

២. ផ្តល់ប៉ារ៉ាសេតាម៉ុលរាល់៦ម៉ោងម្តង បើនៅបន្តមានគ្រុនក្តៅ

| | ប៉ារ៉ាសេតាម៉ុល (១២.៥ មក្រ/គក្រ/ដូស) | | |
|---|---|---|---|
| អាយុ | ប៉ារ៉ាសេតាម៉ុល ស៊ីរ៉ូប (១២០មក្រ/៥ម.ល) | ប៉ារ៉ាសេតាម៉ុល (១០០មក្រ) | ប៉ារ៉ាសេតាម៉ុល (៥០០មក្រ) |
| ២ខែ ដល់ក្រោម៣ឆ្នាំ | ២.៥មល - ៥មល | ១គ្រាប់ | ១/៤(មួយជ្រុងគ្រាប់) |
| ៣ឆ្នាំ ដល់ក្រោម៥ឆ្នាំ | ៧.៥មល -១០មល | ១ ១/២(១គ្រាប់កន្លះ) | ១/២(កន្លះគ្រាប់) |
| មនុស្សចាស់ | | | ១គ្រាប់ |

៣. កុមារមានអាយុក្រោម៦ខែ(បៅដោះសុទ្ធ) ត្រូវបង្កើនការបំបៅដោះដល់កុមារអោយបានញឹកញាប់ជាងធម្មតា

៤. កុមារមានអាយុចាប់ពី៦ខែ ឬកុមារមិនបៅដោះសុទ្ធ ត្រូវផ្តល់ជាតិទឹកច្រើនជាងធម្មតា ដូចជាទឹកដោះម្តាយ ឬទឹកឆ្អិន ទឹកដូងខ្ចី ទឹកបបរ ទឹកសម្ល និង ល្វងលោម លើកទឹកចិត្តកុមារអោយបរិភោគអាហារដែលសំបូរសារជាតិចិញ្ចឹម និងផ្លែឈើទុំអោយបានញឹកញាប់ និងច្រើនជាងធម្មតា។

៥. បើគ្រុនក្តៅលើសពី ១ថ្ងៃ ត្រូវយកទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតជាងគេ។

៦. មិនត្រូវឲ្យឱសថមានជាតិអាស្ពីរីន។

៤. ពន្យល់ជូនក្រុមថា ហេតុផលដែលកុមារឈឺត្រូវការអាហារច្រើន ពីព្រោះអាហារផ្តល់នូវថាមពល និងការពារកុមារពីជំងឺដង្កាត់ផ្សេងៗ។ អាហារដែលល្អ គឺជាឱសថ មួយក្នុងចំណោម " ឱសថ " ដ៏ស័ក្តិសិទ្ធិបំផុត ដែលអាចរកបានឱ្យកុមារ។

៥. ពន្យល់ជូនក្រុមថា ហេតុផលដែល កុមារឈឺ ជាពិសេសកុមារមានគ្រុនក្តៅត្រូវការជាតិទឹកច្រើនជាងធម្មតា គឺកុមារគ្រុនក្តៅបាត់បង់ជាតិទឹក ពីរាងកាយរបស់វា តាមរយៈការបែកញើស។ ចូរប្រើរឿងខាងក្រោមធ្វើ ជាឧទាហរណ៍:

នៅពេលយើងធ្វើការក្រោមកំដៅព្រះអាទិត្យ យើងបែកញើស និងបន្ទាប់មកមានអារម្មណ៍ថា ក្តៅ និង

ស្រេកទឹកជាខ្លាំង។ ហេតុអ្វី? ពីព្រោះនៅពេលយើងបែកញើស ញើសជាទឹកដែលចេញពីរាងកាយរបស់យើង។ រាងកាយរបស់យើងត្រូវការទឹក ដើម្បីឱ្យមានសុខភាពល្អ ហេតុដូច្នេះយើងផឹកទឹក ដើម្បីបង្គ្រប់ជាតិ ទឹកដែលបាត់បង់តាមញើសនោះ។ ដូចគ្នាដែរ នៅពេលកុមារមានគ្រុនក្តៅ ពួកគេបែកញើស និងការដែល បែកញើសនេះ ធ្វើឱ្យកុមារបាត់បង់ជាតិទឹក។ យើងចាំបាច់ត្រូវបង្គ្រប់ជាតិទឹកដែលបាត់បង់ទៅនោះ ដោយ ផ្តល់ដល់ពួកគេនូវ អាហារ និងជាតិទឹកឱ្យបានច្រើន។ ចំពោះទារកអាយុក្រោម ៦ខែ យើងត្រូវឱ្យម្តាយ បំបៅដោះឱ្យបានញឹកញាប់ និងកុមារអាយុច្រើនជាង ៦ខែ យើងត្រូវបង្កើនការផ្តល់អាហារ និងជាតិទឹក។

បញ្ជាក់ថាកុមារឈឺស្រាលពុំត្រូវការឱសថ ដើម្បីឱ្យវាជាសះស្បើយនោះឡើយ។ អាហារនិងជាតិទឹកបន្ថែម ជា " ឱសថ " ដ៏ស័ក្តសិទ្ធិសម្រាប់ព្យាបាលកុមារ ដែលឈឺស្រាល។

**ចន្លុចំណោចនី ៥៖ អនុចត្តចនីផ្សេចៗ ដើម្បីបញ្ចុះកំដៅកុមារមានគ្រុនក្តៅនៅផ្ទះ រយៈពេល ៣០នាទី**

- អនុវត្តបង្ហាញ

សូមឱ្យសិក្ខាកាមអង្គុយជារង្វង់ និងសូមឱ្យអ្នកស្ម័គ្រចិត្តម្នាក់ អានឱ្យឮខ្លាំងនូវសារដំបូងមួយនៅលើផ្នែក “ សារគន្លឹះ នៃការថែទាំជាមូលដ្ឋានសម្រាប់កុមារមានគ្រុនក្តៅនៅផ្ទះ “ ។ បើសិក្ខាកាមពុំមានទំនុកចិត្តនឹងអានខ្លាំងៗ អ្នកសម្រប-សម្រួលត្រូវអានឱ្យឮខ្លាំងៗ។ សាកសួរ សិក្ខាកាមតើមានសំណួរអ្វីទេ។

១. ជូនតុក្កតាទារកមួយសម្រាប់សិក្ខាកាមម្នាក់ និងសូមឱ្យគាត់បង្ហាញការបញ្ចុះកំដៅកុមារ ដោយជូតតុក្កតា នឹងកន្សែងជ្រលក់ទឹកធម្មតា ។ រកសិក្ខាកាមឱ្យបង្ហាញក្រុមពីរបៀបជូតនៅជុំវិញកកុមារ ក្រោមក្លៀក និង នៅម្តុំក្រលៀន ដោយមានការធិប្បាយជាមួយផងដែរ។ តំបន់ទាំង៣នេះសំខាន់ណាស់សម្រាប់បញ្ចុះកំដៅ។

២. សូមឱ្យសិក្ខាកាមគ្រប់រូបអនុវត្តជូតតុក្កតាទារក ដោយផ្តោតលើតំបន់សំខាន់ទាំងបី។ សាកសួរសិក្ខាកាម តើ មានសំណួរអ្វីទេ។

៣. នៅពេលបានអនុវត្តគ្រប់គ្នាហើយ សូមឱ្យអ្នកស្ម័គ្រចិត្តម្នាក់អានឱ្យឮខ្លាំងៗ នូវសារទី ២នៅក្នុងមេរៀន។ សូមឱ្យសិក្ខាកាមចែករំលែកនូវបទពិសោធន៍ពីការឱ្យថ្នាំប៉ារ៉ាសេតាម៉ុលទៅកុមារនៅពេលគ្រុនក្តៅ។ តើគាត់ផ្តល់ថ្នាំគ្រាប់ដល់កុមារទេ? តើថ្នាំ ប៉ារ៉ាសេតាម៉ុលបន្ថយកំដៅបាន ឬទេ?។ សូមឱ្យសិក្ខាកាមគិតថាព័ត៌មាននេះ មានន័យដូចម្តេច ហើយសាកសួរពីរបៀបផ្តល់ថ្នាំប៉ារ៉ាសេតាម៉ុលឱ្យកុមារកន្លះគ្រាប់ ឬ១ជ្រុង។

៤. ចែកថ្នាំប៉ារ៉ាសេតាម៉ុល ឱ្យសិក្ខាកាមម្នាក់ ១គ្រាប់ និងបង្ហាញពីរបៀបកាត់គ្រាប់ថ្នាំជា ២ចំហៀង។ បន្ទាប់ មកកាត់ចំហៀងគ្រាប់និមួយៗ ទៅជា ២ជ្រុង ដើម្បីបាន ៤ជ្រុង។ សូមឱ្យសិក្ខាកាមស្ម័គ្រចិត្តពន្យល់ក្រុមពី ក្រុមអាយុនៃកុមារ ដែលត្រូវទទួលទំហំគ្រាប់ថ្នាំ។

៥. បន្ទាប់មក បង្ហាញពីការកិនថ្នាំប៉ារ៉ាសេតាម៉ុលជាម្សៅ និងលាយក្នុងទឹកផឹក ហើយប្រើស្លាបព្រាបញ្ចុក។

៦. សូមឱ្យអ្នកស្ម័គ្រចិត្តម្នាក់អានឱ្យឮខ្លាំងៗ សារទី ៣ដល់ទី ៦នៅក្នុងមេរៀន។ សួរក្រុមទាំងមូលហេតុអ្វីពួកគាត់គិតថា កុមារម្នាក់ដែលមានគ្រុនក្តៅ រយៈពេលលើសពី ១ថ្ងៃត្រូវនាំទៅមណ្ឌលសុខភាព។ ពន្យល់ថា ជំងឺធ្ងន់ធ្ងរ ជាច្រើនអាច បង្កឱ្យក្តៅខ្លួនខ្លាំង និងថាក្តៅខ្លួនលើសពី ១ថ្ងៃអាចមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។ បើក្តៅលើសពី ១ថ្ងៃ ត្រូវនាំកុមារទៅមណ្ឌលសុខភាព ដើម្បីព្យាបាល។ សាកសួរសិក្ខាកាមតើមានសំណួរ អ្វី

ទេ។

**ចន្លុះបំណងទី ៦៖ ពិភាក្សាអំពីសញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព និង ពេលណាដែលត្រូវបញ្ជូនកុមារមានគ្រុនក្ដៅ ទៅមណ្ឌលសុខភាព រយៈពេល ២០នាទី**

➢ **ពិភាក្សាក្រុមធំ**

**សំណួរ៖** តើសញ្ញាអ្វីខ្លះ ដែលអ្នកថែទាំត្រូវនាំកុមារទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យនៅជិតជាងគេជាបន្ទាន់?



- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្ដារខៀន
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីសញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព
- សូមឱ្យសិក្ខាកាម អានឱ្យឮខ្លាំងៗ នូវសារនៅលើក្រដាសដែលសរសេររួច ។ សាកសួរ សិក្ខាកាម តើមានសំណួរអ្វីទេ។

➢ ចម្លើយចូលរួម៖ ត្រូវបញ្ជូនកុមារមានគ្រុនក្ដៅ បើមានសញ្ញាណាមួយដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាពដូចខាងក្រោម៖

❖ មិនអាចបៅបាន ឬមិនអាចផឹកបាន ឬបានតិចតួច ឬ
❖ ក្អួតគ្មានសល់ក្រោយពេលបៅឬញុាំ ឬ
❖ សន្លឹម ឬបាត់ស្មារតីឬ
❖ ឈឺកាន់តែធ្ងន់ធ្ងរទៅៗ ឬ
❖ មានសញ្ញាចេញឈាមណាមួយដូចជា
  – ឈាមច្រមុះ

- ឈាមអញ្ចាញធ្មេញ
- ចេញចំនុចក្រហមៗក្រោមស្បែក
- មានឈាមក្នុង លាមក ឬក្នុងកម្អួត
- ចង្វាក់ដង្ហើម ញាប់ ឬ
- ប្រកាច់

**វត្ថុបំណងទី ៧៖ រៀបរាប់ពីវិធានការការពារគ្រុនក្តៅ** **រយៈពេល ២០នាទី**

➢ ពិភាក្សាក្រុមធំ

➢ បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖














- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីវិធានការការពារគ្រុនក្តៅ

**ចម្លើយ ៖**

អាចការពារកុំឲ្យមានគ្រុនក្តៅបានលុះណាតែការពារមូលហេតុដែលនាំឲ្យមានគ្រុនក្តៅ ។ ភាគច្រើននៃគ្រុនក្តៅ បណ្តាលមកពី ការឆ្លងរោគ ។ ដូច្នេះដើម្បីកុំឲ្យមានការឆ្លងរោគ ត្រូវជៀសវាងប្រភពនៃការឆ្លងរោគ និងរក្សាអនុវត្ត អនាម័យ។

វិធីការពារការរាលដាលនៃការឆ្លងមានដូចតទៅ៖

- រក្សាអនាម័យស្អាត៖ ដោយលាងដៃជាមួយសាប៊ូឲ្យបានញឹកញាប់ជាពិសេសមុនពេល បំបៅដោះកូន មុនពេលបរិភោគ មុនពេល រៀបចំអាហារ និងបញ្ចុក អាហារកូន និងក្រោយពេលចេញពីបង្គន់
- ជៀសវាងប៉ះពាល់ជាមួយអ្នកជំងឺ
- ផ្តល់អាហារូបត្ថម្ភឲ្យបានសមស្របនិងត្រឹមត្រូវ
- ទទួលថ្នាំបង្ការឲ្យសព្វគ្រប់និងត្រឹមត្រូវ
- ផឹកទឹកឲ្យបានច្រើន
- ជៀសវាងពី ជំងឺឆ្លងផ្សេងៗ

**ចំណងជើងមេរៀនទី ៣៖ ជំងឺពងបែកនៅដៃ ជើង និងមាត់ រយៈពេល ១ ម៉ោង ៥០នាទី**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១. កំណត់និយមន័យជំងឺពងបែកនៅដៃ ជើង និងមាត់

២. ពន្យល់អំពីមូលហេតុដែលបង្កឲ្យមានជំងឺពងបែកនៅដៃ ជើង និងមាត់

៣. រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺពងបែកនៅដៃ ជើង និងមាត់

៤. រៀបរាប់ពីការព្យាបាល និងការថែទាំ ជំងឺពងបែកនៅដៃ ជើង និងមាត់នៅផ្ទះ

៥. រៀបរាប់ពីវិធានការការពារជំងឺពងបែកនៅដៃ ជើង និងមាត់

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សា
- រូបភាពទំព័រទី ៦៤ និង ៦៦
- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីចម្លើយចូលរួម
- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត កន្រ្តៃ និងបង់ស្អិត។

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- សំណួរបំផុសគំនិត
- ពិភាក្សាក្រុមធំ

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖

ដោយផ្អែកលើបទពិសោធន៍របស់យើងកន្លងមក អ្នកទាំងអស់គ្នាបានយល់ដឹង អំពីអ្វីជាគ្រុនក្តៅ ប៉ុន្តែមានគ្រុនក្តៅខ្លះជាសញ្ញារបស់ជំងឺពងបែក ដៃ ជើងនិងមាត់ ។ ឥឡូវនេះ យើងចាប់ផ្តើមពិភាក្សាអំពី ជំងឺពងបែក ដៃ ជើងនិងមាត់ ដូច្នេះយើងអាចយល់អំពី របៀបការពារនៅពេលអនាគត។

**វត្ថុបំណងទី ១៖ កំណត់និយមន័យ ជំងឺពងបែក ដៃ ជើងនិងមាត់ រយៈពេល ២០ នាទី**

➢ សំណួរបំផុសគំនិត

**សំណួរ៖** តើអ្នកទាំងអស់ ឬអ្នកណាម្នាក់ធ្លាប់កើត ឬក៏ធ្លាប់ឮ ជំងឺពងបែកនៅដៃ ជើង និងមាត់ ឬទេ? តើអ្វីជាជំងឺពងបែកនៅដៃ ជើង និងមាត់?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីនិយមន័យជំងឺពងបែកនៅដៃ ជើង និងមាត់

**ចម្លើយចូលរួម៖**

ជាជំងឺឆ្លងដែលបង្កឡើងដោយវីរុស ច្រើនកើតមានចំពោះទារកនិងកុមារ ភាគច្រើនលើកុមារដែលមានអាយុតិចជាង១០ឆ្នាំ ជាពិសេស កុមារអាយុក្រោម៥ឆ្នាំ។ ជំងឺនេះស្តែង**ចេញជា គ្រុនក្តៅ ពងបែកនៅមាត់ និង មានពង កន្ទួលលើបាតដៃ បាតជើង និង កំប៉េះគូទ។**

**វត្ថុបំណងទី ២៖ ពន្យល់អំពីមូលហេតុដែលបង្កឱ្យមានជំងឺពងបែកនៅដៃ ជើង និងមាត់**

**រយៈពេល ៣០នាទី**

➢ **ពិភាក្សាក្រុមធំ**

**សំណួរបំផុសគំនិត**

**សំណួរ៖** ដូច្នេះ តើអ្នកទាំងអស់អាចប្រាប់ពីមូលហេតុអ្វីដែលបង្កឲ្យមានជំងឺពងបែកនៅដៃ ជើង និង មាត់?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីមូលហេតុបង្កឲ្យមានជំងឺពងបែកនៅដៃ ជើង និងមាត់

**ចម្លើយចូលរួម៖**

➢ ជំងឺពងបែក ដៃជើង និងមាត់ បង្កឡើងដោយ វីរុស កុកសាគី និង **អង់តេរ៉ូវីរុស ៧១** (EV71)

➢ ជំងឺពងបែក ដៃជើង និង មាត់ជាជំងឺឆ្លង ដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមការប៉ះពាល់ ផ្ទាល់ជាមួយ នឹងវត្ថុរាវ នៃផ្លូវដង្ហើម រួមមាន ទឹកមាត់ កំហាក ស្លេស និងសំបោរ ទឹករងៃដែលចេញពីពងបែក លាមកអ្នកជំងឺ។

➢ អ្នកជំងឺអាចចំលងខ្លាំងបំផុតក្នុងសប្តាហ៍ទី១។

➢ ជំងឺពងបែក ដៃជើង និងមាត់ មិនឆ្លងទៅ ឬ ឆ្លងមកពីសត្វ ឡើយ។

**តើយើងអាចឆ្លងជំងឺពងបែក ដៃជើង និង ក្នុងមាត់លើសពីមួយដងដែរ ឬ ទេ?**

អាច! ពីព្រោះជំងឺពងបែក ដៃជើង និង ក្នុងមាត់ បង្កឡើងដោយវីរុសផ្សេងៗគ្នា។ ការឈឺជំងឺនេះម្តងអាច បង្កឲ្យមាន ប្រព័ន្ធការពារខ្លួនទៅនឹងវីរុសតែមួយប្រភេទប៉ុណ្ណោះ ដូច្នេះយើងអាចឈឺម្តងទៀតប្រសិនបើ យើងឆ្លងវីរុសប្រភេទថ្មី មួយផ្សេងទៀត។

**វត្ថុបំណងទី ៣៖ រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺពងបែក ដៃជើង និងមាត់ រយៈពេល ២០នាទី**

- ពិភាក្សាក្រុមធំ
- បិតរូបភាពនេះមុខក្រុម៖









**សំណួរបំផុសគំនិត**

**សំណួរ៖** តើអ្នកទាំងអស់អាចប្រាប់ពីរោគសញ្ញាជំងឺពងបែកនៅដៃ ជើង និងមាត់ឬទេ មានអ្វីខ្លះ?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរោគសញ្ញាជំងឺពងបែកនៅដៃ ជើង និងមាត់

**ចម្លើយចូលរួម៖**

- o រយៈពេលគិតចាប់តាំងពីថ្ងៃឆ្លងវីរុសរហូតដល់ថ្ងៃចេញរោគសញ្ញាដំបូងជាទូទៅ ៣ ទៅ ៧ ថ្ងៃ។
- o រោគសញ្ញាដំបូង មាន គ្រុនក្តៅជាទូទៅមានរយៈពេលពី ១ថ្ងៃ ទៅ២ថ្ងៃ
- o ការហូបចុកថយចុះ អស់កំលាំង និង ជាញឹកញយឈឺបំពង់ក។
- o មួយឬពីរថ្ងៃបន្ទាប់ពីគ្រុនក្តៅ អ្នកជំងឺចាប់ផ្តើមឈឺក្នុងមាត់ ដោយមាន ចំនុចពណ៌ក្រហមតូចៗ ដែលចេញជាពង និងវិវត្តទៅជាដំបៅមានលើអណ្តាត អញ្ចាញ និង ផ្នែកខាងក្នុងនៃថ្ពាល់។ ស្បែកកន្ទួលមិនរមាស់ ស្នាមកន្ទួលឬ ពងបែកជាទូទៅមាននៅលើបាតដៃ និង បាតជើង ហើយក៏អាចមាននៅលើ កំប៉េះគូទ និង អវៈយវៈភេទ។
- o ជួនកាលអ្នកជំងឺ មានតែកន្ទួល ឬ ដំបៅក្នុងមាត់។
- o ក្នុងករណីធ្ងន់ធ្ងរ អ្នកជំងឺមានរោគសញ្ញាប្រព័ន្ធប្រសាទនិងផ្លូវដង្ហើមជាមួយគ្នា និងវិវត្តទៅរកការស្លាប់យ៉ាងឆាប់រហ័សបើគ្មានការព្យាបាលសមស្របទាន់ពេលវេលា។

**ចំនុចបំណងទី ៤៖ រៀបរាប់ពី ការព្យាបាល និងការថែទាំជំងឺពងបែក ដៃជើង និងមាត់ នៅផ្ទះ រយៈពេល ២០នាទី**

- ➢ **ពិភាក្សាក្រុមធំ**
- ➢ **ចម្លើយចូលរួម៖**

ជំងឺពងបែក ដៃជើង និងមាត់ មួយចំនួន អាចជាសះស្បើយក្នុងរយៈពេលពី៧ទៅ១០ថ្ងៃ **ប៉ុន្តែ មួយចំនួនទៀតអាចវិវត្តទៅជាសណ្ឋានធ្ងន់ធ្ងរ** ដែលតំរូវឲ្យមានការថែទាំព្យាបាលនៅមូលដ្ឋានសុខាភិបាល។

<u>**ការថែទាំព្យាបាលនៅផ្ទះ៖**</u>

- ❖ ឲ្យប៉ារ៉ាសេតាម៉ុល ដើម្បីបន្ថយ គ្រុនក្តៅ និង បំបាត់ការឈឺចុកចាប់
- ❖ ឲ្យ វីយ៉ូលេហ្សង់ស្យាន ដែលមានកំហាប់០.៥០% សម្រាប់លាបស្បែក និងកំហាប់០.២៥% សម្រាប់លាបភ្នាស់ខាងក្នុង
- ❖ មិនត្រូវប្រើថ្នាំ អាស្ពីរីន (aspirin) ដើម្បីបញ្ចុះកំដៅឡើយ។
- ❖ តាមដានជាប្រចាំរកគ្រុនក្តៅខ្លាំង សញ្ញាប្រព័ន្ធប្រសាទ និងសញ្ញាផ្លូវដង្ហើមក្នុងរយៈពេល ៧ថ្ងៃ
    - o សញ្ញាប្រព័ន្ធប្រសាទរួមមាន៖ សន្លឹមប្រកាច់កន្ត្រាក់រឹងដៃជើងឬទន់ដៃទន់ជើង
    - o សញ្ញាផ្លូវដង្ហើមរួមមាន៖ ពិបាកដកដង្ហើមឬដកដង្ហើមញាប់

**បើមានគ្រុនក្តៅខ្លាំង សញ្ញាប្រព័ន្ធប្រសាទ និងសញ្ញាផ្លូវដង្ហើម ត្រូវបញ្ជូនទៅមូលដ្ឋានសុខាភិបាលជាបន្ទាន់**

**ចំនុចបំណងទី ៥៖ រៀបរាប់ពីវិធានការការពារជំងឺពងបែក ដៃជើង និងមាត់ រយៈពេល ២០នាទី**

- ➢ ពិភាក្សាក្រុមធំ

**សំណួរ៖ តើជំងឺពងបែកដៃជើង និងក្នុងមាត់អាចការពារបានដែរឬទេ?** អាចបង្ការបាន

**សំណួរ៖ តើត្រូវធ្វើយ៉ាងណាដើម្បីការពារជំងឺពងបែកដៃជើងនិងក្នុងមាត់?**

- ➢ ត្រូវលាងសំអាតដៃអោយបានស្អាតជាប្រចាំ ជាមួយទឹកនិងសាប៊ូ ឬផេះ ពិសេសក្រោយប៉ះពាល់ជាមួយ នឹងវត្ថុរាវ នៃផ្លូវដង្ហើម រួមមាន ទឹកមាត់ កំហាក ស្លេស និងសំបោរ ទឹករងៃដែលចេញពី

ពងបែក លាមកអ្នកជំងឺ។

- ត្រូវលាងសំអាតដៃអោយបានស្អាត មុនពេលរៀបចំអាហារ មុនពេលបរិភោគ មុនបញ្ចុកចំណីដល់ទារក ឬ កុមារ ក្រោយចេញពីបង្គន់ និងក្រោយប្តូរទ្រនាប់ គូទទារក ឬជូតសំអាតរាងកាយកុមារ។ លាងសំអាតផ្ទៃនិងរបស់ដែលប្រលាក់ដោយទឹកនិងសាប៊ូ។
- ជៀសវាងការប៉ះពាល់ស្និតស្នាល(ថើប អោប ប្រើប្រាស់សម្ភារៈសំរាប់ហូបចុក រួមគ្នា។ល។)
- ត្រូវបន្ត ផ្តល់អាហារដែលមានសារជាតិចិញ្ចឹមច្រើន និង ទឹកស្អាតដល់កុមារ។ ប្រើស្លាបព្រា និងចានដាច់ដោយឡែកសំរាប់កុមារនិមួយៗ។
- អ្នកមើលថែទាំកុមារតូចៗត្រូវមានអនាម័យផ្ទាល់ខ្លួនល្អ។

**សង្ខេបមេរៀនឡើងវិញ:**

- អ្នកសម្របសម្រួលសង្ខេបខ្លឹមសារមេរៀនតាមវត្ថុបំណងនីមួយៗ

**ការវាយតម្លៃ:**

**សំណួរ:**

1. តើការថែទាំជាមូលដ្ឋានសម្រាប់កុមារមានគ្រុនក្តៅនៅផ្ទះមានអ្វីខ្លះ?
2. ចូររៀបរាប់សញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាពអ្វីខ្លះ ដែលអ្នកថែទាំត្រូវនាំកុមារទៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យ ដែលនៅជិតជាងគេជាបន្ទាន់ ចំពោះកុមារមានគ្រុនក្តៅ?



ត្រូវបញ្ជូនកុមារទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យជាបន្ទាន់ក្នុងករណី កុមារមានរោគសញ្ញា ឬអាការៈណាមួយដូចខាងលើ

3. តើការព្យាបាល ថែទាំជាមូលដ្ឋានសម្រាប់កុមារមានជំងឺពងបែកដៃជើងនិងមាត់នៅផ្ទះមានអ្វីខ្លះ?
4. តើអ្វីខ្លះដែលត្រូវនាំកុមារមានជំងឺពងបែកដៃជើងនិងមាត់ទៅមណ្ឌលសុខភាព?

**សង្ខេបម៉ូឌុល**

អ្នកសម្របសម្រួលសង្ខេបខ្លឹមសារមេរៀនតាមវត្ថុបំណងនិមួយៗ

**គ្រុនក្ដៅ**

១. កំណត់និយមន័យគ្រុនក្ដៅ
២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានគ្រុនក្ដៅ
៣. រៀបរាប់ពីរោគសញ្ញា ឬអាការៈគ្រុនក្ដៅ
៤. រៀបរាប់ពីវិធានការណ៍ការពារគ្រុនក្ដៅ
៥. រៀបរាប់ពីការព្យាបាល និងការថែទាំគ្រុនក្ដៅនៅផ្ទះ
៦. អនុវត្តវិធីផ្សេងៗ ដើម្បីបញ្ចុះកំដៅកុមារមានគ្រុនក្ដៅ
៧. ពិភាក្សាអំពីសញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព និង ពេលណាដែលត្រូវបញ្ជូនកុមារមានគ្រុនក្ដៅ ទៅមណ្ឌលសុខភាព

**ជំងឺពងបែកដៃជើងនិងមាត់**

១. កំណត់និយមន័យជំងឺពងបែកនៅដៃ ជើង និងមាត់
២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺពងបែកនៅដៃ ជើង និងមាត់
៣. រៀបរាប់ពីរោគសញ្ញា ឬអាការៈជំងឺពងបែកនៅដៃ ជើងនិងមាត់
៤. រៀបរាប់ពីវិធានការការពារជំងឺពងបែកនៅដៃ ជើង និងមាត់
៥. រៀបរាប់ពីការព្យាបាល និងការថែទាំ ជំងឺពងបែកនៅដៃ ជើង និងមាត់នៅផ្ទះ
៦. ពិភាក្សាអំពីសញ្ញាដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព និង ពេលណាដែលត្រូវបញ្ជូនកុមារមានជំងឺពងបែក ដៃជើង និងមាត់ ទៅមណ្ឌលសុខភាព

**មេរៀនទី៤៖ សង្ខេបម៉ូឌុល និងការធ្វើតេស្តក្រោយពេលសិក្សា រយៈពេល ៣៥នាទី**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច ៖

១. រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ
២. វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយពេលសិក្សា

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ មានសរសេរពីវត្ថុបំណងម៉ូឌុល
- ក្រដាសផ្ទាំងធំ មានសារគន្លឹះសម្រាប់ម៉ូឌុលនេះ
- ហ្វឺតសម្រាប់សរសេរ, បង់ស្អិត
- បញ្ជីសំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

**វិធីសាស្ត្របង្រៀន៖**

- ពិភាក្សាក្រុម

- តេស្តក្រោយវគ្គសិក្សា

**ជំហានសកម្មភាព៖**

**បង្ហាញពីវគ្គបំណងរួម៖**

**សេចក្តីផ្តើម៖** អ្នកសម្របសម្រួលពន្យល់ថា នេះគឺជាមេរៀនចុងក្រោយសម្រាប់ម៉ូឌុលនេះ។

**វគ្គបំណងទី១៖ រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ (១០នាទី)**

**ពិភាក្សាក្រុម**

- អ្នកសម្របសម្រួល ដឹកនាំសិក្ខាកាមពិភាក្សាពីចំណុចសង្ខេប និងសារគន្លឹះសម្រាប់ម៉ូឌុលនេះ។ អ្នក សម្របសម្រួលត្រូវបិទសារគន្លឹះនៅលើក្រដាសផ្ទាំងធំ ដើម្បីឱ្យសិក្ខាកាមមើល និងអាន។
- បន្ទាប់មក អ្នកសម្របសម្រួល សួរសិក្ខាកាមថា តើមានសំណួរអ្វីទេ?

**វគ្គបំណងទី ២៖ វាយតម្លៃចំណេះដឹងតាមរយៈការធ្វើតេស្តក្រោយពេលសិក្សា (២៥នាទី)**

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថា មុននឹងយើងបញ្ចប់ម៉ូឌុលនេះ យើងនឹងធ្វើតេស្តក្រោយពេលសិក្សាខ្លី មួយ។ តេស្តនេះគឺដូចគ្នានឹងតេស្តមុនពេលសិក្សាដែលអ្នកទាំងអស់គ្នាបានធ្វើមុនចាប់ផ្តើមម៉ូឌុលនេះដែរ។ ការធ្វើតេស្តបែបនេះ គឺដើម្បីវាស់ពីចំណេះដឹងសិក្ខាកាមនៅមុននឹងក្រោយពេលសិក្សា ដើម្បីចង់ដឹងថា តើអ្នក ទាំងអស់គ្នា បានទទួលចំណេះដឹងប៉ុណ្ណាពីវគ្គនេះ។ ដូច្នេះសូមកុំព្រួយបារម្ភ ប្រសិនបើអ្នកមិនចេះសំណួរណាមួយនោះ។

បន្ទាប់មក ចែកសំណួរតេស្តដល់សិក្ខាកាម។

ក្រោយពីសិក្ខាកាមបានធ្វើតេស្តក្រោយពេលសិក្សាចប់ អ្នកសម្របសម្រួលត្រូវបូកសរុបចម្លើយ ហើយប្រៀប-ធៀបនឹងលទ្ធផលតេស្តមុនពេលសិក្សា។

**សំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា**

សំណួរ "ត្រូវ ឬ ខុស" (សំណួរត្រូវ ត្រូវបានបង្ហាញក្នុងប្រអប់ខ្មៅ)

១. ពេលកូនរបស់លោក អ្នកមានជំងឺគ្រុនក្តៅ អ្នកត្រូវធ្វើអ្វីខ្លះ?

☐ ស្លៀកពាក់នូវសម្លៀកបំពាក់ក្រាស់ៗ ដើម្បីកុំអោយរងារ

☐ ត្រូវនាំកុមារទៅមណ្ឌលសុខភាពឬមន្ទីរពេទ្យ

☐ ត្រូវដោះខោអាវកុមារចេញ រួចជូតស្អំនឹងកន្សែងទទឹក ពិសេសនៅជុំវិញក ក្នុងក្លៀក និងម្តុំក្រលៀន

☐ ត្រូវតមអាហារ និងជាតិទឹកនានា

២. តើសញ្ញាអ្វីខ្លះដែលត្រូវបញ្ជូនកុមារមានគ្រុនក្តៅជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត?

- ☐ ត្រូវបញ្ជូនរាល់កុមារមានគ្រុនក្តៅទាំងអស់ទៅមណ្ឌលសុខភាពឬមន្ទីរពេទ្យ
- ☐ បៅមិនបាន ផឹកមិនបានឬ បានតិចតួច
- ☐ ក្អួតគ្មានសល់ក្រោយពេលបៅឬញាំ
- ☐ សន្លឹម ឬបាត់ស្មារតី
- ☐ មានសញ្ញាចេញឈាមណាមួយ
- ☐ ចង្វាក់ដង្ហើម ញាប់ ឬ
- ☐ ប្រកាច់

៣. ចូររៀបរាប់ពីវិធីសាស្ត្របញ្ចុះកំដៅដោយស្អំទឹក?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

.....................................................................................................................................

| | | |
|---|---|---|
| ៤. ជំងឺពងបែកនៅដៃ ជើង និងមាត់ ជាជំងឺឆ្លងដែលបង្កឡើងដោយវីរុស ច្រើនកើតមានចំពោះទារកនិងកុមារ ភាគច្រើនលើកុមារដែលមានអាយុតិចជាង១០ឆ្នាំ ជាពិសេស កុមារអាយុក្រោម៥ឆ្នាំ។ ជំងឺនេះស្តែង**ចេញជា គ្រុនក្តៅ ពងបែកនៅមាត់ និង មានពង កន្ទួលលើបាតដៃ បាតជើង និង កំប៉េះគូទ។** | ត្រូវ | ខុស |
| ៥. ជំងឺពងបែក ដៃជើង និង ក្នុងមាត់ជាជំងឺឆ្លងដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមការប៉ះពាល់ ផ្ទាល់ជាមួយ នឹងវត្ថុរាវ នៃផ្លូវដង្ហើម រួមមាន ទឹកមាត់ កំហាក ស្លេស និងសំបោរ ទឹករងៃដែលចេញពីពងបែក លាមកអ្នកជំងឺ | ត្រូវ | ខុស |

៦.រោគសញ្ញា ឬអាការៈជំងឺពងបែក ដៃជើង និងមាត់មានអ្វីខ្លះ? សូមគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ (ចម្លើយត្រូវ ច)

ក. ដំបូងគ្រុនក្តៅជាទូទៅមានរយៈពេលពី ១ថ្ងៃ ទៅ២ថ្ងៃ

ខ. ការហូបចុកថយចុះ អស់កំលាំង និង ជាញឹកញយឈឺ បំពង់ក

គ. មួយឬពីរថ្ងៃបន្ទាប់ពីគ្រុនក្តៅ អ្នកជំងឺចាប់ផ្តើមឈឺក្នុងមាត់ ដោយមាន ចំនុចពណ៌ក្រហមតូចៗ ដែលចេញជាពង និងវិវត្តទៅជាដំបៅមានលើអណ្តាត អញ្ចាញ និង ផ្ទៃកខាងក្នុងនៃថ្ពាល់។

ឃ. ស្បែកកន្ទួលមិនរមាស់ ស្នាមកន្ទួលឬ ពងបែកជាទូទៅមាននៅលើបាតដៃ និង បាតជើងហើយក៏អាចមាននៅលើ កំប៉េះគូទ និង អវៈយវៈភេទ។។

ង. ជួនកាលអ្នកជំងឺ មានតែកន្ទួល ឬ ដំបៅក្នុងមាត់។

ច. ក្នុងករណីធ្ងន់ធ្ងរ អ្នកជំងឺមានរោគសញ្ញាប្រព័ន្ធប្រសាទនិងផ្លូវដង្ហើមជាមួយគ្នា និងវិវត្តទៅរកការស្លាប់យ៉ាងឆាប់រហ័សបើគ្មានការព្យាបាលសមស្របទាន់ពេលវេលា។

ឆ.ទាំងអស់ខាងលើ

៧.ដើម្បីការពារជំងឺពងបែក ដៃជើង និងមាត់ តើត្រូវធ្វើដូចម្តេច? សូមគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ (ចម្លើយត្រូវ ង)

ក. ត្រូវលាងដៃអោយអោយបានស្អាតជាប្រចាំ ជាមួយទឹកនិងសាប៊ូ ឬផេះ ពិសេសក្រោយប៉ះពាល់ ជាមួយ នឹងវត្ថុរាវ នៃផ្លូវដង្ហើម រួមមាន ទឹកមាត់ កំហាក ស្លេស និងសំបោរ ទឹករងៃដែលចេញពីពងបែក លាមកអ្នកជំងឺ។

ខ. ត្រូវលាងសំអាតដៃអោយបានស្អាត មុនពេលរៀបចំអាហារ មុនពេលបរិភោគ មុនបញ្ចុកចំណីដល់ទារក ឬ កុមារ ក្រោយចេញពីបង្គន់ និងក្រោយប្តូរទ្រនាប់ គូទទារក ឬជូតសំអាតរាងកាយកុមារ។ លាងសំអាតផ្ទៃនិងរបស់ដែលប្រលាក់ដោយទឹកនិងសាប៊ូ។

គ. ជៀសវាងការប៉ះពាល់ស្និតស្នាល(ថើប អោប ប្រើប្រាស់សម្ភារៈសំរាប់ហូបចុក រួមគ្នា។ល។)ជាមួយកុមារដែលមានជំងឺពងបែកដៃជើង និងក្នុងមាត់ អាចកាត់បន្ថយការឆ្លងផងដែរ។

ឃ. ផ្តល់អាហារដែលមានសារជាតិចិញ្ចឹមច្រើននិង ទឹកស្អាតដល់កុមារ។ប្រើស្លាបព្រា និងចានដាច់ដោយឡែកសំរាប់កុមារនិមួយៗ។

ង. អ្នកមើលថែទាំកុមារតូចៗត្រូវមានអនាម័យផ្ទាល់ខ្លួនល្អ។

ច.ទាំងអស់ខាងលើ

៨. តើត្រូវធ្វើអ្វីខ្លះដើម្បី ព្យាបាល និងការថែទាំជំងឺពងបែក ដៃជើង និងមាត់ នៅផ្ទះ ? ហ៊ុំចម្លើយណាត្រឹមត្រូវ

ក. ឲ្យប៉ារ៉ាសេតាម៉ុល ដើម្បីបន្ថយ គ្រុនក្តៅ និង បំបាត់ការឈឺចុកចាប់

ខ. ជូត ឬលាប វីយ៉ូលេហ្សង់ស្យាន កន្លែងមានពងទឹក ឬដំបៅ

គ. មិនត្រូវប្រើថ្នាំ អាស្ពីរីន (aspirin) ដើម្បីបញ្ចុះកំដៅឡើយ

ឃ. ទាំងអស់ខាងលើ

៨. តើពេលណាដែលត្រូវយកកុមារមាន ជំងឺពងបែក ដៃជើង និងមាត់ មូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតជាបន្ទាន់? ហ៊ុំចម្លើយណាត្រឹមត្រូវ

ក. គ្រុនក្តៅខ្លាំង

ខ. សញ្ញាប្រព័ន្ធប្រសាទដូចជាសន្លឹមប្រកាច់កន្ត្រាក់រឹងដៃជើងឬទន់ដៃទន់ជើង

គ. សញ្ញាផ្លូវដង្ហើមដូចជាពិបាលដកដង្ហើមឬដកដង្ហើមញាប់។

ឃ. ទាំងអស់ខាងលើ

# ម៉ូឌុលទី៤

## ជំងឺផ្តាសាយ

# សៀវភៅបណ្តុះបណ្តាលក្រុមគ្រប់គ្រងភូមិ

## ម៉ូឌុលទី៤ ជំងឺផ្តាសាយ

| ចំណងជើងមេរៀន | វត្ថុបំណងនៃការសិក្សា | រយៈពេល* |
|---|---|---|
| ១.ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា | ១– រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ<br>២– អនុវត្តន៍ការសាកល្បងមុនការសិក្សា | ៤០នាទី |
| ២. ជំងឺផ្តាសាយ | ១. កំណត់រោគសញ្ញា និងអាការៈនៃ ជំងឺផ្តាសាយ តាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល<br>២. ពិភាក្សាអំពី មូលហេតុដែលបង្កឱ្យមានជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល<br>៣. រៀបរាប់ពី ការព្យាបាល និងការថែទាំជំងឺផ្តាសាយតាមរដូវកាលនៅផ្ទះ<br>៤. រៀបរាប់ពីសញ្ញាជំងឺផ្តាសាយតាមរដូវកាល ដែលតម្រូវឱ្យមាន ការថែទាំនៅមូលដ្ឋានសុខាភិបាល<br>៥. រៀបរាប់ពី វិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺផ្តាសាយបក្សី<br>៦. រៀបរាប់ពី វិធានការដែលត្រូវអនុវត្តពេលមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល<br>៧. រៀបរាប់ពី វិធានការការពារជំងឺផ្តាសាយតាមរដូវកាល និងផ្តាសាយបក្សី | ៦ម៉ោង ៥០នាទី |
| ៣. ការសង្ខេប និងការសាកល្បងក្រោយសិក្សា | ១– រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ<br>២– អនុវត្តការសាកល្បងក្រោយការសិក្សា | ៥០នាទី |
| **សរុប** | | **៨ម៉ោង ២០នាទី** |

* ថ្ងៃបណ្តុះបណ្តាលនិមួយៗមានរយៈពេលសរុបម៉ោង (ព្រឹកម៉ោង៨ព្រឹក ដល់៥ល្ងាច)

- រយៈពេលបណ្តុះបណ្តាល៥ម៉ោង (ពេលព្រឹក៣ម៉ោង និងរសៀល២ម៉ោង)
- សម្រាក ២ម៉ោងសម្រាប់អាហារថ្ងៃត្រង់និង១ម៉ោងសម្រាប់អាហារសម្រន់ (ព្រឹក៣០នាទី និងរសៀល៣០នាទី)

# សេចក្តីណែនាំកម្មវិធីសិក្សា

## ម៉ូឌុលទី ៤៖ អំពីជំងឺផ្តាសាយ

### មេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងដំបូង រយៈពេលសរុប ៤0នាទី

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១- រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ | – គោលបំណងនៃម៉ូឌុលទី ៤ | – បាឋកថា | – ផ្ទាំងក្រដាសធំ ដែលមាន សរសេរអំពីគោលបំណង នៃម៉ូឌុលនេះ | ១០ នាទី | – សំណួរ-ចម្លើយ |
| ២- អនុវត្តការសាកល្បងមុនការសិក្សា | ការសាកល្បងមុនការសិក្សា | ការសាកល្បងមុនការសិក្សា | ឯកសារសាកល្បងមុន ការសិក្សា<br>ក្តាខៀន ហ្វឺត<br>ក្រដាសផ្ទាំងធំ | ៣០ នាទី | ការត្រួតពិនិត្យ |

### មេរៀនទី ២៖ ជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល រយៈពេលសរុប៦ម៉ោង៥0នាទី

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. កំណត់រោគសញ្ញា និងអាការៈនៃ ជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល | – និយមន័យជំងឺ ផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកលនិងអាការៈ ជំងឺ | – សំណួរបំផុសគំនិត | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួមនិមួយៗ<br>– រូបភាពទំព័រទី៨២-៨៣<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ | ៩០ នាទី | – សំណួរ-ចម្លើយ |

| | | | | | |
|---|---|---|---|---|---|
| ២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺផ្កាសាយតាមរដូវកាល ផ្កាសាយបក្សី និងផ្កាសាយសកល | – មូលហេតុនិងសារគន្លឹះដែលបង្កឲ្យមានជំងឺផ្កាសាយតាមរដូវកាល ផ្កាសាយបក្សី និងផ្កាសាយសកល | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួមនិមួយៗ<br>– រូបភាពទំព័រទី៨៥ ៨៦ ៨៧ ៨៩<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ១១០ នាទី | – ចម្លើយតបពីក្រុមពិភាក្សា |
| ៣. រៀបរាប់ពីការព្យាបាល និងការថែទាំជំងឺផ្កាសាយតាមរដូវកាលនៅផ្ទះ | – វិធីព្យាបាល និង សារគន្លឹះសំខាន់ព្យាបាល<br>– និងថែទាំជំងឺផ្កាសាយតាមរដូវកាលនៅផ្ទះ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួមនិមួយៗ<br>– រូបភាពទំព័រទី៩០ | ៩០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៤. រៀបរាប់ពី សញ្ញា ជំងឺផ្កាសាយតាមរដូវកាល ដែលតម្រូវឱ្យមាន ការថែទាំនៅមូលដ្ឋានសុខាភិបាល | – ស្គាល់សញ្ញាជំងឺផ្កាសាយតាមរដូវកាលដែលតម្រូវឱ្យមាន ការថែទាំនៅមូលដ្ឋានសុខាភិបាល | – ការបំផុសគំនិត | – ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួមនិមួយៗ | ៤០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ៥. រៀបរាប់ពី វិធានការ ដែលត្រូវអនុវត្ត ពេលជួបករណីសង្ស័យ ថាមានជំងឺផ្តាសាយបក្សី | – ដឹងពី វិធានការ ដែលត្រូវអនុវត្ត ពេលជួបករណីសង្ស័យ ថាមានជំងឺផ្តាសាយបក្សី | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួមនិមួយៗ<br>– រូបភាពទំព័រទី៩២<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ២០ នាទី | – សំណួរ-ចម្លើយ<br>ចម្លើយតបពីក្រុមពិភាក្សា |
| ៦៖ រៀបរាប់ពី វិធានការ ដែលត្រូវអនុវត្ត ពេលមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល | – ដឹងពី វិធានការ ដែលត្រូវអនុវត្ត ពេលមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល | – ពិភាក្សាក្រុមធំ | – ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួមនិមួយៗ<br>– រូបភាពទំព័រទី៩៣ | ២០ នាទី | – សំណួរ-ចម្លើយ<br>ចម្លើយតបពីក្រុមពិភាក្សា |
| ៧. រៀបរាប់ពីវិធានការ ការពារជំងឺ ផ្តាសាយតាមរដូវកាល និង ផ្តាសាយបក្សី | – វិធានការ ការពារនិងសារគន្លឹះ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្រដាសធំផ្ទាំងមានសរសេរ អំពីចម្លើយចូលរួមនិមួយៗ<br>– រូបភាពទំព័រទី ៩៥ ៩៦ ៩៧ ៩៨ ៩៩ និង១០០<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ៩០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

## មេរៀនទី ៣៖ ការសង្ខេប និងការសាកល្បងក្រោយសិក្សា រយៈពេលសរុប ៥0នាទី

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១- រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ | ដំណោះស្រាយបញ្ហានានា និងសំណូមពររបស់សិក្ខាកាម | – ពិភាក្សាក្រុម | – ផ្ទាំងក្រដាសធំ មានសរសេរ អំពីវត្ថុបំណងការសិក្សា<br>– ក្រដាសផ្ទាំងធំ<br>– ក្តាខៀន ហ្វឺត | ២០ នាទី | – សំណួរ-ចម្លើយ |
| ២- អនុវត្តការសាកល្បងក្រោយការសិក្សា | ការសាកល្បងក្រោយការសិក្សា | សាកល្បងក្រោយការសិក្សា | ឯកសារសាកល្បងក្រោយការសិក្សា | ៣0 នាទី | ការត្រួតពិនិត្យ |

# គម្រោងមេរៀន

## ចំណុចជើងមេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងមុនការសិក្សា រយៈពេល ៤០នាទី

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ

២. អនុវត្តន៍ការសាកល្បងមុនការសិក្សា។

**សម្ភារៈជំនួយបង្រៀន៖**

- ផ្ទាំងក្រដាសធំ ដែលមានសរសេរអំពីវត្ថុបំណងសិក្សាថ្ងៃនេះផងដែរ
- ឯកសារសំណួរសាកល្បងមុនការសិក្សា ដែលបានថតចម្លងរួច សម្រាប់សិក្ខាកាមនីមួយៗ

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- ការសាកល្បងមុនការសិក្សា

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖ សូមស្វាគមន៍ម្តងទៀត ចំពោះកម្មវិធីបណ្តុះបណ្តាលម៉ូឌុលទី៤របស់យើង។ យើងសង្ឃឹមថា អ្នកទទួលបាន នូវបទពិសោធន៍ល្អៗច្រើន កាលពីម៉ូឌុលមុនៗដូចជាអ្នកបានសាកល្បង នូវសកម្មភាពជាក្រុមគ្រប់គ្រងភូមិ របស់អ្នក។ យើងនឹងពិភាក្សាគ្នាអំពីបទពិសោធន៍ខ្លះៗរបស់អ្នកនៅថ្ងៃនេះ។ យើងពេញចិត្តនឹងស្តាប់យោបល់ និងគំនិតផ្សេងៗរបស់អ្នកណាស់។

នៅក្នុងការបណ្តុះបណ្តាល លើកមុនៗកន្លងមក យើងបានជជែកគ្នាអំពីជំងឺរាក គ្រុនក្តៅ ជំងឺពងបែកដៃជើងនិងមាត់ មូលហេតុ របៀបព្យាបាល ការស្វែងរកការថែទាំពេលមានសញ្ញាគ្រោះថ្នាក់ និងការការពារ ។ លើកនេះយើងនិង ពិភាក្សាគ្នាអំពីជំងឺផ្តាសាយ តើអ្នកយល់ឃើញយ៉ាងណាដែរ?

**វត្ថុបំណងទី ១៖ រៀបរាប់ពីគោលបំណង នៃការបណ្តុះបណ្តាលថ្ងៃនេះ**

➢ បាឋកថា

ថ្ងៃនេះយើងនឹងរៀនម៉ូឌុលថ្មីមួយទៀត គឺជំងឺផ្តាសាយ ដែលតែងកើតមានជាញឹកញាប់ក្នុងអំឡុងខែវិច្ឆិកា ដល់ខែមេសា ។ ដូច្នេះ គោលបំណងរបស់ យើងនៅថ្ងៃនេះគឺ ៖

- ពិភាក្សាអំពីជំងឺផ្តាសាយតាមរដូវកាល
- ពិភាក្សាអំពីជំងឺផ្តាសាយបក្សី
- ពិភាក្សាអំពីផ្តាសាយសកល
- ជជែកអំពីមធ្យោបាយផ្សេងៗក្នុងការថែទាំពេលមានជំងឺទាំងនេះ

- ពិភាក្សាអំពីសញ្ញាគ្រោះថ្នាក់ នៃជំងឺផ្តាសាយតាមរដូវកាលដែលបង្ហាញថាត្រូវស្វែងរកសេវាថែទាំ
- ពិភាក្សាត្រូវធ្វើអ្វីខ្លះ នៅពេលយើងឃើញសញ្ញាគ្រោះថ្នាក់ទាំងនេះ។
- ពិភាក្សាត្រូវរាយការណ៍យ៉ាងដូចម្តេចពេលជួប ករណីសង្ស័យជំងឺផ្តាសាយ
- ពិភាក្សាថា តើត្រូវអនុវត្តអនាម័យល្អនៅផ្ទះរបស់យើងដូចម្តេចដើម្បីការពារកុំឲ្យមានជំងឺផ្តាសាយតាមរដូវកាល

**វត្ថុបំណងទី ២៖ អនុវត្តការសាកល្បងមុនការសិក្សា**

➢ ការសាកល្បងមុនការសិក្សា

មុនពេលយើងចាប់ផ្តើម យើងចង់ឱ្យអ្នកទាំងអស់គ្នា ធ្វើសំណួរសាកល្បងមួយខ្លីៗ។ ប្រហែលជាអ្នកនៅចាំ បានថា កាលពីលើកមុនសំណួរសាកល្បងនេះ នឹងជួយអ្នកសម្របសម្រួលឱ្យរកឃើញ នូវវិធីសាស្រ្តល្អបំផុតដែលជួយ ដល់ការរៀនសូត្រនៅក្នុងវគ្គនេះ។ សូមកុំបារម្ភ ប្រសិនបើអ្នកមិនដឹងរាល់ចម្លើយទាំងអស់។ គ្រាន់តែសាកល្បង ឆ្លើយឱ្យបានល្អតាមដែលអាចធ្វើបាន។ មុនពេលយើងចាប់ផ្តើម តើអ្នកមានសំណួរអ្វីទេ?

១. ចែកសំណួរសាកល្បងមុនការសិក្សាដល់សិក្ខាកាមម្នាក់មួយច្បាប់ និងសុំឱ្យពួកគាត់ធ្វើរៀងៗខ្លួន។

២. រក្សាទុកពិន្ទុនេះដើម្បីប្រៀបធៀប ជាមួយនឹងពិន្ទុសាកល្បងក្រោយការសិក្សា។

**សំណួរសាកល្បងមុន និងក្រោយការសិក្សា**

សំណួរត្រូវ ឬ ខុស (ចម្លើយត្រឹមត្រូវ គឺនៅក្នុងប្រអប់ពណ៌ខ្មៅ

| | | |
|---|---|---|
| ១. ជំងឺផ្តាសាយជាជំងឺធម្មតាដែលតែងកើតមានជាញឹកញាប់តាមរដូវកាល | ត្រូវ | ខុស |
| ២. កុមារមានគ្រុនផ្តាសាយ និង ក្អក តែងជួបញឹកញាប់ ប៉ុន្តែជួនកាលវាអាចវិវត្តទៅជាធ្ងន់ធ្ងរ ដែលអាចមានគ្រោះថ្នាក់ដល់អាយុជីវិត បើពុំព្យាបាលឱ្យបានត្រឹមត្រូវ។ | ត្រូវ | ខុស |
| ៣. រាល់ជំងឺទាំងអស់របស់កុមារទាំងអស់អាចព្យាបាលនៅផ្ទះ ដោយមានប្រសិទ្ធិភាពបំផុត និងការយកកុមារទៅមណ្ឌលសុខភាពពុំចាំបាច់ទេ។ | ត្រូវ | ខុស |
| ៤. ជំងឺផ្តាសាយបក្សី គឺជាជំងឺផ្តាសាយមួយ ដែលជាធម្មតាចំលងរវាងសត្វបក្សីឈឺទៅបក្សីផ្សេងទៀត ប៉ុន្តែជួនកាល វាអាចចំលងពីបក្សីមកមនុស្សនាំឲ្យកើតផ្តាសាយបក្សីលើមនុស្ស | ត្រូវ | ខុស |
| ៥. ជំងឺផ្តាសាយបក្សីលើមនុស្ស ជាជំងឺធ្ងន់ធ្ងរ ដែលតំរូវឲ្យមានការ ធ្វើការព្យាបាលនៅមន្ទីរពេទ្យ។ | ត្រូវ | ខុស |
| ៦. ប្រសិនមានមាន់ទាឈឺឬងាប់ត្រូវរាយការណ៍ជាបន្ទាន់តាមទូរស័ព្ទ៖ ០១២ ២១៤ ៩៧០ ឬ០១២ ៨៣៣ ៧៩៥ | ត្រូវ | ខុស |
| ៧.បើសង្ស័យថានរណាម្នាក់មានជំងឺផ្តាសាយបក្សីត្រូវបញ្ជូនអ្នកជំងឺទៅជួបគ្រូពេទ្យជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតដើម្បីពិនិត្យព្យាបាលឱ្យទាន់ពេលវេលា ឬទូរស័ព្ទទៅលេខ៖ ១១៥ ឬ០១២ ៤៨៨ ៩៨១ ឬ០៨៩ ៦៦៩ ៥៦៧។ | ត្រូវ | ខុស |

| | | |
|---|---|---|
| ៨. ក្រុមគ្រប់គ្រងភូមិ អាចជួយប្រជាជននៅក្នុងភូមិរបស់ខ្លួនសង្គ្រោះជីវិតរបស់មនុស្សគ្រប់វ័យ បើពួកគាត់បានទទួលការបណ្ដុះបណ្ដាល អំពីសញ្ញាគ្រោះថ្នាក់ និងសញ្ញាតម្រូវឱ្យបញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាព។ | ត្រូវ | ខុស |

៩៖ តើអ្នកអាចធ្វើអ្វីដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លង វីរុសហាស់ប្រាំអិនមួយ? ចម្លើយ ឃ .

ក.កុំ លេងជាមួយ ឬ ប៉ះពាល់បសុបក្សី ឬ ចូលទៅទីកន្លែងដែលមានមេរោគផ្ដាសាយបក្សីសាយភាយដោយមិនមានវិធានការការពារជាមុន (ប៉ះពាល់ជាមួយបក្សីស្រុក ឬព្រៃ ឈឺ ឬស្លាប់ដោយ កាន់ សំលាប់ បោចរោម កាប់សាច់ ធ្វើម្ហូបអាហារ)

ខ.កុំបរិភោគផលិតផលសាច់ឬស៊ុតបសុបក្សី ដែលចំអិនមិនឆ្អិនល្អ

គ.កុំប៉ះពាល់ជាមួយ អ្នកជំងឺផ្ដាសាយបក្សី ដោយមិនមានវិធានការការពារជាមុន

ឃ. ទាំងអស់ខាងលើ

១០. តើត្រូវធ្វើដូចម្តេចដើម្បីការពារខ្លួនអ្នក ប្រសិនជាអ្នកប៉ះពាល់ជាមួយបសុបក្សី ឬ សត្វស្លាប?ចម្លើយ ឃ

ក. លាងសម្អាតដៃជាមួយសាប៊ូ ឬផេះឲ្យបានញឹកញាប់

ខ.តាមដានមើលមានគ្រុនក្ដៅលើសពី៣៨ឬទេ?

គ. មានក្អក ឬពិបាកដកដង្ហើម

ឃ. បើមានសញ្ញា ក ខ និងគ ត្រូវទៅមូលដ្ឋានសុខាភិបាលជាបន្ទាន់។

១១. តើត្រូវធ្វើដូចម្តេចដើម្បីរៀបចំនិងបរិភោគ សាច់ឬស៊ុតបសុបក្សី ឬ សត្វស្លាប? (ចម្លើយ៖ ង)

ក. ប្រើក្រម៉ាឬម៉ាស ដើម្បីខ្ទប់មាត់ឬច្រមុះមុនពេលយើងប៉ះពាល់មាន់ទា

ខ. ស្រុះមាន់ទានឹងទឹកក្ដៅមុនបោចរោម

គ. ប្រមូលរោមមាន់ទានិងកាកសំណល់ផ្សេងទៀតយកទៅកប់ឬដុតចោល .

ឃ. លាងសំអាតដៃនិងរបស់របរប្រើប្រាស់ដូចជាចាន កាំបិត ដែលប្រើប្រាស់រួចជាមួយផេះឬសាប៊ូឬផេះឲ្យស្អាតត្រឹមត្រូវ។

ង. ទាំងអស់ខាងលើ

១២. ក្នុងអំឡុងមានការរាតត្បាតប្រសិនជាមានបសុបក្សី ឬ មាន់ទាងាប់តើយើងអាចយកមកធ្វើម្ហូបបានឬទេ? (ចម្លើយ៖ ខ)

ក. បាទ/ចាស

ខ. ទេ

១៣.តើត្រូវធ្វើដូចម្តេចប្រសិនជាអ្នកប៉ះជាមួយលាមកបសុបក្សី ក្នុងតំបន់មានឆ្លងជំងឺ និងធ្លាក់ខ្លួនឈឺ (ចម្លើយ៖ ក និង ឃ)

ក.ទៅពិគ្រោះជាមួយគ្រូពេទ្យជាបន្ទាន់ឬទូរស័ព្ទទៅលេខ៖ ១១៥ ឬ០១២ ៨៨៨ ៩៨១ ឬ០៨៩ ៦៦៩ ៥៦៧។

ខ.ព្យាបាលដោយខ្លួនឯង

គ. ទិញថ្នាំក្នុងភូមិ

ឃ. ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតផ្ទះជាបន្ទាន់

១៤. គូសរង្វង់ជុំវិញសញ្ញាគ្រោះថ្នាក់ របស់កុមារដែលឈឺធ្ងន់ ដែលមានន័យថាកុមារនោះត្រូវព្យាបាលនៅ មូលដ្ឋានសុខាភិបាល។ (ចម្លើយ៖ ក និង ខ)

ក. កុមារពុំអាចញាំ ឬ ផឹក ឬ បៅដោះបាន

ខ. កុមារពិបាកដកដង្ហើម

គ. កុមារក្តៅខ្លួនមធ្យមរយៈពេល១ថ្ងៃ

១៥. គូសរង្វង់ជុំវិញកន្លែង២ ដែលទីនោះក្រុមគ្រប់គ្រងភូមិអាចទទួលបាននូវព័ត៌មានបន្ថែមអំពីអ្វី ដែលពួកគាត់បានរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាល។ (ចម្លើយ៖ ក និងគ)

ក. សាកសួរបុគ្គលិកមណ្ឌលសុខភាព

ខ. សាកសួរគ្រូឱសថបូរាណ

គ. អានមេរៀនដែលចែកឱ្យ

**ចំណងជើងមេរៀនទី ២៖ ជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល រយៈពេល ៦ ម៉ោង ៥០នាទី**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១. កំណត់រោគសញ្ញា និងអាការៈនៃ ជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល

២. ពិភាក្សាអំពី មូលហេតុដែលបង្កឱ្យមានជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល

៣. រៀបរាប់ពី ការព្យាបាល និងការថែទាំជំងឺផ្តាសាយតាមរដូវកាលនៅផ្ទះ

៤. រៀបរាប់ពីសញ្ញាជំងឺផ្តាសាយតាមរដូវកាល ដែលតម្រូវឱ្យមាន ការថែទាំនៅមូលដ្ឋានសុខាភិបាល

៥. រៀបរាប់ពី វិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺផ្តាសាយបក្សី

៦. រៀបរាប់ពី វិធានការដែលត្រូវអនុវត្តពេលមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកល

៧. រៀបរាប់ពី វិធានការការពារជំងឺផ្តាសាយតាមរដូវកាល និងផ្តាសាយបក្សី

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សា
- រូបភាពទំព័រទី ១២ ១៣ ១៥ ១៦ ១៧ ១៩ ២០ ២២ ២៣ ២៥ ២៦ ២៧ ២៨ ២៩ ៣០
- ក្រដាស ដែលមានសរសេរសោរវិធានការការពារផ្តាសាយតាមរដូវកាល ផ្តាសាយសកល ផ្តាសាយបក្សី

- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត កន្ត្រៃ និងបង់ស្អិត។

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- សំណួរបំផុសគំនិត
- ពិភាក្សាក្រុមធំ

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖

ដោយផ្អែកលើបទពិសោធន៍របស់យើងកន្លងមក អ្នកទាំងអស់គ្នាបានយល់ដឹង អំពីអ្វីជាជំងឺ ផ្តាសាយ ប៉ុន្តែប្រហែល ជាយើងមិនទាន់យល់ច្បាស់ អំពីមូលហេតុរបស់វា និងការការពារ ។ ឥឡូវនេះ យើងចាប់ផ្តើមពិភាក្សាអំពីមូលហេតុខ្លះៗនៃជំងឺផ្តាសាយ ដូច្នេះយើងអាចយល់អំពី របៀបការពារជំងឺនេះនៅពេលអនាគត។

**វត្ថុបំណងទី ១៖ កំណត់រោគសញ្ញា និងអាការៈនៃជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និងផ្តាសាយសកល** **រយៈពេល ៩០ នាទី**

**សេចក្តីផ្តើម៖**

ដូចដែលអ្នកបានដឹងហើយថា ក្អកផ្តាសាយកើតមានជាញឹកញាប់ ហើយកុមារអាចមានក្អកផ្តាសាយ ៥ - ៥ដងក្នុង ១ឆ្នាំ។ ក្អកផ្តាសាយមិនមែនជាជំងឺធ្ងន់ធ្ងរទេ ប៉ុន្តែអាចវិវត្តសន្សឹមៗ ទៅជារលាកសួត បើសិនកុមារពុំបានទទួលនូវការថែទាំព្យាបាលត្រឹមត្រូវ។ ការយល់ដឹងពីពេលវេលា និងសញ្ញាដែលនាំឱ្យគិតដល់ ឬ ពីការលេចឡើងនៃជំងឺរលាកសួត មានសារៈសំខាន់ណាស់។ កុមារមានជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ ចាំបាច់ត្រូវទទួលការពិនិត្យ ព្យាបាលនៅមណ្ឌលសុខភាព បើពុំនោះទេកុមារអាចស្លាប់។

- **សំណួរបំផុសគំនិត**

តើមានអ្នកណាដឹងថាមានជំងឺផ្តាសាយប៉ុន្មានយ៉ាង?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរោគសញ្ញាជំងឺផ្តាសាយតាមរដូវកាល

**ចម្លើយចូលរួម៖** ផ្តាសាយមានបីយ៉ាងធំៗ៖

1. ផ្តាសាយតាមរដូវកាល
2. ផ្តាសាយបក្សី

3. ផ្តាសាយសកល

**សំណួរ៖** តើនៅក្នុងភូមិរបស់យើងឥឡូវនេះមានអ្នកណាមួយមានជំងឺផ្តាសាយ (ផ្តាសាយតាមរដូវកាល)ឬទេ?

តើអ្នកដឹងថាជំងឺផ្តាសាយមានអាការៈនិងរោគសញ្ញាយ៉ាងដូចម្តេច?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរោគសញ្ញាជំងឺផ្តាសាយតាមរដូវកាល

**ចម្លើយចូលរួម៖** ផ្តាសាយតាមរដូវកាលមានរោគសញ្ញា៖

- o គ្រុនក្តៅភ្លាមៗ ចាប់ពី៣៨អង្សា ឡើងទៅ (យកកំដៅ នៅក្រោមក្លៀក)
- o ក្អកស្ងួត
- o ឈឺបំពង់ក
- o ហៀរសំបោរ
- o ឈឺក្បាល
- o ឈឺសាច់ដុំ
- o របិតរបៃ អស់កំលាំងខ្លាំង

ជាទូទៅរយៈពេល សំងំរបស់ជំងឺមានរយៈពេលខ្លី ១-៣ថ្ងៃ។



បិទរូបភាពខាងក្រោមនេះ នៅមុខសិក្ខាកាម













**សួរសិក្ខាកាមនូវសំណួរ** ៖ តើទៅជាជំងឺផ្តាសាយបក្សី?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម

- បង្ហាញចម្លើយចូលរួមនៅលើក្រដាសផ្ទាំងធំ អំពីនិយមន័យជំងឺផ្តាសាយបក្សី

**ចម្លើយចូលរួម៖** ជំងឺផ្តាសាយបក្សីគឺជាជំងឺឆ្លង បណ្តាលមកពីវីរុសហាស់ប្រាំអិនមួយ(H5N1) ដែលជាធម្មតាចំលងរវាងសត្វបក្សីឈឺ ទៅបក្សីផ្សេងទៀត ប៉ុន្តែជួនកាល វាអាចចំលងពីបក្សីមកមនុស្ស។ ជំងឺផ្តាសាយបក្សីលើមនុស្ស ជាជំងឺធ្ងន់ធ្ងរ ដែលតំរូវឲ្យមានការ ធ្វើការព្យាបាលនៅមន្ទីរពេទ្យ។ អត្រាស្លាប់លើមនុស្ស មានរហូតដល់ទៅ ៦០ ភាគរយ។ទោះជាវាមិនងាយឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀត ប៉ុន្តែបើវាផ្លាស់ប្តូរ វានឹងអាចរាលដាល ដូចនឹងជំងឺផ្តាសាយតាមរដូវកាល។ ដូច្នេះការរកឃើញទាន់ពេលវេលា មានសារៈសំខាន់បំផុត។

**សូមពន្យល់បន្ថែម** ៖ ប៉ះពាល់ជាមួយ អ្នកជំងឺផ្តាសាយបក្សី (គឺ ប៉ះពាល់យ៉ាងស្និទ្ធ (តិចជាង១ម៉ែត្រ) លើសពី៥នាទី (ឧទាហរណ៍៖ អ្នកថែទាំ និយាយជាមួយ ឬប៉ះពាល់ជាមួយ អ្នកជំងឺផ្តាសាយបក្សី )

ជាទូទៅរយៈពេល សំងំរបស់ជំងឺមានរយៈពេលខ្លី ២-៨ថ្ងៃ ជួនកាលរហូតដល់១៧ថ្ងៃ ជាមធ្យម ៧ថ្ងៃ។

**សំណួរ**៖ តើនៅក្នុងភូមិរបស់យើងឥឡូវនេះមានអ្នកណាមួយមានជំងឺផ្តាសាយបក្សីឬទេ?
តើអ្នកដឹងថាជំងឺផ្តាសាយបក្សី មានអាការៈនិងរោគសញ្ញាយ៉ាងដូចម្តេច?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីរោគសញ្ញាជំងឺផ្តាសាយបក្សី

**ចម្លើយចូលរួម៖** ផ្តាសាយបក្សីមានរោគសញ្ញា៖

## មានរោគសញ្ញាដូចគ្នានឹងផ្តាសាយតាមរដូវកាល

1. គ្រុនក្តៅខ្លាំងៗ ចាប់ពី៣៨អង្សា ឡើងទៅ (យកកំដៅ នៅក្រោមក្លៀក)
2. ក្អកស្ងួត
3. ឈឺបំពង់ក
4. ហៀរសំបោរ
5. ឈឺក្បាល
6. ឈឺសាច់ដុំ
7. រហិតរហៃ អស់កំលាំងខ្លាំង

## រួមជាមួយនឹង

1. មានប្រវត្តិប៉ះពាល់ជាមួយមាន់ ឬទា ឬបសុបក្សី ឈឺ ឬងាប់ក្នុងអំឡុង៧ថ្ងៃមុនចាប់ផ្តើមឈឺ ឬប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សី និង
2. សញ្ញាផ្លូវដង្ហើម ដូចជា ហត់ ឬពិបាកដកដង្ហើម

**សំណួរ**៖

- តើពាក្យរាតត្បាតសកលមានន័យថាម៉េចដែរ?
    - កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
    - សម្របសម្រួលចម្លើយសិក្ខាកាម

- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីពាក្យរាតត្បាតសកលៈ មានន័យថា គឺជាការរាតត្បាតជម្ងឺសកល ពេញទូទាំងប្រទេស គ្រប់ប្រទេស ច្រើនប្រទេស៕

➢ អ្វីជាផ្តាសាយសកល? មានអ្នកណាម្នាក់ដឹងឬទេ?
  - o កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
  - o សម្របសម្រួលចម្លើយសិក្ខាកាម
  - o បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ ដែលមានសរសេរ

**ផ្តាសាយសកល**

- ផ្តាសាយសកលជាជំងឺផ្តាសាយប្រភេទថ្មី ដែលឆ្លងយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់
- ជំងឺផ្តាសាយបក្សីក៏អាច បង្កជាជំងឺផ្តាសាយសកលធ្ងន់ធ្ងរ បើវីរុសបំលែងខ្លួន ដែលអាចឆ្លងយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់។

**ទត្ថុបំណងទី ២៖ ពន្យល់អំពីមូលហេតុដែលបង្កឱ្យមាន ជំងឺផ្តាសាយតាមរដូវកាល ផ្តាសាយបក្សី និង ផ្តាសាយសកល** **រយៈពេល ១១០ នាទី**

- **ពិភាក្សាក្រុមធំ៖ រយៈពេល ៣០នាទី**

បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖






- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើអ្នកគិតថាមនុស្សម្នាក់មានជំងឺផ្តាសាយ (ជំងឺផ្តាសាយតាមរដូវកាល)យ៉ាងដូចម្តេច?
- សួរសិក្ខាកាមថា តើមានឥរិយាបទអាក្រក់អ្វីខ្លះ ដែលអ្នកគិតថា បណ្តាលឱ្យមានផ្តាសាយតាមរដូវកាល? សូមគិតអំពីប្រជាជននៅក្នុងភូមិរបស់អ្នក ចំពោះអ្នកដែលកើតមានជំងឺផ្តាសាយញឹក

ញាប់។ តើពួកគាត់មានឥរិយាបទអ្វីខ្លះ ដែលបង្កឱ្យពួកគាត់មានជំងឺ?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីមូលហេតុដែលបង្កឱ្យមានជំងឺផ្តាសាយ

**ចម្លើយ៖** ជំងឺផ្តាសាយតាមរដូវកាលបណ្តាលមកពី៖

- ➢ កង្វះអនាម័យ៖ ក្នុងផ្ទះកខ្វក់ ខោអាវកខ្វក់ មានផ្សែងចង្រ្កាន ផ្សែងបារី មានភក់ជ្រាំ មានលាមកសត្វ/មនុស្ស សំរាម ព្រៃស៊ុបទ្រុប ប្រើប្រាស់ក្រម៉ារួមគ្នា ។ល។
- ➢ នៅជិត ឬនៅជាមួយ ឬ លេងជាមួយ ឬប៉ះពាល់ ឬនិយាយជាមួយអ្នកជំងឺផ្តាសាយ ដោយមិនមានវិធានការការពារជាមុន
- ➢ មិនបានលាងសម្អាតដៃជាមួយសាប៊ូឲ្យបានញឹកញាប់ ជាពិសេស មុនពេល បំបៅដោះកូន មុនពេលបរិភោគ មុនពេលរៀបចំអាហារ និងបញ្ចុកអាហារកូន និងក្រោយពេលចេញពីបង្គន់ជាដើម។
- ➢ មិនបានទទួលថ្នាំបង្ការសព្វគ្រប់និងត្រឹមត្រូវ
- ➢ អាកាសធាតុប្រែប្រួល

**ពិភាក្សាក្រុមធំ៖ រយៈពេល ៣០នាទី**

បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖










**និទានរឿងទៅកាន់សិក្ខាកាមទាំងមូលៈ**

**និទានរឿងទី១ៈ** តើក្មេងប្រុសនេះកំពុងធ្វើអ្វី? ចម្លើយ កាន់ទាពីរក្បាល

ក្មេងប្រុសម្នាក់នេះលក់ទាពីរក្បាល មកឲ្យអ្នកក្នុងតំលៃ ៥០០០រៀល ។ ក្មេងប្រុសម្នាក់នេះប្រាប់អ្នកថា ទានេះឈឺ និងត្រូវគេបរិភោគវាថ្ងៃនេះ ហេតុនេះបានជាលក់ក្នុងតំលៃថោក។ នៅទីផ្សារ ទារស់ត្រូវបានលក់ទៅតាមទំងន់របស់វាហើយមួយគីឡូក្រាមថ្លៃ៦០០០រៀល។

សំណួរបំផុសគំនិតៈ

តើអ្នកគិតថាអ្នកមានជំងឺផ្តាសាយបក្សី យ៉ាងដូចម្តេច?

**និទានរឿងទី២ៈ**

បិទរូបនេះនៅចំពោះមុខសិក្ខាកាមៈ



តើបុរសនេះកំពុងធ្វើអ្វី? ចម្លើយ បោចមាន់

បុរសនេះចង់ឲ្យមាន់១ក្បាលនេះមកឲ្យអ្នក ដោយមិនយកលុយ ។ អ្នកអាចធ្វើវាជាអាហារពីព្រោះវាទើបតែងាប់ថ្មីៗ។

សំណួរបំផុសគំនិតៈ

**តើអ្នកគិតថាអ្នកមានជំងឺផ្តាសាយបក្សី យ៉ាងដូចម្តេច?**

**ចម្លើយចូលរួមៈ** ការសំលាប់មាន់ បោចមាន់ និងការរៀបចំ សត្វបសុបក្សីឈឺឬងាប់ សំរាប់ធ្វើម្ហូប គឺជាការ

គ្រោះថ្នាក់បំផុត ដូច្នេះឥរិយាបទនេះត្រូវតែបញ្ឈប់៕ ការប៉ះពាល់ដោយផ្ទាល់ជាមួយសត្វបសុបក្សីដែលមានជំងឺ ឬផ្ទៃឬវត្ថុដែលប៉ះជាមួយ សំបោរ លាមក ជាប្រភពចំលងដ៏ចំបង ។ ការប្រឈមខ្ពស់ ក្នុងពេលសំលាប់ បោច កាប់សំលាប់ និងធ្វើម្ហូប៕

**ចែកសិក្ខាកាមជាបីក្រុមះដើម្បីពិភាក្សាៈ រយៈពេល ៥០នាទី**

តើអ្នកអាចធ្វើអ្វីដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លង វីរុស ហាស់ប្រាំអិនមួយ?

តើត្រូវធ្វើដូចម្តេចដើម្បីការពារខ្លួនអ្នក ប្រសិនជាអ្នកប៉ះពាល់ជាមួយបសុបក្សី ឬ សត្វស្លាប?

តើត្រូវធ្វើដូចម្តេចបើមានបសុបក្សី ឬ សត្វស្លាបងាប់?

តើត្រូវធ្វើដូចម្តេចដើម្បីរៀបចំនិងបរិភោគ សាច់ឬស៊ុតបសុបក្សី ឬ សត្វស្លាប?

តើត្រូវធ្វើដូចម្តេចដើម្បីត្រួតពិនិត្យ ការរាលដាលបសុបក្សីពេលមានការរាតត្បាត?

ក្នុងអំឡុងមានការរាតត្បាតប្រសិនជាមានបសុបក្សី ឬ មាន់ទាងាប់តើយើងអាចយកមកធ្វើម្ហូបបានឬទេ?

តើត្រូវធ្វើដូចម្តេចប្រសិនជាអ្នកប៉ះជាមួយលាមកបសុបក្សី ក្នុងតំបន់មានឆ្លងជំងឺ និងធ្លាក់ខ្លួនឈឺ?

**រឿងនិទានទីមួយះសំរាប់ក្រុមទីមួយ ៖** សមាជិកសហគមប្រាប់អ្នកថា មានមាន់ងាប់ចំនួន៣០ក្បាលក្នុងទ្រុង កាលពីព្រឹកមិញនេះ ពេលដែលគាត់ទៅដាក់ចំណីឲ្យវាស៊ី ។ ប្រពន្ធគាត់សួរថាតើគាត់អាចយកមាន់ ២-៣ក្បាល សំរាប់ធ្វើម្ហូបអាហារសំរាប់អាហារពេលល្ងាច និង ហើយគាត់និងយកមាន់នៅសល់ទៅលក់នៅឯផ្សារ។គាត់បានឮ ថាមាន់នេះអាចឆ្លងជំងឺផ្តាសាយបក្សី? គាត់ចង់ឲ្យអ្នកផ្តល់ដំបូន្មានឲ្យគាត់ តើអ្វីដែលអ្នកអាចប្រាប់គាត់បាន?

**រឿងនិទានទីពីរះ សំរាប់ក្រុមទីពីរ ៖** សមាជិកសហគមម្នាក់ប្រាប់អ្នកថា ជីដូនមួយរបស់នាងមកដល់ភូមិកាលពីសប្តាហ៍មុននិងបាននាំមកជាមួយនូវមាន់និងស៊ុតមួយចំនួន ។ អ្នកនិងគ្រួសារអ្នកបានបរិភោគមាន់ពីរក្បាលកាលពីថ្ងៃអាទិត្យ ប៉ុន្តែថ្ងៃនេះមាន់ដែលនៅសល់បានងាប់។ ពេលនេះអ្នកភ័យ និងចង់ដឹងថាមាន់នេះងាប់ដោយសារជំងឺផ្តាសាយបក្សី ឬអត់?

**រឿងនិទានទីបីះ សំរាប់ក្រុមទីបី ៖** សមាជិកសហគមម្នាក់បានទៅផ្សារកាលពីពេលព្រឹកម្សិលម៉្សិញ និងបានឃើញមាន់ជាច្រើន ងាប់ ដូច្នេះអ្នកមិនបានទិញ វាទេ និង ប្រញាប់ប្រញាល់ត្រលប់មកផ្ទះវិញ ប៉ុន្តែអ្នកចង់ដឹងថា អ្នកឆ្លងជំងឺនេះនិងស្លាប់ឬទេ?

បន្ទាប់ពិភាក្សាឲ្យតំណាងក្រុមឡើងបកស្រាយទៅក្រុមធំ

បន្ទាប់មកះ

បិទរូបនេះនៅចំពោះមុខសិក្ខាកាមឡើងវិញះ









សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើអ្នកគិតថាមនុស្សម្នាក់មានជំងឺផ្តាសាយបក្សី យ៉ាងដូចម្តេច?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម

បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ:

**ចម្លើយ៖** ជំងឺផ្តាសាយបក្សីលើមនុស្សបណ្តាលមកពី៖

1. លេងជាមួយឬប៉ះពាល់បសុបក្សី ឬ ចូលទៅទីកន្លែងដែលមានមេរោគផ្តាសាយបក្សីសាយភាយ ដោយមិនមានវិធានការការពារជាមុន (ប៉ះពាល់ជាមួយបក្សីស្រុក ឬព្រៃ ឈឺ ឬស្លាប់ ដោយ កាន់ សំលាប់ បោចរោម កាប់សាច់ ធ្វើម្ហូបអាហារ)
2. បរិភោគផលិតផលសាច់ឬស៊ុតបសុបក្សី ដែលចំអិនមិនឆ្អិនល្អ
3. ប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សី ដោយមិនមានវិធានការការពារជាមុន

**មូលហេតុដែលនាំឲ្យមានផ្តាសាយសកល គឺបណ្តាលមកពី វីរុសដែលរាលដាលដូចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដូចផ្តាសាយតាមរដូវកាល។**

## **វត្ថុបំណងទី ៣៖ រៀបរាប់ពី ការព្យាបាល និងការថែទាំជាមូលដ្ឋានសំរាប់ ជំងឺផ្តាសាយតាមរដូវកាល នៅផ្ទះ**

**រយៈពេល ៤០ នាទី**

ពិភាក្សាក្រុមធំ

- បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖



នៅពេលណាកូនរបស់គាត់មានក្អកផ្តាសាយ តើអ្នកថែទាំគេដូចម្តេច?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីវិធានការការពារជំងឺផ្តាសាយតាមរដូវកាល

**ការថែទាំជាមូលដ្ឋានសម្រាប់អ្នកជំងឺផ្តាសាយតាមរដូវកាលនៅផ្ទះ**

**កុមារអាយុក្រោម៥ឆ្នាំ**

- o វិធីបន្ថយក្អក ដែលមានសុវត្ថិភាព៖
    - o បំបៅដោះកុមារឱ្យបានញឹកញាប់ជាងធម្មតា (កុមារអាយុក្រោម ៦ខែ បៅដោះសុទ្ធ)
    - o ចំពោះកុមារមិនបៅដោះសុទ្ធ ឬអាយុចាប់ពី ៦ខែ ឱ្យទឹកតែក្តៅឧណ្ឌៗ ជាមួយទឹកក្រូចឆ្មារ និងស្ករ ឬទឹកឃ្មុំ ឬមួយទឹកតែក្តៅឧណ្ហៗ ជាមួយខ្ញី ក្នុងរសជាតិឡមៗ ឱ្យកុមារផឹក តាមដែលអាចផឹកបាន
- o ត្រូវផ្តល់ជាតិទឹកដល់កុមារញ៉ាំឱ្យបានច្រើនដូចជា ទឹកដោះម្តាយ ទឹកដូង ទឹក ។ល។
- o បៀវសំបោរ/កណ្តាស ត្រូវសំអាតច្រមុះកុមារឲ្យបានញឹកញាប់ជាមួយក្រណាត់/កន្សែង/

ក្រម៉ាស្អាត។

- o លួងលោមកុមារឱ្យញុំាអាហារឱ្យបានញឹកញាប់ បើវាឈឺបំពង់កចូរឱ្យអាហារទន់ៗដូចជាបបរមាន ជីវជាតិគ្រប់គ្រាន់។
- o បើក្អកយូរចាប់ពី ៣ថ្ងៃ ត្រូវយកទៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យដែលនៅជិតជាង គេជាបន្ទាន់។
- o ក្តៅខ្លួន ស្អំកុមារនឹងក្រណាត់ /កន្សែង/ ក្រម៉ាសើមនៅឃ្លៀក ក ក្រលៀន ។ល។
- o មិនត្រូវផ្តល់អង់ទីប៊ីយ៉ូទិកដល់កុមារ
- o មិនត្រូវដាក់សេរ៉ូម ឬ ចាក់ថ្នាំតាមសរសៃដល់កុមារ

**ត្រូវបញ្ជូនកុមារមានក្អកផ្តាសាយទៅមូលដ្ឋានសុខាភិបាល បើមានសញ្ញាណាមួយ ខាងក្រោម៖**

- – មិនស្ទូវបៅ ឬ ញុំា ឬ មិនអាចបៅបាន ឬ មិនអាចផឹកបាន។
- – ឈឺរឹតតែធ្ងន់ទៅ។
- – ចាប់មានគ្រុនក្តៅខ្លាំង។
- – ដកដង្ហើមហត់ ឬ ញាប់ជាងធម្មតា។
- – ផ្ទាំងទ្រូងផ្នែកខាងក្រោមផតចូលពេលដកដង្ហើមចូល។
- – កុមារពុំធូរស្រាលក្រោយរយ:ពេល ៣ថ្ងៃ។

**អាយុចាប់ពី៥ឆ្នាំឡើង**

- o វិធីបន្ថយក្អក ដែលមានសុវត្ថិភាព៖
  - o ឱ្យទឹកតែក្តៅឧណ្ហៗ ជាមួយទឹកក្រូចឆ្មារ និងស្ករ ឬទឹកឃ្មុំ ឬមួយទឹកតែក្តៅឧណ្ហៗ ជាមួយខ្ញី តាមដែលអាចផឹកបាន
  - o សំរាកឲ្យបានច្រើនផឹកទឹកឲ្យបានច្រើន
  - o ខ្ពស់មាត់ជាមួយទឹកអំបិល

## ចំណុចទី ៤៖ រៀបរាប់ពី សញ្ញាជំងឺផ្តាសាយតាមរដូវកាល ដែលតម្រូវឱ្យមាន ការថែទាំនៅមូលដ្ឋានសុខាភិបាល រយ:ពេល ៤០ នាទី

- ➢ ការបំផុសគំនិត

1- ពន្យល់ថា គ្រុនផ្តាសាយ និងក្អក បើពុំព្យាបាលអាចនឹងបង្កទៅជាជំងឺធ្ងន់ធ្ងរបាន។ សួរក្រុម “តើសញ្ញា ដែលតម្រូវឱ្យមានការថែទាំនៅសេវាសុខភាព នៃកុមារមានក្អកផ្តាសាយ ឬ ក្អកធ្ងន់ធ្ងរ មានអ្វីខ្លះ? ” តើ អ្នកធ្វើអនុសាសន៍អ្វីខ្លះ សម្រាប់កុមារមានសញ្ញាទាំងអស់នេះ?

2- បន្ទាប់ពីការផ្តល់គំនិត ពន្យល់ថា ជានិច្ចកាលពួកគាត់ត្រូវធ្វើអនុសាសន៍ថា ឪពុកម្តាយ ឬ អ្នកថែទាំត្រូវ នាំកុមារ ស្វែងរកការព្យាបាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ បើសិនពួកគេមានសញ្ញាណាមួយដែល តម្រូវឱ្យមានការថែទាំនៅសេវាសុខភាព ដូចខាងក្រោម ៖

**ត្រូវបញ្ជូនកុមារមានក្អកផ្តាសាយទៅមូលដ្ឋានសុខាភិបាល បើមានសញ្ញាណាមួយ ខាងក្រោម៖**

- – មិនស្ទូវបៅ ឬ ញុំា ឬ មិនអាចបៅបាន ឬ មិនអាចផឹកបាន។

- ឈឺរឹតតែធ្ងន់ទៅ។
- ចាប់មានគ្រុនក្តៅខ្លាំង។
- ដកដង្ហើមហត់ ឬ ញាប់ជាងធម្មតា។
- ផ្ទាំងទ្រូងផ្នែកខាងក្រោមផតចូលពេលដកដង្ហើមចូល។
- កុមារពុំធូរស្រាលក្រោយរយៈពេល ៣ថ្ងៃ។

**ចន្លុះបំណងទី ៥៖ រៀបរាប់ពី ចំណាត់ការដែលត្រូវអនុវត្ត ពេលជួបករណីសង្ស័យ ថាមានជំងឺផ្តាសាយបក្សី**

**រយៈពេល ២០ នាទី**

**ពិភាក្សាក្រុមធំ**

**តើពេលណាដែលអ្នកសង្ស័យថាកុមារម្នាក់ឬមនុស្សម្នាក់មានជំងឺផ្តាសាយបក្សី?**

**មានរោគសញ្ញាដូចគ្នានឹងផ្តាសាយតាមរដូវកាល**

1. គ្រុនក្តៅខ្លាំងៗ ចាប់ពី៣៨អង្សា ឡើងទៅ (យកកំដៅ នៅក្រោមក្លៀក)
2. ក្អកស្ងួត
3. ឈឺបំពង់ក
4. ហៀរសំបោរ
5. ឈឺក្បាល
6. ឈឺសាច់ដុំ
7. រហិតរហៃ អស់កំលាំងខ្លាំង

**រួមជាមួយនឹង**

3. មានប្រវត្តិប៉ះពាល់ជាមួយមាន់ ឬទា ឬបសុបក្សី ឈឺ ឬងាប់ក្នុងអំឡុង៧ថ្ងៃមុនចាប់ផ្តើមឈឺ ឬប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សី និង
4. សញ្ញាផ្លូវដង្ហើម ដូចជា ហត់ ឬពិបាកដកដង្ហើម

**តើពេលសង្ស័យណាមានកុមារម្នាក់ឬមនុស្សម្នាក់មានជំងឺផ្តាសាយបក្សីត្រូវធ្វើដូចម្តេច?**




1) ត្រូវបញ្ជូនអ្នកជំងឺទៅជួបគ្រូពេទ្យជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតដើម្បីពិនិត្យព្យាបាលឱ្យទាន់ពេលវេលា។

2) កុំផ្ដល់ឱសថអាស្ពីរីនដល់អ្នកជំងឺ
3) នៅពេលថៃទាំអ្នកជំងឺត្រូវជៀសវាងការប៉ះពាល់ជិតស្និទ្ធជាមួយអ្នកជំងឺដូចជា ការអោប រឺថើបជាដើម។
4) ណែនាំដល់អ្នកជំងឺអោយពាក់ម៉ាស់ ឬប្រើក្រម៉ាគ្របច្រមុះ និង មាត់។ចំពោះអ្នកថៃទាំក៏ត្រូវពាក់ម៉ាស់ ឬក្រម៉ា ការពារខ្លួនឯងផងដែរ
5) ប្រសិនមានមាន់ទាឈឺឬងាប់ខុសធម្មតា នៅក្នុងភូមិ ត្រូវរាយការណ៍ជាបន្ទាន់តាមទូរស័ព្ទ៖ **០១២ ២១៤ ៩៧០ ឬ ០១២ ៨៣៣ ៧៩៥**
6) បើសង្ស័យថានរណាម្នាក់មានជំងឺផ្ដាសាយបក្សីសូមបញ្ជូនអ្នកជំងឺទៅពិគ្រោះជាមួយគ្រូពេទ្យជាបន្ទាន់ឬទូរស័ព្ទទៅក្រសួងសុខាភិបាលតាមទូរស័ព្ទលេខ៖ **១១៥ ឬ ០១២ ៤៨៨ ៩៨១ ឬ ០៨៩ ៦៦៩ ៥៦៧** ។

**វត្ថុបំណងទី ៦៖ រៀបរាប់ពី វិធានការដែលត្រូវអនុវត្ត ពេលមានផ្ទុះជំងឺផ្ដាសាយរាតត្បាតជាសកល**

**រយៈពេល ២០ នាទី**

**ពិភាក្សាក្រុមធំ**

**ពេលមានផ្ទុះជំងឺផ្ដាសាយរាតត្បាតជាសកលតើអ្នកត្រូវធ្វើដូចម្ដេច?**



អ្នកជំងឺផ្ដាសាយជាច្រើនកំពុងសំរាកព្យាបាលក្នុងពេលការរាតត្បាតជំងឺផ្ដាសាយជាសកលក្នុងឆ្នាំ ១៩១៨-១៩១៩

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្ដារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីវិធានការត្រូវធ្វើពេលមានផ្ដាសាយសកល

**សេចក្តីផ្តើម ៖** បច្ចុប្បន្ននេះវីរុសជំងឺផ្តាសាយបក្សីមិនទាន់បំលែងខ្លួនវា និងមាន លទ្ធភាពចំលងពីមនុស្សទៅមនុស្សនៅឡើយទេ ។ ប៉ុន្តែប្រសិនបើវាមានលទ្ធភាពចំលងពីមនុស្សទៅមនុស្សនោះវានឹងអាចឆ្លងរីករាលដាលជុំវិញពិភពលោក ហើយមនុស្សមួយចំនួននឹងស្លាប់ដោយជំងឺនេះ។ ការឆ្លងរាលដាលពីមនុស្សទៅមនុស្ស នៃវីរុសជំងឺផ្តាសាយបក្សីជុំវិញពិភពលោកនេះត្រូវបាន គេហៅថាការឆ្លងរាលដាល ជាសកល។

**ចម្លើយចូលរួម៖** ដូច្នេះប្រសិនបើការរាតត្បាតនោះកើតឡើង យើងត្រូវអនុវត្តនូវសេចក្តី ណែនាំមួយចំនួនដូចខាងក្រោមនេះ ៖

1. ត្រូវរាយការណ៍ជាបន្ទាន់ប្រសិនបើក្នុងកន្លែងណាមួយមានអ្នកជំងឺកើតជំងឺផ្តាសាយច្រើន
2. មិនត្រូវធ្វើដំណើរទៅកន្លែងដែលមានមនុស្សកកកុញ ឬ កន្លែងដែលមានជំងឺផ្តាសាយច្រើននៅទីនោះ
3. បើមានអ្នកទើបតែមកពីតំបន់ផ្ទុះនោះ ត្រូវឱ្យអ្នកនោះលាងសំអាតខ្លួន និង ពាក់ម៉ាស់ ហើយនៅឱ្យដាច់ពីសមាជិកគ្រួសារ និង ឱ្យប្រើសំភារៈប្រើប្រាស់ ដោយឡែក
4. ត្រូវលាងដៃជាមួយសាប៊ូ និងទឹកឱ្យបានញឹកញាប់
5. ត្រូវប្រើក្រដាសអនាម័យ កន្សែងដៃ ឬ ក្រម៉ា ខ្ទប់ច្រមុះ និងមាត់នៅពេលក្អក ឬកណ្តាស់ និងបោះចោលក្រដាសអនាម័យដោយប្រុងប្រយ័ត្ន និង បោកគក់ កន្សែងដៃ ឬក្រម៉ាជាមួយសាប៊ូ និងទឹករួចហាលកណ្តាល ថ្ងៃឱ្យស្ងួតល្អ
6. ត្រូវប្រាប់ទៅអ្នកជិតខាង សាច់ញាតិ ដើម្បីរកវិធីព្យាបាលនៅផ្ទះ ឬទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលជិតបំផុត ឬ ក៏ទៅកន្លែងព្យាបាលបណ្តោះអាសន្នដែលរៀបចំឡើងដោយអាជ្ញាធរមូលដ្ឋាន។

**វគ្គបំណងទី ៧៖ រៀបរាប់ពីវិធានការការពារជំងឺផ្តាសាយតាមរដូវកាល និង ផ្តាសាយបក្សី**

**រយៈពេល ៩០ នាទី**

ពិភាក្សាក្រុមធំ

- បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖











- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើធ្វើដូចម្តេចដើម្បីការពារជំងឺផ្តាសាយតាមរដូវកាល?
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីវិធានការការពារជំងឺផ្តាសាយតាមរដូវកាល

**ចម្លើយ** ៖អំពីវិធានការការពារជំងឺផ្តាសាយតាមរដូវកាល

1. ត្រូវមានអនាម័យល្អ៖ សម្អាតក្នុងផ្ទះឲ្យបានស្អាតជាប្រចាំ បោកគក់ខោអាវ មិនត្រូវឲ្យមានផ្សែងចង្ក្រាន ឬផ្សែងបារីនៅក្នុងផ្ទះ បោសសម្អាតសំរាម លាមកសត្វ/មនុស្ស លុបបំបាត់ភក់ជ្រាំ និងកាប់ឆ្ការព្រៃជុំវិញផ្ទះ មិនត្រូវប្រើប្រាស់ក្រម៉ារួមគ្នា ។ល។
2. មិនត្រូវនៅជិត ឬនៅជាមួយ ឬ លេងជាមួយ ឬប៉ះពាល់ ឬនិយាយជាមួយអ្នកជំងឺផ្តាសាយ
3. ត្រូវលាងសម្អាតដៃជាមួយសាប៊ូឲ្យបានញឹកញាប់ជាពិសេសមុនពេល បំបៅដោះកូន មុនពេលបរិភោគ រៀបចំអាហារ បញ្ចុក អាហារកូន និងក្រោយពេលចេញពីបង្គន់ ជាដើម។
4. យកកុមារទៅទទួលថ្នាំបង្ការឲ្យបានគ្រប់តាមកាលកំណត់របស់គ្រូពេទ្យ
5. ស្លៀកពាក់ខោអាវឲ្យកុមារឲ្យជិត ឬកុំឲ្យត្រូវទឹកភ្លៀង

**ពិភាក្សាក្រុមធំ**

- បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖


ផ្តាសាយបក្សី
មិនត្រូវអោយកុមារលេង
ឬប៉ះពាល់មាន់-ទាទេ
ជាពិសេសមាន់-ទា
ដែលឈឺ ឬងាប់
គ្រោះថ្នាក់!


ផ្តាសាយ
បក្សី
ជំងឺផ្តាសាយបក្សី
អាចឆ្លងទៅមនុស្ស
តាមរយៈមាន់-ទា
ដែលឈឺ ឬងាប់
សូមណែនាំកូន
លោកអ្នកកុំអោយ
ប៉ះពាល់មាន់-ទា
ដែលឈឺ ឬងាប់
ចំពោះព័ត៌មាន
បន្ថែមសូមទាក់ទង
ក្រសួងសុខាភិបាល
តាមទូរស័ព្ទលេខ
០១២ ៨៨៨ ៩៨១
ឬ ០៨៩ ៦៦៩ ៥៦៧
គ្រោះថ្នាក់!
មាន់-ទាដែលឈឺ ឬ ងាប់
មិនមែនជារបស់សំរាប់លេងទេ






We have to wear mask or Krama
before touching poultry


We have to wear mask or Krama
before touching poultry.


Put poultry in boiling water
before plucking.


Collect all feather and other waste
to bury or burn.


Wash your hand and other utensil
with soap or ash properly.


ផ្តាសាយ?
លាងដៃ ការពារខ្លួនអ្នក!




ដៃស្អាត =
សុខភាពល្អ


ដៃស្អាត=សុខភាពល្អ
សូមលាងដៃឱ្យបាន
ញឹកញាប់ជាមួយ
សាប៊ូ ឬផេះ











- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើធ្វើដូចម្តេចដើម្បីការពារជំងឺផ្តាសាយបក្សី?
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម

- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីវិធានការការពារជំងឺផ្តាសាយបក្សី

**ចម្លើយ** ៖អំពីវិធានការការពារជំងឺផ្តាសាយបក្សី

1. មិនត្រូវលេងជាមួយឬប៉ះពាល់បសុបក្សី ឬ ចូលទៅទីកន្លែងដែលមានមេរោគផ្តាសាយបក្សីសាយភាយដោយមិនមានវិធានការការពារជាមុន (ប៉ះពាល់ជាមួយបក្សីស្រុក ឬព្រៃ ឈឺ ឬស្លាប់ ដោយ កាន់ សំលាប់ បោចរោម កាប់សាច់ ធ្វើម្ហូបអាហារ)
2. មិនត្រូវបរិភោគផលិតផលសាច់ឬស៊ុតបសុបក្សី ដែលចំអិនមិនឆ្អិនល្អ
3. មិនត្រូវប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សី ដោយមិនមានវិធានការការពារជាមុន
4. នៅឲ្យឆ្ងាយពីសត្វបក្សីឈឺឬងាប់ ជាពិសេសកុមារ ។
5. ហាមក្មេងកុំឱ្យចូលរួមទស្សនាជល់មាន់
6. ពេលកណ្តាស់ ក្អក ត្រូវយកដៃ កន្សែងដៃ ឬ ក្រម៉ាខ្ទប់មុខ ដើម្បីជៀសវាងបាចសាចទៅអ្នកដ៏ទៃទៀត។
7. លាងសម្អាតដៃជាមួយសាប៊ូ ឬផេះឲ្យបានញឹកញាប់ បន្ទាប់ពីប៉ះជាមួយបសុបក្សី រាល់ពេលក្រោយ ជូតសំបោរ ឬចាប់កាន់សត្វចិញ្ចឹមគ្រប់ប្រភេទ និង លាងដៃមុនរាល់ទទួលទានអាហារ
8. បើប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សីត្រូវមានវិធានការការពារជាមុន
9. មិនត្រូវយកមាន់ឬទា ដែលឈឺឬងាប់ មករៀបចំធ្វើជាអាហារត្រូវយកទៅកប់។
10. មិនត្រូវទៅកន្លែងដែលមានជំងឺផ្តាសាយបក្សីកំពុងតែរាតត្បាត បើពុំមានភារកិច្ចចាំបាច់
11. មិនត្រូវបឺត ឬ ជញ្ជក់ក្បាលមាន់ពេលជល់មាន់

## តើអ្នកចិញ្ចឹម អ្នកដឹកជញ្ជូន អ្នកសំលាប់ និង អ្នកលក់ សត្វបក្សីត្រូវបង្ការការឆ្លងយ៉ាងដូចម្តេច?



- ✓ ត្រូវពាក់ម៉ាស់ ស្បែកជើងកវែង និងស្រោមដៃក្នុងពេល ៖
  - ចេញ និងចូល កសិដ្ឋានចិញ្ចឹមសត្វ
  - ពេលដឹកជញ្ជូនសត្វបក្សី តាមរថយន្ត ឬ តាមម៉ូតូ
  - ពេលដំណើរការសំលាប់សត្វបក្សី ជាអាជីព នៅក្នុងផ្សារ និងទីសាធារណៈ
  - ជៀសវាងវាសដៃលើមុខ និងភ្នែកខ្លួនឯង
- ✓ នៅពេលបញ្ចប់សកម្មភាពការងារដូចបានរៀបរាប់ខាងលើ ត្រូវលាង សំអាតដៃ ជាបន្ទាន់ ហើយត្រូវងូតទឹកសំអាតរាងកាយជាមួយសាប៊ូអោយបានស្អាត។ រាល់សំភារៈ ការពារផ្សេងៗ ទៀតត្រូវត្រាំទឹកនិងសាប៊ូហើយបោកសំអាត និងហាលថ្ងៃអោយបានត្រឹមត្រូវ។

## តើអ្នកចំអិនអាហារអាចបង្ការការឆ្លងយ៉ាងដូចម្តេច?

- ✓ មិនត្រូវយកសត្វស្លាបដែលឈឺ ឬ ងាប់មកធ្វើជាអាហារ
- ✓ ត្រូវជ្រើសរើសទិញសាច់បក្សី មាន់ ទា និងស៊ុតពីកន្លែងដែលមានការទទួល ខុសត្រូវ និង ធានា ឬមកពីប្រភពដែលជឿជាក់ថាគ្មានផ្ទុះជំងឺ និងជ្រើសរើស សាច់មាន់មើលស្រស់ ថ្មីគ្មានស្នាមជាំខ្មៅ ចំណែកស៊ុតត្រូវមើលអោយស្រស់ថ្មី គ្មានលាមកជាប់សំបក
- ✓ នៅពេលរៀបចំចំអិនអាហារ មិនត្រូវវាសដៃទៅលើច្រមុះ ភ្នែក មាត់ និងសំភារៈផ្សេងទៀត ដែលមិនចាំបាច់ដូចជា ទូរស័ព្ទដៃជាដើម។



**មេរៀនទី៣៖ សង្ខេបម៉ូឌុល និងការធ្វើតេស្តក្រោយពេលសិក្សា** **រយៈពេល ៥០នាទី**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច ៖

១. រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ

២. វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយពេលសិក្សា

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ មានសរសេរពីវត្ថុបំណងម៉ូឌុល
- ក្រដាសផ្ទាំងធំ មានសារគន្លឹះសម្រាប់ម៉ូឌុលនេះ
- ហ្វឺតសម្រាប់សរសេរ, បង់ស្អិត
- បញ្ជីសំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

**វិធីសាស្ត្របង្រៀន៖**

- ពិភាក្សាក្រុម
- តេស្តក្រោយវគ្គសិក្សា

**ជំហានសកម្មភាព៖**

**បង្ហាញពីវត្ថុបំណងរួម៖**

**សេចក្តីផ្តើម៖** អ្នកសម្របសម្រួលពន្យល់ថា នេះគឺជាមេរៀនចុងក្រោយសម្រាប់ម៉ូឌុលនេះ។

**វត្ថុបំណងទី១៖ រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ (២០នាទី)**

**ពិភាក្សាក្រុម**

- អ្នកសម្របសម្រួល ដឹកនាំសិក្ខាកាមពិភាក្សាពីចំណុចសង្ខេប និងសារគន្លឹះសម្រាប់ម៉ូឌុលនេះ។ អ្នក សម្របសម្រួលត្រូវបិទសារគន្លឹះនៅលើក្រដាសផ្ទាំងធំ ដើម្បីឱ្យសិក្ខាកាមមើល និងអាន។
- បន្ទាប់មក អ្នកសម្របសម្រួល សួរសិក្ខាកាមថា តើមានសំណួរអ្វីទេ?

**សារគន្លឹះ ៖ ចម្លើយចូលរួម៖** ផ្តាសាយមានបីយ៉ាងធំៗ៖

1. ផ្តាសាយតាមរដូវកាល
2. ផ្តាសាយសកល
3. ផ្តាសាយបក្សី

**សារគន្លឹះ ៖ ចម្លើយចូលរួម៖** ផ្តាសាយតាមរដូវកាលមានរោគសញ្ញា៖

1. គ្រុនក្តៅខ្លាំងៗ ចាប់ពី៣៨អង្សា ឡើងទៅ (យកកំដៅ នៅក្រោមក្លៀក)
2. ក្អកស្ងួត
3. ឈឺបំពង់ក
4. ហៀរសំបោរ
5. ឈឺក្បាល
6. ឈឺសាច់ដុំ
7. របិតរហៃ អស់កំលាំងខ្លាំង

ជាទូទៅរយៈពេល សំងំរបស់ជំងឺមានរយៈពេលខ្លី ១-៣ថ្ងៃ។

**សារគន្លឹះ ៖ ចម្លើយចូលរួម៖** ផ្តាសាយបក្សីមានរោគសញ្ញាៈ

## មានរោគសញ្ញាដូចគ្នានឹងផ្តាសាយតាមរដូវកាល

1. គ្រុនក្តៅភ្លាមៗ ចាប់ពី៣៨អង្សា ឡើងទៅ (យកកំដៅ នៅក្រោមក្លៀក)
2. ក្អកស្ងួត
3. ឈឺបំពង់ក
4. ហូរសំបោរ
5. ឈឺក្បាល
6. ឈឺសាច់ដុំ
7. របិតរហៃ អស់កំលាំងខ្លាំង

**រួមជាមួយនឹង**

1. មានប្រវត្តិប៉ះពាល់ជាមួយមាន់ ឬទា ឬបសុបក្សី ឈឺ ឬងាប់ក្នុងអំឡុង៧ថ្ងៃមុនចាប់ផ្តើមឈឺ ឬប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សី និង
2. សញ្ញាផ្លូវដង្ហើម ដូចជា ហត់ ឬពិបាកដកដង្ហើម

**សារគន្លឹះ ៖ ផ្តាសាយសកល**

- ផ្តាសាយសកលជាជំងឺផ្តាសាយប្រភេទថ្មី ដែលឆ្លងយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់
- ជំងឺផ្តាសាយបក្សី ក៏អាចបង្កជាជំងឺផ្តាសាយសកលធ្ងន់ធ្ងរ បើវីរុសបំលែងខ្លួន ដែលអាចឆ្លងយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់

**សារគន្លឹះ ៖ ចម្លើយចូលរួម៖** មូលហេតុនៃជំងឺផ្តាសាយតាមរដូវកាលៈ

- ✓ កង្វះអនាម័យ៖ ក្នុងផ្ទះកខ្វក់ ខោអាវកខ្វក់ មានផ្សែងចង្ក្រាន ផ្សែងបារី មានភក់ជ្រាំ មានលាមកសត្វឬមនុស្ស សំរាម ព្រៃស៊ុបទ្រុប ប្រើប្រាស់ក្រម៉ារួមគ្នា ។ល។
- ✓ នៅជិត ឬនៅជាមួយ ឬ លេងជាមួយ ឬប៉ះពាល់ ឬនិយាយជាមួយអ្នកជំងឺផ្តាសាយ ដោយមិនមានវិធានការការពារជាមុន
- ✓ មិនបានលាងសម្អាតដៃជាមួយសាប៊ូឲ្យបានញឹកញាប់ ជាពិសេស មុនពេល បំបៅដោះកូន មុនពេលបរិភោគ មុនពេលរៀបចំអាហារ និងបញ្ចុកអាហារកូន និងក្រោយពេលចេញពីបង្គន់ ជាដើម។
- ✓ មិនបានទទួលថ្នាំបង្ការសព្វគ្រប់និងត្រឹមត្រូវ
- ✓ អាកាសធាតុប្រែប្រួល

**សារគន្លឹះ ៖ ចម្លើយ៖** ជំងឺផ្តាសាយបក្សីលើមនុស្សបណ្តាលមកពីៈ

1. លេងជាមួយឬប៉ះពាល់បសុបក្សី ឬ ចូលទៅទីកន្លែងដែលមានមេរោគផ្តាសាយបក្សីសាយភាយ ដោយមិនមានវិធានការការពារជាមុន (ប៉ះពាល់ជាមួយបក្សីស្រុក ឬព្រៃ ឈឺ ឬស្លាប់ ដោយ កាន់ សំលាប់ បោចរោម កាប់សាច់ ធ្វើម្ហូបអាហារ)

2. បរិភោគផលិតផលសាច់ឬស៊ុតបសុបក្សី ដែលចំអិនមិនឆ្អិនល្អ
3. ប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សី ដោយមិនមានវិធានការការពារជាមុន

**មូលហេតុដែលនាំឲ្យមានផ្តាសាយសកល គឺបណ្តាលមកពី វីរុសដែលរាលដាលដូចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដូចផ្តាសាយតាមរដូវកាល។**

**សារគន្លឹះ៖ ការថែទាំជាមូលដ្ឋានសម្រាប់អ្នកជំងឺផ្តាសាយតាមរដូវកាលនៅផ្ទះ**

**កុមារអាយុក្រោម៥ឆ្នាំ**

- វិធីបន្ថយក្អក ដែលមានសុវត្ថិភាព៖
  - បំបៅដោះកុមារឱ្យបានញឹកញាប់ជាងធម្មតា (កុមារអាយុក្រោម ៦ខែ បៅដោះសុទ្ធ)
  - ចំពោះកុមារមិនបៅដោះសុទ្ធ ឬអាយុចាប់ពី ៦ខែ ឱ្យទឹកតែក្តៅឧណ្ហៗ ជាមួយទឹកក្រូចឆ្មារ និងស្ករ ឬទឹកឃ្មុំ ឬមួយទឹកតែក្តៅឧណ្ហៗ ជាមួយខ្ញី ក្នុងរសជាតិឡមៗ ឱ្យកុមារផឹក តាមដែលអាចផឹកបាន
- ត្រូវផ្តល់ជាតិទឹកដល់កុមារញ៉ាំឱ្យបានច្រើនដូចជា ទឹកដោះម្តាយ ទឹកដូង ទឹក ។ល។
- ហៀរសំបោរ/កណ្តាស ត្រូវសំអាតច្រមុះកុមារឲ្យបានញឹកញាប់ជាមួយក្រណាត់/កន្សែង/ក្រម៉ាស្អាត។
- លួងលោមកុមារឱ្យញ៉ាំអាហារឱ្យបានញឹកញាប់ បើវាឈឺបំពង់កចូរឱ្យអាហារទន់ៗដូចជាបបរមាន ជីវជាតិគ្រប់គ្រាន់។
- បើក្អកយូរចាប់ពី ៣ថ្ងៃ ត្រូវយកទៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យដែលនៅជិតជាង គេជាបន្ទាន់។
- ក្តៅខ្លួន ស្អំកុមារនឹងក្រណាត់ /កន្សែង/ ក្រម៉ាសើមនៅឃ្លៀក ក ក្រលៀន ។ល។
- មិនត្រូវផ្តល់អង់ទីប៊ីយ៉ូទិកដល់កុមារ
- មិនត្រូវដាក់សេរ៉ូម ឬ ចាក់ថ្នាំតាមសរសៃដល់កុមារ

**ត្រូវបញ្ជូនកុមារមានក្អកផ្តាសាយទៅមូលដ្ឋានសុខាភិបាល បើមានសញ្ញាណាមួយ ខាងក្រោម៖**

- មិនស្ទូវបៅ ឬ ញ៉ាំ ឬ មិនអាចបៅបាន ឬ មិនអាចផឹកបាន។
- ឈឺរឹតតែធ្ងន់ទៅ។
- ចាប់មានគ្រុនក្តៅខ្លាំង។
- ដកដង្ហើមហត់ ឬ ញាប់ជាងធម្មតា។
- ផ្ទាំងទ្រូងផ្នែកខាងក្រោមផតចូលពេលដកដង្ហើមចូល។
- កុមារពុំធូរស្រាលក្រោយរយៈពេល ៣ថ្ងៃ។

**អាយុចាប់ពី៥ឆ្នាំឡើង**

- វិធីបន្ថយក្អក ដែលមានសុវត្ថិភាព៖
  - ឱ្យទឹកតែក្តៅឧណ្ហៗ ជាមួយទឹកក្រូចឆ្មារ និងស្ករ ឬទឹកឃ្មុំ ឬមួយទឹកតែក្តៅឧណ្ហៗ ជាមួយខ្ញី តាមដែលអាចផឹកបាន
  - សំរាកឲ្យបានច្រើន ផឹកទឹកឲ្យបានច្រើន
  - ខ្ពុរមាត់ជាមួយទឹកអំបិល

**សារគន្លឹះ ៖ត្រូវបញ្ជូនកុមារមានគ្រុនក្តៅផ្តាសាយទៅមូលដ្ឋានសុខាភិបាល បើមានសញ្ញាណាមួយ ខាងក្រោម៖**

- មិនសូវបៅ ឬ ញាំ ឬ មិនអាចបៅបាន ឬ មិនអាចផឹកបាន។
- ឈឺរឹតតែធ្ងន់ទៅ។
- ចាប់មានគ្រុនក្តៅខ្លាំង។
- ដកដង្ហើមហត់ ឬ ញាប់ជាងធម្មតា។
- ផ្ទាំងទ្រូងផ្នែកខាងក្រោមផតចូលពេលដកដង្ហើមចូល។
- កុមារពុំធូរស្រាលក្រោយរយៈពេល ៣ថ្ងៃ។

**សារគន្លឹះ ៖ ពេលសង្ស័យថា មានជំងឺផ្តាសាយបក្សីត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖**

1) ត្រូវបញ្ជូនអ្នកជំងឺទៅជួបគ្រូពេទ្យជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតដើម្បីពិនិត្យព្យាបាលឱ្យទាន់ពេលវេលា។
2) កុំផ្តល់ឱសថអាស្ពីរីនដល់អ្នកជំងឺ
3) នៅពេលថែទាំអ្នកជំងឺត្រូវជៀសវាងការប៉ះពាល់ជិតស្និទ្ធជាមួយអ្នកជំងឺដូចជា ការអោប រឺ ថើបជាដើម។
4) ណែនាំដល់អ្នកជំងឺអោយពាក់ម៉ាស់ ឬប្រើក្រម៉ាគ្របច្រមុះ និង មាត់។ចំពោះអ្នកថែទាំក៏ត្រូវពាក់ម៉ាស់ ឬក្រម៉ា ការពារខ្លួនឯងផងដែរ
5) ប្រសិនមានមាន់ទាឈឺឬងាប់ខុសធម្មតា នៅក្នុងភូមិ ត្រូវរាយការណ៍ជាបន្ទាន់ទៅក្រសួងកសិកម្ម តាមទូរស័ព្ទលេខ៖ **០១២ ២១៤ ៩៧០** ឬ **០១២ ៨៣៣ ៧៩៥**
6) បើសង្ស័យថានរណាម្នាក់មានជំងឺផ្តាសាយបក្សីសូមបញ្ជូនអ្នកជំងឺទៅពិគ្រោះជាមួយគ្រូពេទ្យជាបន្ទាន់ឬទូរស័ព្ទទៅក្រសួងសុខាភិបាលតាមទូរស័ព្ទលេខ៖ **១១៥** ឬ**០១២ ៤៨៨ ៩៨១** ឬ **០៨៩ ៦៦៩ ៥៦៧**។

**ពេលមានផ្ទុះជំងឺផ្តាសាយរាតត្បាតជាសកលត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖**

1. ត្រូវរាយការណ៍ជាបន្ទាន់ប្រសិនបើក្នុងកន្លែងណាមួយមានអ្នកជំងឺកើតជំងឺផ្តាសាយច្រើន
2. មិនត្រូវធ្វើដំណើរទៅកន្លែងដែលមានមនុស្សកកកុញ ឬ កន្លែងដែលមានជំងឺផ្តាសាយច្រើននៅទីនោះ
3. បើមានអ្នកទើបតែមកពីតំបន់ផ្ទុះនោះ ត្រូវឱ្យអ្នកនោះលាងសំអាតខ្លួន និង ពាក់ម៉ាស់ ហើយនៅឱ្យដាច់ពីសមាជិកគ្រួសារ និង ឱ្យប្រើសំភារៈប្រើប្រាស់ ដោយឡែក
4. ត្រូវលាងដៃជាមួយសាប៊ូ និងទឹកឱ្យបានញឹកញាប់
5. ត្រូវប្រើក្រដាសអនាម័យ កន្សែងដៃ ឬ ក្រម៉ា ខ្ទប់ច្រមុះ និងមាត់នៅពេលក្អក ឬកណ្តាស់ និង បោះចោលក្រដាសអនាម័យដោយប្រុងប្រយ័ត្ន និង បោកគក់ កន្សែងដៃ ឬក្រម៉ាជាមួយសាប៊ូ និងទឹករួចហាលកណ្តាល ថ្ងៃឱ្យស្ងួតល្អ
6. ត្រូវប្រាប់ទៅអ្នកជិតខាង សាច់ញាតិ ដើម្បីរកវិធីព្យាបាលនៅផ្ទះ ឬទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលជិតបំផុត ឬក៏ទៅកន្លែងព្យាបាលបណ្តោះអាសន្នដែលរៀបចំឡើងដោយអាជ្ញាធរមូលដ្ឋាន។

**សារគន្លឹះ ៖ ចម្លើយ ៖ អំពីវិធានការការពារជំងឺផ្តាសាយតាមរដូវកាល៖**

1. ត្រូវមានអនាម័យល្អ៖ សម្អាតក្នុងផ្ទះឲ្យបានស្អាតជាប្រចាំ បោកគក់ខោអាវ មិនត្រូវ ឲ្យមានផ្សែងចង្រ្កាន ឬផ្សែងបារីនៅក្នុងផ្ទះ បោសសម្អាតសំរាម លាមកសត្វ/មនុស្ស លុបបំបាត់ភក់ជ្រាំ និងកាប់ឆ្ការព្រៃជុំវិញផ្ទះ មិនត្រូវប្រើប្រាស់ក្រម៉ារួមគ្នា ។ល។
2. មិនត្រូវនៅជិត ឬនៅជាមួយ ឬ លេងជាមួយ ឬប៉ះពាល់ ឬនិយាយជាមួយអ្នកជំងឺផ្តាសាយ
3. ត្រូវលាងសម្អាតដៃជាមួយសាប៊ូឲ្យបានញឹកញាប់ជាពិសេសមុនពេល បំបៅដោះកូន មុនពេលបរិភោគ រៀបចំអាហារ បញ្ចុក អាហារកូន និងក្រោយពេលចេញពីបង្គន់ ជាដើម។
4. យកកុមារទៅទទួលថ្នាំបង្ការឲ្យបានគ្រប់តាមកាលកំណត់របស់គ្រូពេទ្យ
5. ស្លៀកពាក់ខោអាវឲ្យកុមារឲ្យជិត ឬកុំឲ្យត្រូវទឹកភ្លៀង

**សារគន្លឹះ ៖ ចម្លើយ ៖ អំពីវិធានការការពារជំងឺផ្តាសាយបក្សី**

1. មិនត្រូវលេងជាមួយឬប៉ះពាល់បសុបក្សី ឬ ចូលទៅទីកន្លែងដែលមានមេរោគផ្តាសាយបក្សីសាយភាយដោយមិនមានវិធានការការពារជាមុន (ប៉ះពាល់ជាមួយបក្សីស្រុក ឬព្រៃ ឈឺ ឬស្លាប់ដោយ កាន់ សំលាប់ បោចរោម កាប់សាច់ ធ្វើម្ហូបអាហារ)
2. មិនត្រូវបរិភោគផលិតផលសាច់ឬស៊ុតបសុបក្សី ដែលចំអិនមិនឆ្អិនល្អ
3. មិនត្រូវប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សី ដោយមិនមានវិធានការការពារជាមុន
4. នៅឲ្យឆ្ងាយពីសត្វបក្សីឈឺឬងាប់ ជាពិសេសកុមារ ។
5. ហាមក្មេងកុំឱ្យចូលរួមទស្សនាជល់មាន់
6. ពេលកណ្តាស់ ក្អក ត្រូវយកដៃ កន្សែងដៃ ឬ ក្រម៉ាខ្ទប់មុខ ដើម្បីជៀសវាងបាចសាចទៅអ្នកដ៏ទៃទៀត។
7. លាងសម្អាតដៃជាមួយសាប៊ូ ឬផេះឲ្យបានញឹកញាប់ បន្ទាប់ពីប៉ះជាមួយបសុបក្សី រាល់ពេលក្រោយ ជូតសំបោរ ឬចាប់កាន់សត្វចិញ្ចឹមគ្រប់ប្រភេទ និង លាងដៃមុនរាល់ទទួលទានអាហារ
8. បើប៉ះពាល់ជាមួយអ្នកជំងឺផ្តាសាយបក្សីត្រូវមានវិធានការការពារជាមុន
9. មិនត្រូវយកមាន់ឬទា ដែលឈឺឬងាប់ មករៀបចំធ្វើជាអាហារត្រូវយកទៅកប់។
10. មិនត្រូវទៅកន្លែងដែលមានជំងឺផ្តាសាយបក្សីកំពុងតែរាតត្បាត បើពុំមានភារកិច្ចចាំបាច់
11. មិនត្រូវបឺត ឬ ជញ្ជក់ក្បាលមាន់ពេលជល់មាន់

**វត្ថុបំណងទី ២៖ វាយតម្លៃចំណេះដឹងតាមរយៈការធ្វើតេស្តក្រោយពេលសិក្សា (៣០នាទី)**

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថា មុននឹងយើងបញ្ចប់ម៉ូឌុលនេះ យើងនឹងធ្វើតេស្តក្រោយពេលសិក្សាខ្លីមួយ។ តេស្តនេះគឺដូចគ្នានឹងតេស្តមុនពេលសិក្សាដែលអ្នកទាំងអស់គ្នាបានធ្វើមុនចាប់ផ្តើមម៉ូឌុលនេះដែរ។ ការធ្វើតេស្តបែបនេះ គឺដើម្បីវាស់ពីចំណេះដឹងសិក្ខាកាមនៅមុននឹងក្រោយពេលសិក្សា ដើម្បីចង់ដឹងថា តើអ្នកទាំងអស់គ្នា បានទទួលចំណេះដឹងប៉ុណ្ណាពីវគ្គនេះ។ ដូច្នេះសូមកុំព្រួយបារម្ភ ប្រសិនបើអ្នកមិនចេះសំណួរណាមួយនោះ។

បន្ទាប់មក ចែកសំណួរតេស្តដល់សិក្ខាកាម។

ក្រោយពីសិក្ខាកាមបានធ្វើតេស្តក្រោយពេលសិក្សាចប់ អ្នកសម្របសម្រួលត្រូវបូកសរុបចម្លើយ ហើយប្រៀប-ធៀបនឹងលទ្ធផលតេស្តមុនពេលសិក្សា។

## សំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

សំណួរ "ត្រូវ ឬ ខុស" (សំណួរត្រូវ ត្រូវបានបង្ហាញក្នុងប្រអប់ខ្មៅ)

| | | |
|---|---|---|
| ១. ជំងឺផ្តាសាយជាជំងឺធម្មតាដែលតែងកើតមានជាញឹកញាប់តាមរដូវកាល | ត្រូវ | ខុស |
| ២. កុមារមានគ្រុនផ្តាសាយ និង ក្អក តែងជួបញឹកញាប់ ប៉ុន្តែជួនកាលវាអាចវិវត្តទៅជាធ្ងន់ធ្ងរ ដែលអាចមានគ្រោះថ្នាក់ដល់អាយុជីវិត បើពុំព្យាបាលឱ្យបានត្រឹមត្រូវ។ | ត្រូវ | ខុស |
| ៣. រាល់ជំងឺទាំងអស់របស់កុមារទាំងអស់អាចព្យាបាលនៅផ្ទះ ដោយមានប្រសិទ្ធិភាពបំផុត និងការយកកុមារទៅមណ្ឌលសុខភាពពុំចាំបាច់ទេ។ | ត្រូវ | ខុស |
| ៤. ជំងឺផ្តាសាយបក្សី គឺជាជំងឺផ្តាសាយមួយ ដែលជាធម្មតាចំលងរវាងសត្វបក្សីឈឺទៅបក្សីផ្សេងទៀត ប៉ុន្តែជួនកាល វាអាចចំលងពីបក្សីមកមនុស្សនាំឲ្យកើតផ្តាសាយបក្សីលើមនុស្ស | ត្រូវ | ខុស |
| ៥. ជំងឺផ្តាសាយបក្សីលើមនុស្ស ជាជំងឺធ្ងន់ធ្ងរ ដែលតំរូវឲ្យមានការ ធ្វើការព្យាបាលនៅមន្ទីរពេទ្យ។ | ត្រូវ | ខុស |
| ៦. ប្រសិនមានមាន់ទាឈឺឬងាប់ត្រូវរាយការណ៍ជាបន្ទាន់តាមទូរស័ព្ទ៖ ០១២ ២១៤ ៩៧០ ឬ០១២ ៨៣៣ ៧៩៥ | ត្រូវ | ខុស |
| ៧.បើសង្ស័យថានរណាម្នាក់មានជំងឺផ្តាសាយបក្សីត្រូវបញ្ជូនអ្នកជំងឺទៅជួបគ្រូពេទ្យជាបន្ទាន់ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុតដើម្បីពិនិត្យព្យាបាលឱ្យទាន់ពេលវេលា ឬទូរស័ព្ទទៅលេខ៖ ១១៥ ឬ០១២ ៤៨៨ ៩៨១ ឬ០៨៩ ៦៦៩ ៥៦៧។ | ត្រូវ | ខុស |
| ៨. ក្រុមគ្រប់គ្រងភូមិ អាចជួយប្រជាជននៅក្នុងភូមិរបស់ខ្លួនសង្គ្រោះជីវិតរបស់មនុស្សគ្រប់វ័យ បើពួកគាត់បានទទួលការបណ្តុះបណ្តាល អំពីសញ្ញាគ្រោះថ្នាក់ និងសញ្ញាតម្រូវឱ្យបញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាព។ | ត្រូវ | ខុស |

៩. តើអ្នកអាចធ្វើអ្វីដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លង វីរុសហាស់ប្រាំអិនមួយ? ចម្លើយ ឃ

ក.កុំ លេងជាមួយ ឬ ប៉ះពាល់បសុបក្សី ឬ ចូលទៅទីកន្លែងដែលមានមេរោគផ្តាសាយបក្សីសាយភាយ ដោយមិនមានវិធានការការពារជាមុន (ប៉ះពាល់ជាមួយបក្សីស្រុក ឬព្រៃ ឈឺ ឬស្លាប់ ដោយ កាន់ សំលាប់ បោចរោម កាប់សាច់ ធ្វើម្ហូបអាហារ)

ខ.កុំបរិភោគផលិតផលសាច់ឬស៊ុតបសុបក្សី ដែលចំអិនមិនឆ្អិនល្អ

គ.កុំប៉ះពាល់ជាមួយ អ្នកជំងឺផ្តាសាយបក្សី ដោយមិនមានវិធានការការពារជាមុន

ឃ. ទាំងអស់ខាងលើ

១០. តើត្រូវធ្វើដូចម្តេចដើម្បីការពារខ្លួនអ្នក ប្រសិនជាអ្នកប៉ះពាល់ជាមួយបសុបក្សី ឬ សត្វស្លាប?ចម្លើយ ឃ

ក. លាងសម្អាតដៃជាមួយសាប៊ូ ឬផេះឲ្យបានញឹកញាប់

ខ.តាមដានមើលមានគ្រុនក្តៅលើសពី៣៨ឬទេ?

គ. មានក្អក ឬពិបាកដកដង្ហើម

ឃ. បើមានសញ្ញា ក ខ និងគ ត្រូវទៅមូលដ្ឋានសុខាភិបាលជាបន្ទាន់។

១១. តើត្រូវធ្វើដូចម្តេចដើម្បីរៀបចំនិងបរិភោគ សាច់ឬស៊ុតបសុបក្សី ឬ សត្វស្លាប? (ចម្លើយៈ ង)

ក. ប្រើក្រម៉ាឬម៉ាស ដើម្បីខ្ទប់មាត់ឬច្រមុះមុនពេលយើងប៉ះពាល់មាន់ទា

ខ. ស្រុះមាន់ទានឹងទឹកក្តៅមុនបោចរោម

គ. ប្រមូលរោមមាន់ទានិងកាកសំណល់ផ្សេងទៀតយកទៅកប់ឬដុតចោល

ឃ. លាងសំអាតដៃនិងរបស់របរប្រើប្រាស់ដូចជាចាន កាំបិត ដែលប្រើប្រាស់រួចជាមួយផេះ ឬសាប៊ូឬផេះឲ្យស្អាតត្រឹមត្រូវ។

ង. ទាំងអស់ខាងលើ

១២. ក្នុងអំឡុងមានការរាតត្បាតប្រសិនជាមានបសុបក្សី ឬ មាន់ទាងាប់តើយើងអាចយកមកធ្វើម្ហូបបាន ឬទេ? (ចម្លើយៈ ខ)

ក. បាទ/ចាស

ខ. ទេ

១៣.តើត្រូវធ្វើដូចម្តេចប្រសិនជាអ្នកប៉ះជាមួយលាមកបសុបក្សី ក្នុងតំបន់មានផ្តាសាយបក្សី និងធ្លាក់ខ្លួនឈឺ (ចម្លើយៈ ក និង ឃ)

ក.ទៅពិគ្រោះជាមួយគ្រូពេទ្យជាបន្ទាន់ឬទូរស័ព្ទទៅលេខៈ ១១៥ ឬ០១២ ៤៨៨ ៩៨១ ឬ០៨៩ ៦៦៩ ៥៦៧។

ខ.ព្យាបាលដោយខ្លួនឯង

គ. ទិញថ្នាំក្នុងភូមិ

ឃ. ទៅមូលដ្ឋានសុខាភិបាលដែលនៅជិតផ្ទះជាបន្ទាន់

១៤. គូសរង្វង់ជុំវិញសញ្ញាគ្រោះថ្នាក់ របស់កុមារដែលឈឺធ្ងន់ ដែលមានន័យថាកុមារនោះត្រូវព្យាបាល នៅ មូលដ្ឋានសុខាភិបាល។ (ចម្លើយៈ ក និង ខ)

ក. កុមារពុំអាចញាំ ឬ ផឹក ឬ បៅដោះបាន

ខ. កុមារពិបាកដកដង្ហើម

គ. កុមារក្តៅខ្លួនមធ្យមរយៈពេល១ថ្ងៃ

១៥. គូសរង្វង់ជុំវិញកន្លែង២ ដែលទីនោះក្រុមគ្រប់គ្រងភូមិអាចទទួលបាននូវព័ត៌មានបន្ថែមអំពីអ្វី ដែលពួកគាត់បានរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាល។ (ចម្លើយៈ ក និងគ)

ក. សាកសួរបុគ្គលិកមណ្ឌលសុខភាព

ខ. សាកសួរគ្រូឱសថបូរាណ

គ. អានមេរៀនដែលចែកឱ្យ

# ម៉ូឌុលទី៥

## ជំងឺគ្រុនឈាម និង
## ជំងឺដង្កូវពោះវៀន
## ( ព្រូន )

# សៀវភៅបណ្តុះបណ្តាលក្រុមគ្រប់គ្រងភូមិ

## ម៉ូឌុលទី៥ ជំងឺគ្រុនឈាម និង ជំងឺដង្កូវពោះវៀន (ព្រូន)

| ចំណងជើងមេរៀន | វត្ថុបំណងនៃការសិក្សា | រយៈពេល* |
|---|---|---|
| ១.ការចាប់ផ្តើម និងការសាកល្បងមុនសិក្សា | ១–រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ<br>២–អនុវត្តការសាកល្បងមុនការសិក្សា | ៣០នាទី |
| ២. ជំងឺគ្រុនឈាម | ១–កំណត់និយមន័យនិងអាការៈនៃជំងឺគ្រុនឈាម<br>២–ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺគ្រុនឈាម<br>៣–រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺគ្រុនឈាម<br>៤– រៀបរាប់ពីរៀបរាប់ពីសញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាមដែលត្រូវបញ្ជូនជាបន្ទាន់ទៅគ្រឹះស្ថានសុខាភិបាល<br>៥–រៀបរាប់ពីវិធានការការពារជំងឺគ្រុនឈាម | ២ម៉ោង |
| ២. ជំងឺដង្កូវពោះវៀន (ព្រូន) | ១–កំណត់និយមន័យនិងលក្ខណៈសំគាល់នៃជំងឺដង្កូវពោះវៀន<br>២–ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺដង្កូវពោះវៀន<br>៣–រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺដង្កូវពោះវៀន<br>៤–រៀបរាប់ពីវិធានការការពារការឆ្លងជំងឺដង្កូវពោះវៀន | ២ម៉ោង |
| ៣. ការសង្ខេប និងការសាកល្បងក្រោយសិក្សា | ១– កំណត់បាននូវសិក្ខាកាមត្រូវការជំនួយ ឬការគាំទ្របន្ថែម<br>២– អនុវត្តការសាកល្បងក្រោយការសិក្សា | ៣០នាទី |
| **សរុប** | | **៥ម៉ោង** |

* ថ្ងៃបណ្តុះបណ្តាលនិមួយៗមានរយៈពេលសរុបម៉ោង (ព្រឹកម៉ោង៨ព្រឹក ដល់៥ល្ងាច)

- រយៈពេលបណ្តុះបណ្តាល៥ម៉ោង (ពេលព្រឹក៣ម៉ោង និងរសៀល២ម៉ោង)
- សម្រាក ២ម៉ោងសម្រាប់អាហារថ្ងៃត្រង់និង១ម៉ោងសម្រាប់អាហារសម្រន់ (ព្រឹក៣០នាទី និងរសៀល៣០នាទី)

# សេចក្តីណែនាំកម្មវិធីសិក្សា

## ម៉ូឌុលទី ៥៖ អំពីជំងឺគ្រុនឈាម

### មេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងដំបូង រយៈពេលសរុប ៣០នាទី

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្ត្របង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ | គោលបំណង នៃម៉ូឌុលទី ៥ | បាឋកថា | ផ្ទាំងក្រដាសធំ ដែលមាន សរសេរអំពីគោលបំណងនៃម៉ូឌុលនេះ | ១៥ នាទី | សំណួរ-ចម្លើយ |
| ២.អនុវត្តការសាកល្បងមុនការសិក្សា | ការសាកល្បង មុនការសិក្សា | ការសាកល្បង មុនការសិក្សា | ឯកសារសាកល្បងមុនការសិក្សា<br>ក្តាខៀន ហ្វឺត<br>ក្រដាសផ្ទាំងធំ | ១៥ នាទី | ការត្រួតពិនិត្យ |

### មេរៀនទី ២៖ ជំងឺគ្រុនឈាម រយៈពេលសរុប២ម៉ោង

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្ត្របង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. កំណត់និយមន័យនិង អាការៈ នៃជំងឺគ្រុនឈាម | – និយមន័យជំងឺគ្រុនឈាម<br>– អាការៈនៃជំងឺគ្រុនឈាម | – សំណួរបំផុសគំនិត | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ១៥ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺគ្រុនឈាម | - មូលហេតុនិងសារគន្លឹះដែលបង្កឲ្យមានជំងឺគ្រុនឈាម | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>– សន្លឹករូបភាពទំព័រទី១១៩ ១២០ និង១២១ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ៣. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺគ្រុនឈាម | – ស្គាល់សញ្ញាដែលត្រូវនាំកុមារទៅគ្រឹះស្ថានសុខាភិបាល | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ | ២៥ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៤. រៀបរាប់ពីរៀបរាប់ពីសញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាមដែលត្រូវបញ្ជូនជាបន្ទាន់ទៅគ្រឹះស្ថានសុខាភិបាល | សញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាមដែលត្រូវបញ្ជូនជាបន្ទាន់ទៅគ្រឹះស្ថានសុខាភិបាល | – ពិភាក្សាក្រុមធំ | –ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>–ក្តាខៀន ហ្វឺត<br>–ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ<br>–សន្លឹករូបភាពទំព័រទី១២៣ | ២០ នាទី | សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៥. រៀបរាប់ពីវិធានការការពារជំងឺគ្រុនឈាម | – វិធានការការពារ និងសារគន្លឹះ | – ពិភាក្សាក្រុមធំ | –ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>–ក្តាខៀន ហ្វឺត<br>–ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ<br>–សន្លឹករូបភាពទំព័រទី១២៤ ១២៥និង១២៦ | ៣០ នាទី | សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

## មេរៀនទី ៣៖ ជំងឺដង្កូវពោះវៀន                    រយៈពេលសរុប២ម៉ោង

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្រ្តបង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. កំណត់និយមន័យនិងលក្ខណៈសំគាល់នៃជំងឺដង្កូវពោះវៀន | – និយមន័យជំងឺដង្កូវពោះវៀន<br>– អាការៈនៃជំងឺដង្កូវពោះវៀន | – សំណួរបំផុសគំនិត | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្រ្តៃ<br>– សន្លឹករូបភាពទំព័រទី១២៩ និង១៣០ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| ២. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺដង្កូវពោះវៀន | - មូលហេតុនិងសារគន្លឹះដែលបង្កឲ្យមានជំងឺដង្កូវពោះវៀន | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>– សន្លឹករូបភាពទំព័រទី១៣១ និង១៣២ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៣. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺដង្កូវពោះវៀន | – ស្គាល់សញ្ញាដែលត្រូវនាំកុមារទៅគ្រឹះស្ថានសុខាភិបាល | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ | ៣០ នាទី | – សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |
| ៤. រៀបរាប់ពីវិធានការការពារជំងឺដង្កូវពោះវៀន | – វិធានការការពារនិងសារគន្លឹះ | – ពិភាក្សាក្រុមធំ | – ក្រដាសធំផ្ទាំងមានសរសេរ អំពីវត្ថុបំណងនៃការសិក្សា<br>– ក្តាខៀន ហ្វឺត<br>– ក្រដាសផ្ទាំងធំ បង់ស្អិត និងកន្ត្រៃ<br>សន្លឹករូបភាពទំព័រទី១៣៣ ១៣៤ និង១៣៥ | ៣០ នាទី | សំណួរ-ចម្លើយ<br>– ចម្លើយតបពីក្រុមពិភាក្សា |

## មេរៀនទី ៤៖ ការសង្ខេប និងការសាកល្បងក្រោយសិក្សា រយៈពេលសរុប ៣០នាទី

| វត្ថុបំណង | ខ្លឹមសារ | វិធីសាស្ត្របង្រៀន | សម្ភារៈជំនួយ | រយៈពេល | ការវាយតម្លៃ |
|---|---|---|---|---|---|
| ១. កំណត់បាននូវសិក្ខាកាមណា ដែលចាំបាច់ត្រូវការជំនួយ ឬ ការគាំទ្របន្ថែម | – ដំណោះស្រាយបញ្ហានានា និងសំណូមពររបស់ សិក្ខាកាម | – ពិភាក្សាក្រុម | – ផ្ទាំងក្រដាសធំ មានសរសេរ អំពីវត្ថុបំណងការសិក្សា<br>– ក្រដាសផ្ទាំងធំ<br>– ក្តាខៀន ហ្វឺត | ១៥ នាទី | – សំណួរ-ចម្លើយ |
| ២. អនុវត្តការសាកល្បងក្រោយការសិក្សា | ការសាកល្បងក្រោយការសិក្សា | សាកល្បងក្រោយការសិក្សា | ឯកសារសាកល្បងក្រោយការសិក្សា | ១៥ នាទី | ការត្រួតពិនិត្យ |

# គម្រោងមេរៀន

## ចំណុចដើងមេរៀនទី ១៖ ការចាប់ផ្តើម និងការសាកល្បងមុនការសិក្សា រយៈពេល ៣០នាទី

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

១. រៀបរាប់ពីគោលបំណងនៃការបណ្តុះបណ្តាលថ្ងៃនេះ

២. អនុវត្តការសាកល្បងមុនការសិក្សា។

**សម្ភារៈជំនួយបង្រៀន៖**

- ផ្ទាំងក្រដាសធំ ដែលមានសរសេរអំពីវត្ថុបំណាងសិក្សាថ្ងៃនេះផងដែរ
- ឯកសារសំណួរសាកល្បងមុនការសិក្សា ដែលបានថតចម្លងរួច សម្រាប់សិក្ខាកាមនីមួយៗ

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- ការសាកល្បងមុនការសិក្សា

**ជំហានសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖ សូមស្វាគមន៍ម្តងទៀត ចំពោះកម្មវិធីបណ្តុះបណ្តាលម៉ូឌុលទី៥របស់យើង។ យើងសង្ឃឹមថា អ្នកទទួលបាន នូវបទពិសោធន៍ល្អៗច្រើន កាលពីម៉ូឌុលមុនៗដូចជាអ្នកបានសាកល្បង នូវសកម្មភាពជាក្រុមក្រុមគ្រប់គ្រងភូមិ របស់អ្នក។ យើងនឹងពិភាក្សាគ្នាអំពីបទពិសោធន៍ខ្លះៗរបស់អ្នកនៅថ្ងៃនេះ។ យើងពេញចិត្តនឹងស្តាប់យោបល់ និងគំនិតផ្សេងៗរបស់អ្នកណាស់។

បន្តិចទៀត យើងនិងពិភាក្សាច្រើនអំពីជំងឺគ្រុនឈាម មូលហេតុ របៀបព្យាបាល ការស្វែងរកការថែទាំពេលមានសញ្ញាគ្រោះថ្នាក់ និងការការពារ ។

**វត្ថុបំណងទី ១៖ រៀបរាប់ពីគោលបំណង នៃការបណ្តុះបណ្តាលថ្ងៃនេះ**

➢ បាឋកថា

ការអនុវត្តអនាម័យល្អ ដែលជាការរក្សាខ្លួនយើង និងបរិស្ថានជុំវិញផ្ទះរបស់យើង ឱ្យបានស្អាត គឺជាមធ្យោបាយមួយ ក្នុង ចំណោមមធ្យោបាយដ៏ល្អបំផុត ដើម្បីជៀសវាងការកើតជំងឺមានជំងឺគ្រុនឈាម និងជំងឺផ្សេងៗទៀត។ ការប្រព្រឹត្តិដែលមានអនាម័យល្អប្រសើរជាងការចំណាយប្រាក់ ការចំណាយពេលវេលា ដើម្បីព្យាបាលជំងឺដែលបណ្តាលមកពីការប្រព្រឹត្តិគ្មានអនាម័យ។ ដូច្នេះ គោលបំណងរបស់ យើងនៅថ្ងៃនេះគឺ ៖

- ពិភាក្សាអំពីជំងឺគ្រុនឈាម និងជំងឺដង្កូវពោះវៀន

- ពិភាក្សាថាហេតុអ្វីអនាម័យល្អ និងរក្សាបរិស្ថានជុំវិញផ្ទះឲ្យបានស្អាត មានសារៈសំខាន់ចំពោះសុខភាពយើង ជាពិសេសជៀសវាងពីជំងឺគ្រុនឈាមបាន និងជំងឺដង្កូវពោះវៀន
- ពិភាក្សាថា តើត្រូវអនុវត្តអនាម័យល្អនៅផ្ទះរបស់យើងដូចម្តេចដើម្បីការពារកុំឲ្យមានជំងឺគ្រុនឈាមនិងជំងឺដង្កូវពោះវៀន

**ចំណុចបំណងទី ២៖ អនុវត្តការសាកល្បងមុនការសិក្សា**

➢ ការសាកល្បងមុនការសិក្សា

មុនពេលយើងចាប់ផ្តើម យើងចង់ឱ្យអ្នកទាំងអស់គ្នា ធ្វើសំណួរសាកល្បងមួយខ្លីៗ។ ប្រហែលជាអ្នកនៅចាំ បានថា កាលពីលើកមុនសំណួរសាកល្បងនេះ នឹងជួយអ្នកសម្របសម្រួលឱ្យរកឃើញ នូវវិធីសាស្រ្តល្អបំផុតដែលជួយ ដល់ការរៀនសូត្រនៅក្នុងវគ្គនេះ។ សូមកុំបារម្ភ ប្រសិនបើអ្នកមិនដឹងរាល់ចម្លើយទាំងអស់។ គ្រាន់តែសាកល្បង ឆ្លើយឱ្យបានល្អតាមដែលអាចធ្វើបាន។ មុនពេលយើងចាប់ផ្តើម តើអ្នកមានសំណួរអ្វីទេ?

១. ចែកសំណួរសាកល្បងមុនការសិក្សាដល់សិក្ខាកាមម្នាក់មួយច្បាប់ និងសុំឱ្យពួកគាត់ធ្វើរៀងៗខ្លួន។

២. រក្សាទុកពិន្ទុនេះដើម្បីប្រៀបធៀប ជាមួយនឹងពិន្ទុសាកល្បងក្រោយការសិក្សា។

**សំណួរសាកល្បងមុន និងក្រោយការសិក្សា**

សំណួរត្រូវ ឬ ខុស (ចម្លើយត្រឹមត្រូវ គឺនៅក្នុងប្រអប់ពណ៌ខ្មៅ)

| | | |
|---|---|---|
| ១. ជំងឺគ្រុនឈាមជា ជំងឺឆ្លង និងរាតត្បាត បណ្តាលពី មូសខ្លាញ់ខាំ ពិសេសពេលថ្ងៃ | ត្រូវ | ខុស |
| ២. មូសខ្លាញ់កើតចេញពីដង្កូវទឹក ដែលកើតនៅក្នុងទឹកដក់ | ត្រូវ | ខុស |

៣. សូមគូសធីក នូវចម្លើយដែលជាមូលហេតុនាំឲ្យកើតដង្កូវទឹក។ ចម្លើយត្រឹមត្រូវគឺ ទាំងអស់

☐ ការស្តុកទឹកទុកនៅក្នុងពាង/ អាងទឹកដោយពុំបានគ្របឲ្យបានជិតល្អ

☐ បោះចោលពាសវាលពាសកាល នូវកាកសំណល់ សំបកកំប៉ុង សំបកកង់ឡានចាស់ៗ វត្ថុបាក់បែក សំបកដូង សំបកខ្ទៅខ្ចង ដែលជាមូលហេតុធ្វើឲ្យមានដក់ទឹក ជម្រកមូសខ្លា

☐ រដូវភ្លៀងធ្លាក់

៤. សូមគូសធីក នូវចម្លើយត្រឹមត្រូវសំរាប់កំចាត់ដង្កូវទឹក។ ចម្លើយត្រឹមត្រូវគឺ ទាំងអស់

☐ លាងពាង/អាងទឹក ធុងទឹកកុំឲ្យមានដង្កូវទឹក ឲ្យបានជារៀងរាល់អាទិត្យ

☐ ប្រមូលរាល់វត្ថុដែលដក់ទឹក នៅជុំវិញបរិវេណផ្ទះយកទៅដុត ឬកប់ចោលឲ្យបានជារៀងរាល់អាទិត្យ

☐ ខាប់ ក្រឡ ចានដាក់ទឹកសំរាប់ មាន់ ទា ទូកដែលដាក់លើគោកសំរាប់បិទជ័រទឹកត្រូវចាំបាច់ផ្កាប់

ចាក់ទឹកចោលឲ្យបានជាទៀងរាល់អាទិត្យ ឬផ្កាប់ចុះ

☐ ចានទម្រជើងទូត្រូវចាំបាច់ដាក់អំបិលបន្តិច

☐ ដាក់ត្រី ៧ ពណ៌ក្នុងពាង/អាងទឹកឲ្យស៊ីដង្កូវទឹក ឬ ដាក់ថ្នាំបាណកឃាដសម្លាប់ដង្កូវទឹក ដូចជា ថ្នាំអាបេត ឬ ប៊ីធីអាយ ឬ គ្របពាង/អាងទាំងនោះឲ្យបានជិតល្អ។

៥. តើមូសខ្លាញីខាំមនុស្សនៅពេលណា?សូមគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ។ ចម្លើយត្រឹមត្រូវគឺ ក ខ គ និង ឃ

ក. ពេលព្រឹក

ខ. ពេលថ្ងៃ

គ. ពេលរសៀល

ឃ. ពេលល្ងាច

ង. ពេលយប់

៦. តើត្រូវធ្វើដូចម្តេចដើម្បីកុំឲ្យមូសខ្លាញីខាំ?

ក. ជានិច្ចជាកាលដេកក្នុងមុង ឬ មុងជ្រលក់ថ្នាំ ពិសេសពេលដេកពេលថ្ងៃ ។

ខ. ផ្ទះត្រូវបើកទ្វារបង្អួចឲ្យមានពន្លឺថ្ងៃចេញចូល និងខោអាវត្រូវបត់ទុកដាក់ឲ្យបានត្រឹមត្រូវ។

គ. កាប់ឆ្ការព្រៃស៊ុបទ្រុបនៅជុំវិញផ្ទះឲ្យអស់ ។

ឃ. ត្រូវស្លៀកពាក់ខោអាវឲ្យបានជិតល្អ ហើយឲ្យកុមារលេងនៅកន្លែងណាដែលមានពន្លឺថ្ងៃចេញចូលជានិច្ច កុំឲ្យកុមារលេងកន្លែងងងឹត និងដេកក្នុងមុងនៅពេលថ្ងៃ ។

ង. ការធ្វើអនាម័យសំអាតលំនៅដ្ឋានរៀងៗខ្លួន

ច. បំបាត់ដង្កូវទឹកដោយៈ

- លាងពាងឬអាងទឹក ធុងទឹក ថូផ្កាកុំឲ្យមានដង្កូវទឹក ឲ្យបានជាទៀងរាល់អាទិត្យ
- ប្រមូលរាល់វត្ថុដែលដក់ទឹក នៅជុំវិញបរិវេណផ្ទះយកទៅដុត ឬកប់ចោល ឲ្យបានជាទៀងរាល់អាទិត្យ
- ខាប់ ក្រឡ ចានដាក់ទឹកសំរាប់មាន់ ទា ទូកដែលដាក់លើគោកសំរាប់បិទជ័រទឹកត្រូវចាំបាច់ផ្កាប់ចាក់ទឹកចោលឲ្យបានជាទៀងរាល់អាទិត្យ ឬផ្កាប់ចុះ
- ចានទម្រជើងទូត្រូវចាំបាច់ដាក់អំបិលបន្តិច
- ដាក់ត្រី ៧ពណ៌ក្នុងពាង ឬអាងទឹក ដើម្បីឲ្យស៊ីដង្កូវទឹក ឬ ដាក់ថ្នាំអាបេត ឬថ្នាំប៊ីធីអាយ ឬ គ្របពាង/អាងទាំងនោះឲ្យបានជិតល្អ

៧. តើពេលណាដែលសង្ស័យថាមនុស្សម្នាក់ឬកុមារមានជំងឺគ្រុនឈាម?ចម្លើយត្រឹមត្រូវទាំងអស់

ក. កុមារក្តៅខ្លួន(គ្រុនក្តៅ) ៣៩ ដល់ ៤០អង្សាសេ រយៈពេល ២ ទៅ ៧ ថ្ងៃ

ខ. កុមារក្អួត

គ. កុមារដេកសន្លឹម ឬឡេះឡះ

ឃ.មានចំណុចក្រហមក្រោមស្បែក

ង. មានសញ្ញាចេញឈាមណាមួយដូចជា៖ ឈាមច្រមុះ ឈាមអញ្ចាញធ្មេញ ជុះឈាម ក្អួតឈាម

៨. តើត្រូវធ្វើដូចម្តេច ពេលណាដែលសង្ស័យថាមនុស្សម្នាក់ឬកុមារមានជំងឺគ្រុនឈាម?

ចូរគូសហ៊ុំជុំវិញចម្លើយត្រឹមត្រូវ។ ចម្លើយត្រូវ ក

ក. ត្រូវបញ្ជូនកុមារមកទទួលការពិគ្រោះនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត និង រាយការណ៍មកមណ្ឌលសុខភាព និងការិយាល័យស្រុកប្រតិបត្តិ ជាបន្ទាន់ ។

ខ. ទៅគ្រូពេទ្យឯកជន

គ. ទៅគ្រូបុរាណ

ឃ. ព្យាបាលខ្លួនឯងនៅផ្ទះ

| | | |
|---|---|---|
| ៩. ព្រូនគឺជាពពួកប៉ារ៉ាស៊ីតចង្រៃម្យ៉ាងដែលអាចមាននៅក្នុងរាងកាយរបស់មនុស្ស សត្វ។ វារស់ដោយបឺតស្រូបយក ជីវជាតិពីមនុស្ស សត្វដើម្បីចិញ្ចឹមជីវិតរបស់វា។ | ត្រូវ | ខុស |

១០. នៅពេលមនុស្សកើតព្រូន តើមានលក្ខណៈសំគាល់អ្វីខ្លះ? ចម្លើយត្រឹមត្រូវទាំងអស់

1. ភាគច្រើនឈឺពោះ រាក ក្អួត
2. រមាស់គូថ ពិសេសពេលយប់
3. កុមារញ៉ាំច្រើនតែ មិនលូតលាស់ អត់មានកំលាំង
4. ពេលគេងមានភាពរសាប់រសល់ គេងមិនសូវលក់ស្រួល សុបិន្តអាក្រក់
5. មានរាងកាយស្លេកស្លាំង
6. រាកមូល ធ្លាក់ត្រសាល់គូថ
7. ធំពោះ

១១. មនុស្សកើតព្រូន ធ្វើឲ្យមានផលវិបាកអ្វីខ្លះ? ចម្លើយត្រឹមត្រូវទាំងអស់

ក. បាត់បង់កំលាំង

ខ. ស្លេកស្លាំង

គ. ខ្សោយបញ្ញា ស្មារតី

ឃ. យឺតយ៉ាវក្នុងការធំធាត់

ង. ស្ទះពោះវៀន (ព្រូនចង្កឹះ)

ច. ឧស្សាហ៍មានជំងឺឈឺពោះ ឬរាក (ព្រូនទំពក់)

១២. តើហេតុអ្វីបានជាមនុស្សយើងកើតព្រូន? ចម្លើយត្រឹមត្រូវទាំងអស់

1. បន្ទោរបង់(ជុះអាចម៍) ពាសវាលពាសកាល នៅក្បែរផ្ទះ ឬក្នុងគុម្ពោតព្រៃជិតៗផ្ទះ
2. ប្រើប្រាស់ទឹកមិនស្អាត ដូចជាញ៉ាំទឹកឆៅ ញ៉ាំបន្លែ ឬ ផ្លែឈើមិនបានលាងសំអាតមុនពេលបរិភោគ ត្រីសាច់ចំអិនមិនបានឆ្អិនល្អ
3. ដើរជើងទទេរ
4. ដៃមិនស្អាត យកមកលូកមាត់ ឬ ចាប់កាន់អាហារញ៉ាំជាដើម ។
5. មិនបានលាងសំអាតដៃក្រោយពេលចេញពីបន្ទោរបង់(ជុះអាចម៍) មុនបរិភោគអាហារ និង រៀបចំចំណីអាហារ
6. រុយទំលើលាមក សំរាម ឬ ទំលើគំរង់ខ្មោចសត្វរួចមកទំលើចំណីអាហារដែលយើងញ៉ាំ

១៣. ពេលអ្នកសង្ស័យថា មានកើតព្រូន តើអ្នកធ្វើដូចម្តេច? ចម្លើយត្រឹមត្រូវទាំងអស់

1. ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតផ្ទះ ដើម្បីទទួលការព្យាបាល
2. រៀងរាល់ ខែ ឧសភា និង ខែ វិច្ឆិកា តាមរយៈសេវាសុខាភិបាលចុះតាមមូលដ្ឋាន(ចាក់ថ្នាំបង្ការ....)
3. កុមារសិស្សសាលាបឋមសិក្សាទូទាំងប្រទេសត្រូវតែបានផ្តល់ថ្នាំ ទំលាក់ព្រូន ១ ដូស រៀងរាល់ ៦ ខែម្តង គឺខែ មករា និង ខែ មិថុនា តាមរយៈគ្រូប្រចាំថ្នាក់ ដែលបានសហការជាមួយបុគ្គលិកមណ្ឌលសុខភាព

១៤. តើត្រូវធ្វើដូចម្តេច ដើម្បីកុំឲ្យកើតព្រូន? ចម្លើយត្រឹមត្រូវទាំងអស់

1. លាងសំអាតដៃនឹងសាប៊ូ ឬផេះមុនពេលចាប់កាន់ចំណីអាហារ
2. ត្រូវញ៉ាំទឹកស្អាត ឬទឹកឆ្អិន (ដាំពុះយ៉ាងតិច ១នាទី)
3. ត្រូវញ៉ាំចំណីអាហារ ដែលចំអិនឆ្អិនបានល្អ ហើយគ្របអោយជិតកុំអោយរុយពោម
4. ត្រូវលាង បន្លែ ផ្លែឈើ ជាមួយទឹកស្អាត អោយបានស្អាតមុនបរិភោគ
5. ត្រូវពាក់ស្បែកជើងជានិច្ច
6. អនាម័យខ្លួនប្រាណ កាត់ក្រចកដៃ ក្រចកជើងអោយបានខ្លី
7. ជានិច្ចកាលត្រូវបន្ទោរបង់ក្នុងបង្គន់អនាម័យ

**ចំណងជើងមេរៀនទី ២៖ ជំងឺគ្រុនឈាម** **រយៈពេល ២ ម៉ោង**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

1. កំណត់និយមន័យនិងអាការៈនៃជំងឺគ្រុនឈាម
2. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺគ្រុនឈាម
3. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺគ្រុនឈាម

4. រៀបរាប់ពីសញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាម
5. រៀបរាប់ពីវិធានការការពារជំងឺគ្រុនឈាម

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សា
- រូបភាពទំព័រទី ១១៩ ១២០ ១២១ ១២៣ ១២៤ ១២៥ និង ១២៦
- ក្រដាស ដែលមានសរសេរសារនិយមន័យនិងអាការៈនៃជំងឺគ្រុនឈាម មូលហេតុ វិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យ សញ្ញាគ្រោះថ្នាក់វិធានការការពារជំងឺគ្រុនឈាម
- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត កន្ត្រៃ និងបង់ស្អិត។

**វិធីសាស្ត្របង្រៀន៖**

- បាឋកថា
- សំណួរបំផុសគំនិត
- ពិភាក្សាក្រុមធំ

**ដំណាក់កាលសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

**សេចក្តីផ្តើម៖** (ធ្វើការសន្ទនាបើអាចធ្វើបាន)៖

សូមស្វាគមន៍ម្តងទៀត ចំពោះកម្មវិធីបណ្តុះបណ្តាលម៉ូឌុលទី៥របស់យើង។ យើងសង្ឃឹមថា អ្នកទទួលបាន នូវបទពិសោធន៍ល្អៗច្រើន កាលពីម៉ូឌុលមុនៗដូចជាអ្នកបានសាកល្បង នូវសកម្មភាពជាក្រុមគ្រប់គ្រងភូមិ របស់អ្នក។ យើងនឹងពិភាក្សាគ្នាអំពីបទពិសោធន៍ខ្លះៗរបស់អ្នកនៅថ្ងៃនេះ។ យើងពេញចិត្តនឹងស្តាប់យោបល់ និងគំនិតផ្សេងៗរបស់អ្នកណាស់។

នៅក្នុងការបណ្តុះបណ្តាល លើកមុនៗកន្លងមក យើងបានជជែកគ្នាអំពីជំងឺរាក គ្រុនក្តៅ ជំងឺពងបែកដៃជើងនិងមាត់ ជំងឺផ្តាសាយ មូលហេតុ របៀបព្យាបាល ការស្វែងរកការថែទាំពេលមានសញ្ញាគ្រោះថ្នាក់ និងការការពារ ។ លើកនេះយើងនិង ពិភាក្សាគ្នាអំពីជំងឺគ្រុនឈាមនិងជំងឺដង្កូវពោះវៀន(ព្រូន) តើអ្នកយល់ឃើញយ៉ាងណាដែរ?

**វត្ថុបំណងទី ១៖កំណត់និយមន័យនិងអាការៈនៃជំងឺគ្រុនឈាម រយៈពេល ១៥នាទី**

➢ **សំណួរបំផុសគំនិត**

**សំណួរ៖** តើនៅក្នុងភូមិរបស់យើងឥឡូវនេះមានកុមារមានជំងឺគ្រុនឈាមឬទេ?

ដូចម្តេចដែលហៅថា ជំងឺគ្រុនឈាម? បង្ករមកពីអ្វី?ភ្នាក់ងារចម្លងជាអ្វី?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន

- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីនិយមន័យជំងឺគ្រុនឈាម

**ចម្លើយចូលរួម៖** ជំងឺគ្រុនឈាមជា ជំងឺឆ្លង និងរាតត្បាត បង្ករមកពីការជ្រៀតចូលទៅក្នុងខ្លួនមនុស្ស នូវមេរោគ វីរុសគ្រុនឈាម ភ្នាក់ងារចម្លង គឺមូសខ្លាញីខាំ ពិសេសពេលថ្ងៃ ។

**វត្ថុបំណងទី ២៖ ពន្យល់អំពីមូលហេតុដែលបង្កឱ្យមានជំងឺគ្រុនឈាម រយៈពេល ៣០នាទី**

- **ពិភាក្សាក្រុមធំ**

បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖























- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើអ្នកគិតថាមនុស្សម្នាក់ឆ្លងជំងឺគ្រុនឈាមយ៉ាងដូចម្តេច?

**ចម្លើយចូលរួម៖** មូលហេតុនៃជំងឺគ្រុនឈាម៖

1. ការស្តុកទឹកទុកនៅក្នុងពាង/ អាងទឹកដោយពុំបានគ្របឲ្យបានជិតល្អ
2. បោះចោលពាសវាលពាសការ នូវកាកសំណល់ សំបកកំប៉ុង សំបកកង់ឡានចាស់ៗ វត្ថុបាក់បែក សំបកដូង សំបកខ្ទៅខ្ទង ដែលជាមូលហេតុធ្វើឲ្យមានដក់ទឹក ជម្រកមូសខ្លា
3. កុមារតូច មនុស្សធំ មិនពាក់សំលៀកបំពាក់ឲ្យបានត្រឹមត្រូវ មិនគេងក្នុងមុងដោយ បណ្តោយឲ្យមូសខាំ ជាពិសេសពេលថ្ងៃ ។
4. ការផ្លាស់ប្តូរទីលំនៅ ឬ ទីតាំងរបស់ប្រជាជនពីតំបន់មួយទៅតំបន់មួយដែលបានស្នាក់ នៅ ឬ បានឆ្លងកាត់មួយរយៈក្នុងតំបន់ដែលមានការចម្លងខ្ពស់
5. កត្តាអាកាសធាតុ៖ បំរែបំរួលអាកាសធាតុ ទឹកភ្លៀង រដូវភ្លៀង ។

**វត្ថុបំណងទី ៣៖ រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺគ្រុនឈាម**

**រយៈពេល២៥នាទី**

➢ ពិភាក្សាក្រុមធំ

តើពេលណាដែលអ្នកសង្ស័យថាកុមារមានជំងឺគ្រុនឈាម?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ ចម្លើយចូលរួម

**ចម្លើយចូលរួម៖**

**រាល់កុមារដែលមានជំងឺគ្រុនក្តៅខ្លាំងភ្លាមៗ ៣៩ ដល់ ៤០អង្សាសេ រយៈពេល ២ ទៅ ៧ ថ្ងៃ រួមផ្សំនឹង/ ឬធាតុសញ្ញា ២ ឬច្រើនដូចខាងក្រោម៖**

⇒ មុខក្រហម និង ភ្នាសកែវភ្នែកក្រហម នឹង/ ឬ
⇒ ឈឺក្បាល ឬ
⇒ ឈឺផ្នែកខាងក្រោយក្នុងរង្វង់កែវភ្នែក ឬ
⇒ ឈឺសាច់ដុំ ឈឺសន្លាក់ ឬ
⇒ ដោលស្បែក ឬ
⇒ **សញ្ញានៃការហូរឈាម៖** ចេញឈាមតាមស្បែក (ស្នាមកន្ទួលក្រហម ឬជាំឈាម) ឬ ចេញឈាមតាមភ្នាស (ឈាមច្រមុះ ឬ អញ្ចាញធ្មេញ) ឬ តាមប្រដាប់រំលាយអាហារ (ក្អួតឈាម ជុះឈាម)

ត្រូវសង្ស័យថា កុមារប្រហែលជាគ្រុនឈាម ត្រូវបញ្ជូនកុមារមកទទួលការពិគ្រោះនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត និង រាយការណ៍មកមណ្ឌលសុខភាព និងការិយាល័យស្រុកប្រតិបត្តិ ជាបន្ទាន់ ។

**វត្ថុបំណងទី ៤៖ រៀបរាប់ពីសញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាមដែលត្រូវបញ្ជូនជាបន្ទាន់ទៅគ្រឹះស្ថានសុខាភិបាល**

**រយៈពេល ២០នាទី**

✓ **ពិភាក្សាក្រុមធំ**

បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖



សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំង តើសញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាមដែលត្រូវបញ្ជូនជាបន្ទាន់ទៅគ្រឹះស្ថានសុខាភិបាលមានអ្វីខ្លះ?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំចម្លើយចូលរួម

ចម្លើយចូលរួម៖

**រាល់កុមារដែលមានជំងឺគ្រុនក្តៅខ្លាំងភ្លាមៗ ៣៩ ដល់ ៤០ $^{0}$C រយះពេល ២ ទៅ ៧ ថ្ងៃ នឹងមានសញ្ញាណមួយចំនួនដូចខាងក្រោម៖**

- សន្លឹម ឬ កុមារឡេះឡះ
- អស់កម្លាំងខ្លាំង និង មានឈឺនៅក្នុងពោះដោយថ្លើមរីកធំ ហើយឈឺ ឬ ឈឺជាប់ជានិច្ច ។
- ស្បែកត្រជាក់-ស្អិត

ត្រូវបញ្ជូនកុមារមកទទួលការព្យាបាលជាបន្ទាន់ នៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត និងរាយការណ៍មកមណ្ឌលសុខភាព និងការិយាល័យស្រុកប្រតិបត្តិ ជាបន្ទាន់ ។

**វគ្គបំណងទី ៥៖ រៀបរាប់ពីវិធានការការពារជំងឺគ្រុនឈាម រយះពេល ៣០នាទី**

សេចក្តីផ្តើម៖

វិធានការការពារជំងឺគ្រុនឈាម ជាកាតព្វកិច្ចចាំបាច់របស់បុគ្គលិកម្នាក់ៗ ឬ ប្រជាជនគ្រប់ៗរូបដែលត្រូវទទួលខុសត្រូវផ្ទាល់ក្នុងការការពារកូន ឬសមាជិកគ្រួសាររបស់ខ្លួនដោយធ្វើអនាម័យជុំវិញ លំនៅដ្ឋាន និងទីធ្លាសាធារណជារៀងរាល់អាទិត្យ និងមានការទទួលខុសត្រូវដោយអាជ្ញាធរមូលដ្ឋាន ។

- ពិភាក្សាក្រុមធំ
  - បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖


1-2mm
2-3mm
3-4mm
4-7mm
1st instar
2nd instar
3rd instar








កប់វត្ថុដក់ទឹកបាន
គ្របពាង
លាងថូផ្កា
កាប់ឆ្ការព្រៃជុំវិញផ្ទះ








VectoBac WG


BASF













- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំចម្លើយចូលរួម

**ចម្លើយចូលរួម ៖**

ក. ជានិច្ចជាកាលដេកក្នុងមុង ឬ មុងជ្រលក់ថ្នាំ ពិសេសពេលគេងពេលថ្ងៃ ។

ខ. ផ្ទះត្រូវបើកទ្វារបង្អួចឲ្យមានពន្លឺថ្ងៃចេញចូល និងខោអាវត្រូវបត់ទុកដាក់ឲ្យបាន ត្រឹមត្រូវ។

គ. កាប់ឆ្ការព្រៃស៊ុបទ្រុបនៅជុំវិញផ្ទះឲ្យអស់ ។

ឃ. ត្រូវស្លៀកពាក់ខោអាវឲ្យបានជិតល្អ ហើយឲ្យកុមារលេងនៅកន្លែងណាដែលមានពន្លឺថ្ងៃចេញចូលជានិច្ច កុំឲ្យកុមារលេងកន្លែងងងឹត និងដេកក្នុងមុងនៅពេលថ្ងៃ ។

ង. ការធ្វើអនាម័យសំអាតលំនៅដ្ឋានរៀងៗខ្លួន

ច. បំបាត់ដង្កូវទឹកដោយៈ

- លាងពាងឬអាងទឹក ធុងទឹក ថូផ្កាកុំឲ្យមានដង្កូវទឹក ឲ្យបានជារៀងរាល់អាទិត្យ
- ប្រមូលរាល់វត្ថុដែលដក់ទឹក នៅជុំវិញបរិវេណផ្ទះយកទៅដុត ឬកប់ចោល ឲ្យបានជារៀងរាល់អាទិត្យ
- ខាប់ ក្រឡ ចានដាក់ទឹកសំរាប់មាន់ ទា ទូកដែលដាក់លើគោកសំរាប់បិទជ័រទឹកត្រូវចាំបាច់

ផ្កាប់ចាក់ទឹកចោលឲ្យបានជារៀងរាល់អាទិត្យ ឬផ្កាប់ចុះ

- ចានទម្រជើងទូត្រូវចាំបាច់ដាក់អំបិលបន្តិច
- ដាក់ត្រី ៧ពណ៌ក្នុងពាង ឬអាងទឹក ដើម្បីឲ្យស៊ីដង្កូវទឹក ឬ ដាក់ថ្នាំអាបេត ឬថ្នាំបីធីអាយ ឬ គ្របពាង/អាងទាំងនោះឲ្យបានជិតល្អ

**សង្ខេបម៉ូឌុល**

អ្នកសម្របសម្រួលសង្ខេបខ្លឹមសារមេរៀនតាមវត្ថុបំណងនិមួយៗ

1. កំណត់និយមន័យនិងអាការៈនៃជំងឺគ្រុនឈាម
2. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺគ្រុនឈាម
3. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺគ្រុនឈាម
4. រៀបរាប់ពីសញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាម
5. រៀបរាប់ពីវិធានការការពារជំងឺគ្រុនឈាម

**ចំណងជើងមេរៀនទី ៣៖ ជំងឺដង្កូវពោះវៀន (ព្រូន)** **រយៈពេល ២ ម៉ោង**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹងអាច ៖

1. កំណត់និយមន័យនិងលក្ខណៈសំគាល់នៃជំងឺដង្កូវពោះវៀន
2. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺដង្កូវពោះវៀន
3. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺដង្កូវពោះវៀន
4. រៀបរាប់ពីវិធានការការពារជំងឺដង្កូវពោះវៀន

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ ដែលមានសរសេរអំពីវត្ថុបំណងនៃការសិក្សា
- រូបភាពទំព័រទី ១២៩ ១៣០ ១៣១ ១៣២ ១៣៣ ១៣៤ និង ១៣៥
- ក្រដាស ដែលមានសរសេរសារនិយមន័យនិងលក្ខណៈសំគាល់ មូលហេតុ វិធានការដែលត្រូវអនុវត្ត វិធានការការពារ ជំងឺដង្កូវពោះវៀន
- ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត កន្រ្តៃ និងបង់ស្កុត។

**វិធីសាស្រ្តបង្រៀន៖**

- បាឋកថា
- សំណួរបំផុសគំនិត
- ពិភាក្សាក្រុមធំ

**ដំណាក់កាលសកម្មភាព៖**

**បង្ហាញវត្ថុបំណងរួម**

1. កំណត់និយមន័យនិងលក្ខណៈសំគាល់នៃជំងឺដង្កូវពោះវៀន
2. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺដង្កូវពោះវៀន
3. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺដង្កូវពោះវៀន
4. រៀបរាប់ពីវិធានការការពារជំងឺដង្កូវពោះវៀន

**វត្ថុបំណងទី ១៖កំណត់និយមន័យនិងលក្ខណៈសំគាល់ជំងឺដង្កូវពោះវៀន (ព្រូន) រយៈពេល ៣០នាទី**

➢ **សំណួរបំផុសគំនិត**

**សំណួរ៖** ដូចម្ដេចដែលហៅថាព្រូន?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្ដារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីនិយមន័យព្រូន

**ចម្លើយ៖** ព្រូនគឺជាពពួកប៉ារ៉ាស៊ីតចង្រៃម្យ៉ាងដែលអាចមាននៅក្នុងរាងកាយរបស់មនុស្ស សត្វ។ វារស់ដោយបឺតស្រូបយក ជីវជាតិពីមនុស្ស សត្វដើម្បីចិញ្ចឹមជីវិតរបស់វា។

**សំណួរ៖** តើ ព្រូន ចូលក្នុងរាងកាយមនុស្សយើង ដោយរបៀបណា?

**ចម្លើយ៖** ព្រូនខ្លះអាចមើលឃើញ នៅពេលវាចេញមកក្រៅតាមលាមក ។ ជួនកាលព្រូនអាចចេញមកក្រៅតាមមាត់ ។ ព្រូនខ្លះតូច ៗ ណាស់ យើងមិនអាចមើលឃើញវាទេ តែយើងអាចមើលវាឃើញតាមរយៈការពិនិត្យលាមក ដោយឧបករណ៍មីក្រូទស្សន៍។

ព្រូនចង្កឹះ ព្រូនរំពាត់សេះ ព្រូនអៀន ចូលរាងកាយយើងតាមរយៈមាត់មនុស្ស ដោយហូបចូលនូវពងព្រូន ព្រូនទំពក់ ចូលរាងកាយយើងតាមរយៈការចូលព្រូនតាមបាតជើង

និងព្រូនសសៃចូលរាងកាយយើងតាមរយៈការចូលព្រូនតាមមាត់




ព្រូនចង្កឹះ **(*Ascaris lumbricoide*)**




ព្រូនរំពាត់សេះ **(*Trichuris trichiura*)**




ដង្កូវព្រូនអៀន **(*Enterobius vermicularus*)**




ជំងឺស៊ីស្តូសូមីញ៉ាស៊ីស មេគង្គ **(*Schistosomiasia mekongi*)**




ព្រូនទំពក់ *(Hookworms)*




ដង្កូវព្រូន អង្គីលីល ឬ ព្រូនសសៃ ***(Strongyloide stercoralis)***







ជំងឺព្រូនអំបោះ

នៅពេលមនុស្សកើតជំងឺដង្កូវពោះវៀន(ព្រូន) តើមានលក្ខណ:សំគាល់អ្វីខ្លះ?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ អំពីលក្ខណ:សំគាល់ជំងឺដង្កូវពោះវៀន

**ចម្លើយចូលរួម៖** រោគសញ្ញាលក្ខណ:សំគាល់ជំងឺដង្កូវពោះវៀន (ព្រូន)

– ភាគច្រើនឈឺពោះ រាក ក្អួត
– រមាស់គូថ ពិសេសពេលយប់
– កុមារញាំច្រើនតែ មិនលូតលាស់ អត់មានកំលាំង
– ពេលគេងមានភាពរសាប់រសល់ គេងមិនសូវលក់ស្រួល សុបិន្តអាក្រក់
– មានរាងកាយស្លេកស្លាំង
– រាកមូល ធ្លាក់ត្រសាល់គូថ
– ធំពោះ

មនុស្សកើតព្រូន ធ្វើឲ្យមានផលវិបាកអ្វីខ្លះ?

**ចម្លើយ៖** ផលវិបាករបស់មនុស្សកើតព្រូន

- បាត់បង់កំលាំង
- ស្លេកស្លាំង
- ខ្សោយបញ្ញា ស្មារតី
- យឺតយ៉ាវក្នុងការធំធាត់
- ស្ទះពោះវៀន (ព្រូនចង្កឹះ)
- ឧស្សាមានជំងឺឈឺពោះ ឬរាក (ព្រូនទំពក់)

**ចន្លុះបំណងទី ២៖ ពន្យល់អំពីមូលហេតុដែលបង្កឱ្យមានជំងឺដង្កូវពោះវៀន (ព្រូន) រយៈពេល ៣០នាទី**

- **ពិភាក្សាក្រុមធំ**

បិទរូបនេះនៅចំពោះមុខសិក្ខាកាម៖













សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ តើអ្នកគិតថាមនុស្សម្នាក់ឆ្លងជំងឺដង្កូវព្រូនយ៉ាងដូចម្តេច?

**ចម្លើយចូលរួម៖** មូលហេតុនៃជំងឺដង្កូវព្រូន៖

- ខ្វះការយល់ដឹងអំពីអនាម័យ បន្ទោរបង់ (ជុះអាចម៍) ពាសវាលពាសកាល នៅក្បែរផ្ទះ ឬ ក្នុងគុម្ពោតព្រៃជិតៗផ្ទះ
- ដៃមិនស្អាត យកមកលូកមាត់ ឬ ចាប់កាន់អាហារញ៉ាំជាដើម ។
- ដើរជើងទទេរ
- មិនលាងសំអាតដៃក្រោយពេលចេញពីបន្ទោរបង់ (ជុះអាចម៍) មុនបរិភោគអាហារ និង រៀបចំចំណីអាហារ
- រុយទំលើលាមក សំរាម ឬ ទំលើគំរង់ខ្មោចសត្វ
- ការប្រើប្រាស់ទឹកមិនស្អាត ដូចជាញ៉ាំទឹកឆៅ ញ៉ាំបន្លែ ឬ ផ្លែឈើមិនបានលាងសំអាតមុនពេលបរិភោគ ត្រីសាច់ចំអិនមិនបានឆ្អិនល្អ

**សកម្មភាពទី ៣៖ រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេល សង្ស័យថាមានជំងឺដង្កូវពោះវៀន**

**រយៈពេល៣០នាទី**

➢ ពិភាក្សាក្រុមធំ

តើអ្នកត្រូវធ្វើដូចម្តេចពេលអ្នកសង្ស័យថាកុមារឬមនុស្សធំមានជំងឺដង្កូវពោះវៀន?

- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម

- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំ ចម្លើយចូលរួម

**ចម្លើយចូលរួម៖ Mebendazole500mg/Albendazole** ដល់ក្រុមគោលដៅ

- គ្រប់កុមារទាំងអស់ដែល មានអាយុ ចាប់ពី ១២ ខែ ដល់ ៥៩ ខែត្រូវទៅមណ្ឌលសុខភាព ដើម្បីទទួលថ្នាំទំលាក់ព្រូន ១ ដូស (លេបតែម្តង) រៀងរាល់ ខែ ឧសភា និង ខែ វិច្ឆិកា តាមរយៈសេវាសុខាភិបាលចុះតាមមូលដ្ឋាន(ចាក់ថ្នាំបង្ការ ...........)។

⇒ កុមារមានអាយុចាប់ពី ១២ ទៅ ២៣ ខែ ត្រូវអោយ Mebendazole500mg កន្លះគ្រាប់ (កាច់ថ្នាំជា ២ កំណាត់គឺស្មើនឹង ២៥០ ម.ក្រ) ទំពារលេបតែម្តង បើកុមារតូចមិនអាច ទំពារបាន ត្រូវកិនអោយ ម៉ត់ ដាក់នឹងស្លាបព្រា លាយ ទឹកបន្តិចជាជំនួយ ។

⇒ កុមារអាយុចាប់ពី ២ ឆ្នាំឡើងទៅត្រូវអោយ Mebendazole500mg មួយគ្រាប់លេបតែម្តងដោយទំពារ។ បើកុមារពិបាកលេបត្រូវផឹកទឹកបន្តិច ។

<u>កំណត់សំគាល់:</u> ថ្នាំព្រូនប្រភេទ Mebendazole500mg ងាយស្រួលក្នុងការទំពារលេប និង គ្មានផ្តល់ផលវិបាកអ្វីឡើយ ។

- កុមារសិស្សសាលាបឋមសិក្សាទូទាំងប្រទេសត្រូវតែបានផ្តល់ថ្នាំ ទំលាក់ព្រូន ១ ដូស (លេបតែម្តង) រៀងរាល់ ៦ ខែម្តង គឺខែ មករា និង ខែ មិថុនា តាមរយៈគ្រូប្រចាំថ្នាក់ ដែលបានសហការជាមួយបុគ្គលិកមណ្ឌលសុខភាព។

- ត្រូវផ្តល់ថ្នាំទំលាក់ព្រូន (Mebendazole) មួយដូសដល់គ្រប់ស្ត្រីមានគភ៌ ចាប់ពី ៤ ខែ ដល់ ៩ ខែ និងស្ត្រីក្រោយសំរាល នៅមណ្ឌលសុខភាព និង តាមសេវាសុខភាពចុះមកតាមមូលដ្ឋាន។

- ស្ត្រីស្ថិតក្នុងវ័យបន្តពូជ អាយុ ១៥-៤៩ ឆ្នាំ គួរតែទទួលថ្នាំទំលាក់ព្រូន (Mebendazole) មួយដូសយ៉ាងហោចណាស់អោយបានម្តងក្នុង ១ ឆ្នាំ ។

**ចំណុចទី ៤៖ របៀបទប់ពីទានការការពារជំងឺដង្កូវពោះវៀន រយៈពេល ៣០នាទី**

ពិភាក្សាក្រុមធំ

បិទរូបនេះនៅចំពោះមុខសិក្ខាកាម






សាប៊ូ
















- សុំឱ្យសិក្ខាកាម ក្រឡេកមើលរូបភាពទាំងនេះ
- កត់ត្រាចម្លើយសិក្ខាកាមនៅលើក្តារខៀន
- សម្របសម្រួលចម្លើយសិក្ខាកាម
- បង្ហាញចម្លើយនៅលើក្រដាសផ្ទាំងធំចម្លើយចូលរួម

ចម្លើយចូលរួម ៖

ត្រូវអនុវត្តជារៀងរាល់ថ្ងៃអំពីក្បួនអនាម័យ ដូចតទៅ៖

- លាងសំអាតដៃនឹងសាប៊ូ ឬផេះមុនពេលចាប់កាន់ចំណីអាហារ
- ត្រូវញ៉ាំទឹកស្អាត ឬទឹកឆ្អិន (ដាំពុះយ៉ាងតិច ១នាទី)
- ត្រូវញ៉ាំចំណីអាហារ ដែលចំអិនឆ្អិនបានល្អ ហើយគ្របអោយជិតកុំអោយរុយពោម
- ត្រូវលាង បន្លែ ផ្លែឈើ ជាមួយទឹកស្អាត អោយបានស្អាតមុនបរិភោគ
- ត្រូវពាក់ស្បែកជើងជានិច្ច
- អនាម័យខ្លួនប្រាណ កាត់ក្រចកដៃ ក្រចកជើងអោយបានខ្លី
- ជានិច្ចកាលត្រូវបន្ទោរបង់ក្នុងបង្គន់អនាម័យ

**សង្ខេបម៉ូឌុល**

អ្នកសម្របសម្រួលសង្ខេបខ្លឹមសារមេរៀនតាមវត្ថុបំណងនិមួយៗ

1. កំណត់និយមន័យនិងអាការៈនៃជំងឺគ្រុនឈាម
2. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺគ្រុនឈាម
3. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺគ្រុនឈាម

4. រៀបរាប់ពីសញ្ញាគ្រោះថ្នាក់នៃជំងឺគ្រុនឈាម
5. រៀបរាប់ពីវិធានការការពារជំងឺគ្រុនឈាម
6. កំណត់និយមន័យនិងលក្ខណៈសំគាល់នៃជំងឺដង្កូវពោះវៀន
7. ពិភាក្សាអំពីមូលហេតុដែលបង្កឲ្យមានជំងឺដង្កូវពោះវៀន
8. រៀបរាប់ពីវិធានការដែលត្រូវអនុវត្តពេលជួបករណីសង្ស័យថាមានជំងឺដង្កូវពោះវៀន
9. រៀបរាប់ពីវិធានការការពារជំងឺដង្កូវពោះវៀន

**មេរៀនទី៤៖ សង្ខេបម៉ូឌុល និងការធ្វើតេស្តក្រោយពេលសិក្សា រយៈពេល ៣០នាទី**

**វត្ថុបំណងនៃការសិក្សា៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងអាច ៖

១. រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ

២. វាយតម្លៃចំណេះដឹងក្រោយវគ្គសិក្សា តាមរយៈការធ្វើតេស្តក្រោយពេលសិក្សា

**សម្ភារៈជំនួយបង្រៀន៖**

- ក្រដាសផ្ទាំងធំ មានសរសេរពីវត្ថុបំណងម៉ូឌុល
- ក្រដាសផ្ទាំងធំ មានសារគន្លឹះសម្រាប់ម៉ូឌុលនេះ
- ហ្វឺតសម្រាប់សរសេរ, បង់ស្អិត
- បញ្ជីសំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

**វិធីសាស្ត្របង្រៀន៖**

- ពិភាក្សាក្រុម
- តេស្តក្រោយវគ្គសិក្សា

**ជំហានសកម្មភាព៖**

**បង្ហាញពីវត្ថុបំណងរួម៖**

**សេចក្តីផ្តើម៖** អ្នកសម្របសម្រួលពន្យល់ថា នេះគឺជាមេរៀនចុងក្រោយសម្រាប់ម៉ូឌុលនេះ។

**វត្ថុបំណងទី១៖ រៀបរាប់ពីសារគន្លឹះ និងចំណុចសង្ខេបសម្រាប់ម៉ូឌុលនេះ (១៥នាទី)**

**ពិភាក្សាក្រុម**

- អ្នកសម្របសម្រួល ដឹកនាំសិក្ខាកាមពិភាក្សាពីចំណុចសង្ខេប និងសារគន្លឹះសម្រាប់ម៉ូឌុលនេះ។ អ្នក សម្របសម្រួលត្រូវបិទសារគន្លឹះនៅលើក្រដាសផ្ទាំងធំ ដើម្បីឱ្យសិក្ខាកាមមើល និងអាន។
- បន្ទាប់មក អ្នកសម្របសម្រួល សួរសិក្ខាកាមថា តើមានសំណួរអ្វីទេ?

## វគ្គបំណងទី ២៖ វាយតម្លៃចំណេះដឹងតាមរយៈការធ្វើតេស្តក្រោយពេលសិក្សា (១៥នាទី)

អ្នកសម្របសម្រួលប្រាប់សិក្ខាកាមថា មុននឹងយើងបញ្ចប់ម៉ូឌុលនេះ យើងនឹងធ្វើតេស្តក្រោយពេលសិក្សាខ្លី មួយ។ តេស្តនេះគឺដូចគ្នានឹងតេស្តមុនពេលសិក្សាដែលអ្នកទាំងអស់គ្នាបានធ្វើមុនចាប់ផ្តើមម៉ូឌុលនេះដែរ។ ការធ្វើតេស្តបែបនេះ គឺដើម្បីវាស់ពីចំណេះដឹងសិក្ខាកាមនៅមុននឹងក្រោយពេលសិក្សា ដើម្បីចង់ដឹងថា តើអ្នក ទាំងអស់គ្នា បានទទួលចំណេះដឹងប៉ុណ្ណាពីវគ្គនេះ។ ដូច្នេះសូមកុំព្រួយបារម្ភ ប្រសិនបើអ្នកមិនចេះសំណួរណាមួយនោះ។

បន្ទាប់មក ចែកសំណួរតេស្តដល់សិក្ខាកាម។

ក្រោយពីសិក្ខាកាមបានធ្វើតេស្តក្រោយពេលសិក្សាចប់ អ្នកសម្របសម្រួលត្រូវបូកសរុបចម្លើយ ហើយប្រៀប-ធៀបនឹងលទ្ធផលតេស្តមុនពេលសិក្សា។

## សំណួរសម្រាប់ធ្វើតេស្តក្រោយពេលសិក្សា

សំណួរ “ត្រូវ ឬ ខុស” (សំណួរត្រូវ ត្រូវបានបង្ហាញក្នុងប្រអប់ខ្មៅ)

| | | |
|---|---|---|
| ១. ជំងឺគ្រុនឈាមជា ជំងឺឆ្លង និងរាតត្បាត បណ្តាលពី មូសខ្លាញ់ខាំ ពិសេសពេលថ្ងៃ | ត្រូវ | ខុស |
| ២. មូសខ្លាញ់កើតចេញពីដង្កូវទឹក ដែលកើតនៅក្នុងទឹកដក់ | ត្រូវ | ខុស |

៣. សូមគូសធីក នូវចម្លើយដែលជាមូលហេតុនាំឲ្យកើតដង្កូវទឹក។ ចម្លើយត្រឹមត្រូវគឺ ទាំងអស់

☐ ការស្តុកទឹកទុកនៅក្នុងពាង/ អាងទឹកដោយពុំបានគ្របឲ្យបានជិតល្អ

☐ បោះចោលពាសវាលពាសកាល នូវកាកសំណល់ សំបកកំប៉ុង សំបកកង់ឡានចាស់ៗ វត្ថុបាក់បែក សំបកដូង សំបកខ្ទៅខ្ចង ដែលជាមូលហេតុធ្វើឲ្យមានដក់ទឹក ជម្រកមូសខ្លា

☐ រដូវភ្លៀងធ្លាក់

៤. សូមគូសធីក នូវចម្លើយត្រឹមត្រូវសំរាប់កំចាត់ដង្កូវទឹក។ ចម្លើយត្រឹមត្រូវគឺ ទាំងអស់

☐ លាងពាង/អាងទឹក ធុងទឹកកុំឲ្យមានដង្កូវទឹក ឲ្យបានជាទៀងរាល់អាទិត្យ

☐ ប្រមូលរាល់វត្ថុដែលដក់ទឹក នៅជុំវិញបរិវេណផ្ទះយកទៅដុត ឬកប់ចោលឲ្យបានជាទៀងរាល់អាទិត្យ

☐ ខាប់ ក្រឡ ចានដាក់ទឹកសំរាប់ មាន់ ទា ទូកដែលដាក់លើគោកសំរាប់បិទជ័រទឹកត្រូវចាំបាច់ផ្កាប់ចាក់ទឹកចោលឲ្យបានជាទៀងរាល់អាទិត្យ ឬផ្កាប់ចុះ

☐ ចានទម្រជើងទូត្រូវចាំបាច់ដាក់អំបិលបន្តិច

☐ ដាក់ត្រី ៧ ពណ៌ក្នុងពាង/អាងទឹកឲ្យស៊ីដង្កូវទឹក ឬ ដាក់ថ្នាំបាណកឃាដសម្លាប់ដង្កូវទឹក ដូចជា ថ្នាំអាបេត ឬ ប៊ីធីអាយ ឬ គ្របពាង/អាងទាំងនោះឲ្យបានជិតល្អ។

៥. តើមូសខ្លាញ់ខាំមនុស្សនៅពេលណា?សូមគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ។ ចម្លើយត្រឹមត្រូវគឺ ក ខ គ និង ឃ

ក. ពេលព្រឹក

ខ. ពេលថ្ងៃ

គ. ពេលរសៀល

ឃ. ពេលល្ងាច

ង. ពេលយប់

៦. តើត្រូវធ្វើដូចម្តេចដើម្បីកុំឲ្យមូសខ្លាញ់ខាំ?

ក. ជានិច្ចជាកាលដេកក្នុងមុង ឬ មុងជ្រលក់ថ្នាំ ពិសេសពេលដេកពេលថ្ងៃ ។

ខ. ផ្ទះត្រូវបើកទ្វារបង្អួចឲ្យមានពន្លឺថ្ងៃចេញចូល និងខោអាវត្រូវបត់ទុកដាក់ឲ្យបាន ត្រឹមត្រូវ។

គ. កាប់ឆ្ការព្រៃស៊ុបទ្រុបនៅជុំវិញផ្ទះឲ្យអស់ ។

ឃ. ត្រូវស្លៀកពាក់ខោអាវឲ្យបានជិតល្អ ហើយឲ្យកុមារលេងនៅកន្លែងណាដែលមានពន្លឺថ្ងៃចេញចូលជានិច្ច កុំឲ្យកុមារលេងកន្លែងងងឹត និងដេកក្នុងមុងនៅពេលថ្ងៃ ។

ង. ការធ្វើអនាម័យសំអាតលំនៅដ្ឋានរៀងៗខ្លួន

ច. បំបាត់ដង្កូវទឹកដោយៈ

- លាងពាងឬអាងទឹក ផុងទឹក ថូផ្កាកុំឲ្យមានដង្កូវទឹក ឲ្យបានជារៀងរាល់អាទិត្យ
- ប្រមូលរាល់វត្ថុដែលដក់ទឹក នៅជុំវិញបរិវេណផ្ទះយកទៅដុត ឬកប់ចោល ឲ្យបានជារៀងរាល់អាទិត្យ
- ខាប់ ក្រឡ ចានដាក់ទឹកសំរាប់មាន់ ទា ទូកដែលដាក់លើគោកសំរាប់បិទជ័រទឹកត្រូវចាំបាច់ផ្កាប់ចាក់ទឹកចោលឲ្យបានជារៀងរាល់អាទិត្យ ឬផ្កាប់ចុះ
- ចានទម្រជើងទូត្រូវចាំបាច់ដាក់អំបិលបន្តិច
- ដាក់ត្រី ៧ពណ៌ក្នុងពាង ឬអាងទឹក ដើម្បីឲ្យស៊ីដង្កូវទឹក ឬ ដាក់ថ្នាំអាបេត ឬថ្នាំប៊ីធីអាយ ឬ គ្របពាង/អាងទាំងនោះឲ្យបានជិតល្អ

៧. តើពេលណាដែលសង្ស័យថាមនុស្សម្នាក់ឬកុមារមានជំងឺគ្រុនឈាម?ចម្លើយត្រឹមត្រូវទាំងអស់

ក. កុមារក្តៅខ្លួន(គ្រុនក្តៅ) ៣៩ ដល់ ៤០អង្សាសេ រយៈពេល ២ ទៅ ៧ ថ្ងៃ

ខ. កុមារក្អួត

គ. កុមារដេកសន្លឹម ឬទ្បេះទ្បះ

ឃ.មានចំណុចក្រហមក្រោមស្បែក

ង. មានសញ្ញាចេញឈាមណាមួយដូចជា៖ ឈាមច្រមុះ ឈាមអញ្ចាញធ្មេញ ជុះឈាម ក្អួតឈាម

៨. តើត្រូវធ្វើដូចម្ដេច ពេលណាដែលសង្ស័យថាមនុស្សម្នាក់ឬកុមារមានជំងឺគ្រុនឈាម?

ចូរគូសហ៊ុំជុំវិញចម្លើយត្រឹមត្រូវ។ ចម្លើយត្រូវ ក

ក. ត្រូវបញ្ជូនកុមារមកទទួលការពិគ្រោះនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត និង រាយការណ៍មកមណ្ឌលសុខភាព និងការិយាល័យស្រុកប្រតិបត្តិ ជាបន្ទាន់ ។

ខ. ទៅគ្រូពេទ្យឯកជន

គ. ទៅគ្រូបុរាណ

ឃ. ព្យាបាលខ្លួនឯងនៅផ្ទះ

| | | |
|---|---|---|
| ៩. ព្រូនគឺជាពពួកប៉ារ៉ាស៊ីតចង្រៃម្យ៉ាងដែលអាចមាននៅក្នុងរាងកាយរបស់មនុស្ស សត្វ។ វារស់ដោយបឺតស្រូបយក ជីវជាតិពីមនុស្ស សត្វដើម្បីចិញ្ចឹមជីវិតរបស់វា។ | ត្រូវ | ខុស |

១០. នៅពេលមនុស្សកើតព្រូន តើមានលក្ខណៈសំគាល់អ្វីខ្លះ? ចម្លើយត្រឹមត្រូវទាំងអស់

1. ភាគច្រើនឈឺពោះ រាក ក្អួត
2. រមាស់គូថ ពិសេសពេលយប់
3. កុមារញ៉ាំច្រើនតែ មិនលូតលាស់ អត់មានកំលាំង
4. ពេលគេងមានភាពរសាប់រសល់ គេងមិនសូវលក់ស្រួល សុបិន្តអាក្រក់
5. មានរាងកាយស្លេកស្លាំង
6. រាកមូល ធ្លាក់ត្រសាល់គូថ
7. ធំពោះ

១១. មនុស្សកើតព្រូន ធ្វើឲ្យមានផលវិបាកអ្វីខ្លះ? ចម្លើយត្រឹមត្រូវទាំងអស់

ក. បាត់បង់កំលាំង

ខ. ស្លេកស្លាំង

គ. ខ្សោយបញ្ញា ស្មារតី

ឃ. យឺតយ៉ាវក្នុងការធំធាត់

ង. ស្ទះពោះវៀន (ព្រូនចង្កឹះ)

ច. ឧស្សាហ៍មានជំងឺឈឺពោះ ឬរាក (ព្រូនទំពក់)

១២. តើហេតុអ្វីបានជាមនុស្សយើងកើតព្រូន? ចម្លើយត្រឹមត្រូវទាំងអស់

1. បន្ទោរបង់(ជុះអាចម៍) ពាសវាលពាសកាល នៅក្បែរផ្ទះ ឬក្នុងគុម្ពោតព្រៃជិតៗផ្ទះ
2. ប្រើប្រាស់ទឹកមិនស្អាត ដូចជាញុំាទឹកឆៅ ញុំាបន្លែ ឬ ផ្លែឈើមិនបានលាងសំអាតមុនពេលបរិភោគ ត្រីសាច់ចំអិនមិនបានឆ្អិនល្អ
3. ដើរជើងទទេរ
4. ដៃមិនស្អាត យកមកលូកមាត់ ឬ ចាប់កាន់អាហារញុំាជាដើម ។
5. មិនបានលាងសំអាតដៃក្រោយពេលចេញពីបន្ទោរបង់(ជុះអាចម៍) មុនបរិភោគអាហារ និង រៀបចំចំណីអាហារ
6. រុយទំលើលាមក សំរាម ឬ ទំលើគំរង់ខ្មោចសត្វរួចមកទំលើចំណីអាហារដែលយើងញុំា

១៣. ពេលអ្នកសង្ស័យថា មានកើតព្រូន តើអ្នកធ្វើដូចម្តេច? ចម្លើយត្រឹមត្រូវទាំងអស់

1. ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតផ្ទះ ដើម្បីទទួលការព្យាបាល
2. រៀងរាល់ ខែ ឧសភា និង ខែ វិច្ឆិកា តាមរយៈសេវាសុខាភិបាលចុះតាមមូលដ្ឋាន(ចាក់ថ្នាំបង្ការ.....)
3. កុមារសិស្សសាលាបឋមសិក្សាទូទាំងប្រទេសត្រូវតែបានផ្តល់ថ្នាំ ទំលាក់ព្រូន ១ ដូស រៀងរាល់ ៦ ខែម្តង គឺខែ មករា និង ខែ មិថុនា តាមរយៈគ្រូប្រចាំថ្នាក់ ដែលបានសហការជាមួយបុគ្គលិកមណ្ឌលសុខភាព

១៤. តើត្រូវធ្វើដូចម្តេច ដើម្បីកុំឲ្យកើតព្រូន? ចម្លើយត្រឹមត្រូវទាំងអស់

1. លាងសំអាតដៃនឹងសាប៊ូ ឬផេះមុនពេលចាប់កាន់ចំណីអាហារ
2. ត្រូវញុំាទឹកស្អាត ឬទឹកឆ្អិន (ដាំពុះយ៉ាងតិច ១នាទី)
3. ត្រូវញុំាចំណីអាហារ ដែលចំអិនឆ្អិនបានល្អ ហើយគ្របអោយជិតកុំអោយរុយពោម
4. ត្រូវលាង បន្លែ ផ្លែឈើ ជាមួយទឹកស្អាត អោយបានស្អាតមុនបរិភោគ
5. ត្រូវពាក់ស្បែកជើងជានិច្ច
6. អនាម័យខ្លួនប្រាណ កាត់ក្រចកដៃ ក្រចកជើងអោយបានខ្លី
7. ជានិច្ចកាលត្រូវបន្ទោរបង់ក្នុងបង្គន់អនាម័យ